# សូមក្រាបបង្គំទូលថ្វាយ
# ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
# ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា



## ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត

### ក្នុងឱកាសដ៏មហានក្ខត្តឫក្សឧត្តុង្គឧត្តមថ្លៃថ្លាបំផុតនៃព្រះរាជពិធីច្រារព្ធខួបលើកទី ១០ នៃការគ្រងរាជសម្បត្តិរបស់ព្រះករុណា ជាអម្ចាស់

*ទូលព្រះបង្គំយើងខ្ញុំសូមព្រះបរមរាជានុញ្ញាតថ្វាយព្រះរាជស័ព្ទសាធុការពរ សិរីសួស្តី ជ័យមង្គល បវរមហាប្រសើរ ថ្វាយព្រះករុណាជាអម្ចាស់ សូមព្រះអង្គមានព្រះរាជសុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ព្រះបញ្ញាញាណភ្លឺថ្លា ព្រះជន្មាយុយឺនយូរ និងសម្រេចបានព្រះមហាជោគជ័យសិរីមង្គលគ្រប់ប្រការ ប្រកបដោយព្រះតេជបារមីភ្លឺចិញ្ចាចចិញ្ចែង ដើម្បីគង់នៅជាម្លប់ដ៏ត្រជាក់ត្រជុំរបស់ប្រជារាស្ត្រកម្ពុជាគ្រប់រូប ។*

*រយៈពេល ១០ ឆ្នាំ នៃការឡើងគ្រងរាជសម្បត្តិរបស់ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង បាននាំមកនូវភាពកក់ក្តៅ និងភាពសុខក្សេមក្សាន្ត ចំរុងចម្រើនឥតឈប់ឈររបស់ប្រទេសជាតិ និងប្រជារាស្ត្រកម្ពុជាទាំងមូល ។*

*សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាថែរក្សាព្រះមហាស្វេតច្ឆ័ត្រ និងព្រះបារមីអតីតព្រះ មហាក្សត្រ ព្រះមហាក្សត្រិយានីខ្មែរគ្រប់ព្រះអង្គ សូមប្រោះព្រំ ទ្រទ្រង់ថែរក្សាព្រះករុណាជាទីគោរព សក្ការៈ ជានិច្ចនិរន្តរ៍តរៀងទៅ ។*

*សូមព្រះករុណាថ្លៃវិសេស ទ្រង់ព្រះរាជមេត្តាប្រោស ទទួលនូវគារវភក្តីដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំយើងខ្ញុំ ។*

**ក្រាបបង្គំទូលថ្វាយដោយក្តីគោរព និងកតញ្ញូតាធម៌ដ៏ខ្ពង់ខ្ពស់បំផុត**

**ទស្សនាវដ្តីប្រជាជន**

# សូមប្រសិទ្ធពរបវរមហាប្រសើរជូន

# សម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

## ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា
## និងជាប្រធានគណបក្សប្រជាជនកម្ពុជា



## ក្នុងឱកាសដ៏មហានក្ខត្តឫក្សនៃទិវាគម្រប់ជន្មាយុ ៨២ វស្សា ឈានចូល ៨៣ វស្សារបស់សម្ដេច
## (១៥.១១.១៩៣២-១៥.១១.២០១៤)

យើងខ្ញុំទាំងអស់គ្នាសូមសម្ដែងគារវភក្តី និងកតញ្ញូតាធមិដ៏ជ្រាលជ្រៅបំផុតជូនសម្ដេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** អគ្គមគ្គុទេសដ៏វិសេសវិសាលនៃប្រជាជនកម្ពុជា ដែលបានតស៊ូពុះពារ និងលះបង់អស់កម្លាំងកាយ កម្លាំងចិត្ត បញ្ញា ស្មារតី ដើម្បីបុព្វហេតុឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី សន្តិភាព សេរីភាព ប្រជាធិបតេយ្យ និងវឌ្ឍនភាពនៃកម្ពុជា ។

សូមគោរពជូនពរ **សម្ដេចអគ្គមហាធម្មពោធិសាល** ជាទីគោរពដ៏ខ្ពង់ខ្ពស់ សូមបានប្រកបនូវពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ ជារៀងដរាប ដើម្បីបន្តដឹកនាំមាតុភូមិកម្ពុជា និងគណបក្សប្រជាជនកម្ពុជា ឆ្ពោះទៅរកជោគជ័យធំៗថ្មីៗទៀត ក្នុងបុព្វហេតុកសាង និងការពារមាតុភូមិ ។

**ដោយក្ដីគោរព និងដឹងគុណដ៏ជ្រាលជ្រៅបំផុត**

**ទស្សនាវដ្ដីប្រជាជន**

វិចារណកថា
EDITORIAL

# កម្ពុជានឹងបន្តឈានទៅមុខ ដោយរក្សាបានល្បឿន នៃកំណើនសេដ្ឋកិច្ច និងចីរភាពនៃការអភិវឌ្ឍ

# Cambodia to Advance in Momentum of Economic Growth and Sustainable Development

*រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី ៥ នៃរដ្ឋសភា ដែលមានសម្តេចតេជោ **ហ៊ុន សែន** ជាប្រមុខ បានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ដើម្បីកំណើនការងារ សមធម៌និងប្រសិទ្ធភាពនៅកម្ពុជា។នោះគឺការបោះជំហានទៅមុខដ៏មុតមាំរបស់កម្ពុជាដើម្បីឈានទៅកាន់ដំណាក់កាលថ្មីនៃការអភិវឌ្ឍ ហើយក៏ជាការបន្តរៀបចំកសាងមូលដ្ឋានគ្រឹះសម្រាប់ការសម្រេចបាននូវចក្ខុវិស័យរយៈពេលវែងរបស់ខ្លួនពិសេសគឺមហិច្ឆតាក្នុងការប្រែក្លាយខ្លួន ទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០ ។ មានន័យថា កម្ពុជាកំពុងស្ថិតក្នុងស្ថានភាពបង្កើតឡើងនូវបុរេលក្ខខណ្ឌចាំបាច់ និងបរិស្ថានអនុគ្រោះសម្រាប់ដំណើរការផ្លាស់ប្តូរស៊ីជម្រៅរបស់កម្ពុជាឆ្ពោះទៅរកដំណាក់កាលអភិវឌ្ឍន៍ថ្មីកាន់តែខ្ពស់ថែមទៀត នៅក្នុងរយៈពេលវែងខាងមុខ ។*

*បច្ចុប្បន្ននេះ កម្ពុជាមានលក្ខខណ្ឌអនុគ្រោះយ៉ាងច្រើន។ ក្រៅពីការធានាបាននូវសុខសន្តិភាព ស្ថិរភាព កម្ពុជាដណ្តើមបានមកវិញនូវកាលានុវត្តភាពនៃការរីកចម្រើនខាងផ្នែកសង្គម និងសេដ្ឋកិច្ចយ៉ាងធំធេង។ កម្ពុជាដែលពីមុនជាប្រទេសអន់ថយខាងផ្នែកសេដ្ឋកិច្ច និងគ្របដណ្តប់ទៅដោយភាពក្រីក្រ ឥឡូវនេះបានក្លាយជាប្រទេសស្ថិតនៅក្នុងចំណាត់ថ្នាក់ទី ១៥ ដែលសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់លើពិភពលោកក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយ ជាប្រទេសស្ថិតក្នុងចំណាត់ថ្នាក់ទី ៥ ក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍ ដែលអាចសម្រេចបានគោលដៅអភិវឌ្ឍន៍សហស្សវត្សព្រមទាំងជាប្រទេសជាប់ចំណាត់ថ្នាក់ទី១ នៅតំបន់អាស៊ីប៉ាស៊ីហ្វិក ដែលសម្រេចបានវឌ្ឍនភាពដ៏ល្អប្រសើរក្នុងការកែលម្អសូចនាករ ផ្នែកសង្គមកិច្ច ហើយកំពុងតែធ្វើដំណើរយ៉ាងស្វាហាប់ឆ្លងកាត់ពីចំណាត់ថ្នាក់នៃប្រទេសមានចំណូលទាប ទៅជា ប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុងពេលអនាគតដ៏ខ្លី។*

*ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ សេដ្ឋកិច្ចកម្ពុជាមានសក្តានុពលរីកលូតលាស់ខ្ពស់ និងមានកាលានុវត្តន៍ភាពធ្វើពិពិធកម្មក្នុងវិស័យជាច្រើន។ ចំពោះមុខវិស័យកាត់ដេរ ទេសចរណ៍ សំណង់ និងវិស័យកសិកម្មគឺជាជន្ទល់នៃកំណើនរបស់កម្ពុជា ដែលប្រការនេះចង្អុលបង្ហាញពីភាពចាំបាច់ត្រូវបង្កើនការវិនិយោគក្នុងវិស័យផ្សេងៗទៀត ដើម្បីបង្កើតក្បាលម៉ាស៊ីននៃកំណើនថ្មីៗរបស់កម្ពុជា។ គួរកត់សម្គាល់ថា សេដ្ឋកិច្ចកម្ពុជាចាប់ពីឆ្នាំ ២០០៩ ដល់ឆ្នាំ ២០១៣ បានកើនឡើងជាមធ្យមប្រមាណជា ៦,៧% បើទោះបីជាមានការធ្លាក់ចុះនៅក្នុងឆ្នាំ២០០៩ ដោយសារតែវិបត្តិហិរញ្ញវត្ថុ និងការធ្លាក់ចុះនៃសេដ្ឋកិច្ចសកលលោកក៏ដោយ ។ នៅឆ្នាំ ២០០៩ សេដ្ឋកិច្ចកម្ពុជារក្សាបាននូវកំណើនវិជ្ជមានក្នុងកម្រិត ០,១% ខណៈប្រទេសមួយចំនួនធំមានកំណើនអវិជ្ជមាន ហើយកំណើនសេដ្ឋកិច្ចកម្ពុជាបានហក់ឡើងវិញភ្លាមដោយសម្រេចបាននូវអត្រាកំណើនជាមធ្យមប្រមាណ ៧% ពីឆ្នាំ២០១០ ដល់ ២០១៣ អាស្រ័យដោយភាពរឹងមាំនៃ*

The Royal Government of Cambodia of the fifth legislative term of the National Assembly led by Samdech Techo Hun Sen has put out the phase III of its Rectangular Strategy for Works, Equity and Efficiency in Cambodia. It is a strongly determined forward step of Cambodia toward a new stage of development and the preparation of foundation to realize its long term vision, especially the one to transform the country into a higher middle income nation by the year 2030 and high income by 2050. This means Cambodia is now in the stage of establishing necessary preconditions and environment that are favourable for Cambodia's deepening change toward a new and long-term development phase.

Presently, Cambodia enjoys numerous favourable conditions. Besides guaranteeing peace and stability, Cambodia has regained its great opportunity for socio-economic progress. Cambodia which before was an economically backward country and apparently covered with poverty has now ranked 15th among countries in the world that achieved high economic growth in the last ten years. It ranked the fifth among developing nations that achieved Millennium Development Goals and the first in the Asia-Pacific region that achieved better progress in improving the indicators of social affairs. Cambodia is now making a steadfast journey from low income to lower middle income country in the near future.

The last few years, the Cambodian economy made potentially high progress and endowed with opportunity for diversification in various fields. For the immediate moment, garments, tourism, construction and agriculture play roles of buttress to Cambodia's growth. This has indicated the necessity of increasing investment in other fields to create new engine of growth for the country. It is worth noting that the Cambodian economy grew, from 2009 through to 2013, at an average of 6.7%, though it contracted in 2009 for the world financial crisis and economic slowdown.

In 2009, the Cambodian economy maintained a 0.1% positive growth, while various major countries experienced negative ones. The Cambodian economic growth picked up soon after realizing the growth rate of about 7% from 2010 through to 2013, thanks to the strength of garments exports, tourism and construction, while the world economy was still in unstable condition and the country suffered from drought and issues arisen from the elections. The high growth of regional economies and the recovery of European and the US economies together with the Royal Government's ability to maintain peace, security, political stability and social order have brought about positive condition for the Cambodian economy to achieve a growth of about 7.6%.

In 2004 and the coming moderate term, the Cambodian economic growth has been predicted to be more than 7% based on progress made in the fields of energy and physical infrastructures, of raising high ability to compete, of improving trade facilitation and environment for investment, etc. As far as inflation is concerned, the estimate has been at lower level, roughly 3% to 4% in 2014, although inflation level in the region has gone high along with increase of prices of food and fuel. The foreign exchange of the Riel currency to the USD has been stable with little fluctuation. Bank deposits and loans have increased in 2013 reflecting public trust in the Cambodian banking system.

វិស័យនាំចេញវាយនភណ្ឌ ទេសចរណ៍ និងវិស័យសំណង់ បើទោះបីជាការងើបឡើងនូវសេដ្ឋកិច្ចពិភពលោកនូវមានកម្រិតខ្សោយ ហើយកម្ពុជាបានជួបប្រឈមនឹងគ្រោះទឹកជំនន់ និងបញ្ហាមួយចំនួនទៀតដែលកើតឡើងបន្ទាប់ពីការបោះឆ្នោតក៏ដោយ។ សន្ទុះកំណើនខ្ពស់នៃសេដ្ឋកិច្ចក្នុងតំបន់ និងការងើបឡើងវិញនៃសេដ្ឋកិច្ចសហរដ្ឋអាមេរិក និងតំបន់អឺរ៉ុប គួបផ្សំនឹងសមត្ថភាពរបស់រាជរដ្ឋាភិបាល ក្នុងការរក្សាបានកត្តាសុខសន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គម បានផ្តល់ផលជាវិជ្ជមានចំពោះសេដ្ឋកិច្ចកម្ពុជា ដែលក្នុងឆ្នាំ ២០១៣ កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចប្រមាណ ៧,៦%។ នៅឆ្នាំ ២០១៤ នេះ និងក្នុងរយៈពេលមធ្យមទៅមុខ កំណើនសេដ្ឋកិច្ចត្រូវបានព្យាករណ៍ថានឹងកើនលើសពី ៧% ដោយផ្អែកលើការរីកចម្រើនក្នុងវិស័យថាមពល និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដទៃទៀត ការលើកកម្ពស់សមត្ថភាពប្រកួតប្រជែង ការកែលម្អកិច្ចសម្រួលពាណិជ្ជកម្ម និងបរិយាកាសវិនិយោគជាដើម។ តាមការប៉ាន់ប្រមាណចំពោះអតិផរណាវិញ គឺស្ថិតនៅក្នុងកម្រិតទាបប្រមាណ ៣-៤% ក្នុងឆ្នាំ ២០១៤ នេះ ទោះបីអត្រាអតិផរណាក្នុងតំបន់មានកំណើនខ្ពស់ គួបផ្សំនឹងការកើនឡើងនៃថ្លៃម្ហូបអាហារ និងប្រេងឥន្ធនៈក៏ដោយ។ ចំណែកអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារវិញគឺមានស្ថិរភាពល្អ និងមានការផ្លាស់ប្តូរតិចតួចប៉ុណ្ណោះ។ ប្រាក់បញ្ញើ និងកម្ចីក្នុងធនាគារ បន្តកើនឡើងក្នុងឆ្នាំ ២០១៣ ដែលឆ្លុះបញ្ចាំងពីទំនុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធធនាគារកម្ពុជា។ ទុនបម្រុងអន្តរជាតិក្នុងឆ្នាំ ២០១៣ មានកំណើនប្រមាណ ៥២% ហើយត្រូវបានរំពឹងថានឹងកើនឡើងរហូតដល់ប្រមាណ ៤៥០០ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៤ នេះ ដែលមានចំនួនគ្រប់គ្រាន់សម្រាប់ចំណាយលើការនាំចូលប្រមាណ ៤ ខែកន្លះ។ ចំពោះវិនិយោគផ្ទាល់ពីបរទេសវិញនៅមានសកម្មភាពខ្លាំងក្លាដដែល ជាពិសេសដោយសារការផ្លាស់ទីតាំងរោងចក្រផលិតកម្មពីប្រទេសជិតខាងក្នុងតំបន់ និងកំណើនវិនិយោគផ្ទាល់ពីបរទេស។ កំណើននៃការវិនិយោគក្នុងឆ្នាំ ២០១៤ បានបង្ហាញឲ្យឃើញពីចំណាប់អារម្មណ៍កាន់តែច្រើនលើសក្តានុពលនិងកាលានុវត្តភាពវិនិយោគនៅកម្ពុជា ជាពិសេសការជឿជាក់លើសមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការដឹកនាំ និងគ្រប់គ្រងប្រទេស។

ក្នុងរយៈពេលមួយឆ្នាំកន្លងទៅនេះ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តដោយជោគជ័យនូវផែនការសកម្មភាពនៃកម្មវិធីនយោបាយរបស់ខ្លួន បើទោះបីត្រូវប្រឈមមុខជាមួយនឹងកម្លាំងប្រតិកិរិយា និងមជ្ឈដ្ឋានអគតិមួយចំនួនដែលប៉ុនប៉ងផ្តួលរំលំរាជរដ្ឋាភិបាលថ្មីស្របច្បាប់ ដែលកើតចេញពីការបោះឆ្នោត តាមរយៈការធ្វើបាតុកម្ម កូដកម្ម និងកុបកម្មប្រកបដោយភាពហិង្សាយ៉ាងណាក៏ដោយ ។ រាជរដ្ឋាភិបាលបានអនុវត្តប្រកបដោយប្រសិទ្ធភាព ដោយធ្វើឲ្យគ្រប់ស្ថាប័នរដ្ឋនៅគ្រប់ថ្នាក់ ធានាបាននិរន្តរភាព រក្សាបានស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងប្រក្រតីភាពនៃជីវភាពរបស់ប្រជាជន។ គ្រប់វិស័យសុទ្ធតែមានការរីកចម្រើន ដែលទាំងអស់នេះ ឆ្លុះបញ្ចាំងពីសមត្ថភាពដឹកនាំប្រកបដោយភាពឈ្លាសវៃរបស់សម្តេចតេជោ **ហ៊ុន សែន** ។ ក្នុងឆ្នាំ ២០១៤ នេះ និងឆ្នាំបន្តទៅ មុខទៀត រាជរដ្ឋាភិបាលកម្ពុជាមានសុទិដ្ឋិនិយមដ៏មុតមាំក្នុងការដឹកនាំប្រទេសជាតិឲ្យកាន់តែមានការអភិវឌ្ឍឡើង ពីព្រោះយើងមានកត្តាអនុគ្រោះកាន់តែច្រើន ក្នុងនោះរួមមានទាំងបញ្ហានយោបាយផងដែលត្រូវបានដោះស្រាយរួចរាល់ បង្កលក្ខណៈឲ្យយើងប្រមូលផ្តុំបាននូវកម្លាំងសាមគ្គីជាតិដើម្បីកសាងប្រទេស ។ បញ្ហាចម្បងរបស់យើងដែលត្រូវយកចិត្តទុកដាក់ដោះស្រាយឲ្យបានល្អ គឺការខិតខំធ្វើឲ្យកម្ពុជាបោះជំហានទៅមុខ តាមរយៈការបន្តជំរុញអនុវត្តកំណែទម្រង់ដ៏ទូលំទូលាយ និងស៊ីជម្រៅលើវិស័យទាំងឡាយប្រកបដោយប្រសិទ្ធភាពខ្ពស់ពិតប្រាកដ ។ថ្មីៗនេះ សម្តេចតេជោ **ហ៊ុន សែន** បានថ្លែងថា កម្ពុជាត្រូវការកែទម្រង់ជាចាំបាច់ ដើម្បីដើរឲ្យទាន់នូវតម្រូវការនៃការអភិវឌ្ឍប្រទេស និងភាពប្រកួតប្រជែង នៅក្នុងតំបន់ និងអន្តរជាតិ ។ កម្ពុជាមិនអាចស្កប់ស្កល់បានទេ ។ គោលដៅនៃការកែទម្រង់របស់យើង គឺដើម្បីរក្សាឲ្យបាននូវល្បឿននៃកំណើនសេដ្ឋកិច្ច ក៏ដូចជាចីរភាពនៃការអភិវឌ្ឍ។

កម្ពុជាប្រាកដជាអាចបញ្ចប់ឆ្នាំ ២០១៤ នេះ ប្រកបដោយមោទនភាព ហើយនឹងឈានចូលឆ្នាំ ២០១៥ ជាមួយនឹងសេចក្តីសង្ឃឹមពិត ៕

**ទស្សនាវដ្តីប្រជាជន**

Cambodia’s international reserves in 2013 grew about 52% and expected to get to 4.5 billion USD in 2014, sufficient to cover four and a half month of imports. As for foreign direct investment, the country notes continued strong action owing especially to relocations of production lines of factories in neighboring countries and growth in foreign direct investment. Investment growth in 2014 showed clear impression on investment potential and opportunity in Cambodia, especially confidence in the leadership and management capacity of the Royal Government of Cambodia.

Over the past one year, the Royal Government of Cambodia successfully implemented the plan of action of its political platform though the country has had to face with reactionary forces and ill-willed circles who aim to bring the newly and legally elected Royal Government down by means of violent demonstration and strikes. The Royal Government implements effectively its political platform, in which, state institutions of all levels sustain their functions leading to the guaranteeing of political stability, security, social order and regularity of the people’s livelihood.

The progress made in all fields has illustrated the leadership capacity and wisdom of Samdech Techo Hun Sen. In 2014 and the coming years, the Royal Government of Cambodia is optimistic in leading the country to more development thanks to the numerous favorable conditions that we have secured, resolving political problems included. They should allow us to harness national solidarity forces for national construction. The major problem for us to pay attention to is making Cambodia step forward through continued wide-ranging and deepening reforms in all fields with high effectiveness.

Recently, Samdech Techo Hun Sen made a statement that Cambodia needs reform to keep pace with developed nations and to ensure its competitive ability in the region and the world. Cambodia cannot afford to be satisfied at just what it achieved. Goals of our reforms are to guarantee rapid economic growth and sustainable development. Cambodia will certainly end the year 2014 in pride and start the coming year 2015 with real hope./.

***THE PRACHEACHUN MAGAZINE***

# ការដកហូតដីសម្បទានសេដ្ឋកិច្ចដែលមិនបានធ្វើការអភិវឌ្ឍ បានទទួលការគាំទ្រពីគ្រប់មជ្ឈដ្ឋាន

គោលដៅយុទ្ធសាស្ត្រមួយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៥ បានផ្តោតលើការគ្រប់គ្រង ការការពារ និងការប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិប្រកបដោយតម្លាភាព និងប្រសិទ្ធភាព ដើម្បីរក្សាចីរភាពបរិស្ថាន និងការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ទប់ស្កាត់ការកាប់ទន្ទ្រានដីព្រៃ ការរំលោភកាន់កាប់ដីគ្រប់ប្រភេទដោយខុសច្បាប់ ការប្រមូលដីទុកមិនផលិត ការបន្តដកហូតមកវិញនូវសម្បទានដីសេដ្ឋកិច្ចដែលក្រុមហ៊ុនមិនគោរពតាមកិច្ចសន្យា និងបទដ្ឋានគតិយុត្តជាធរមាន និងបញ្ឈប់ការផ្តល់ថែមទៀតនូវសម្បទានដីសេដ្ឋកិច្ច។ ដីសម្បទានសេដ្ឋកិច្ចដែលត្រូវបានដកហូតមកវិញត្រូវយកទៅបម្រើប្រយោជន៍នៃការថែរក្សាបរិស្ថាន និងការអភិវឌ្ឍប្រកបដោយតម្លាភាព និងសមធម៌ តាមរយៈការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច និងការធ្វើប្រទានកម្ម។

ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ដីសម្បទានសេដ្ឋកិច្ចត្រូវបានប្រគល់ទៅឲ្យក្រុមហ៊ុនជាច្រើនធ្វើការអភិវឌ្ឍ ដូចជាការដាំដំណាំកសិឧស្សាហកម្ម ការធ្វើជាតំបន់ទេសចរណ៍ តំបន់សេដ្ឋកិច្ចជាដើម។ ក្រុមហ៊ុនខ្លះបានបំពេញកាតព្វកិច្ចរបស់ខ្លួនជាមួយរដ្ឋប្រកបដោយការទទួលខុសត្រូវ ប៉ុន្តែក្រុមហ៊ុនខ្លះទៀតមិនអនុវត្តតាមកិច្ចសន្យាទេ ដោយយកដីទៅទុកចោលមិនផលិត។ ករណីខ្លះទៀតបង្កការប៉ះពាល់ធ្ងន់ធ្ងរដល់ប្រជាជន ដូចជា មានកន្លែងខ្លះរាតចូលដល់ភូមិរបស់ប្រជាជន ផ្ទះសម្បែង ដីស្រែ ច្បារដំណាំរបស់ប្រជាជនដែលធ្វើឲ្យប្រជាជនថ្នាំងថ្នាក់ជាខ្លាំង។ករណីជាច្រើនត្រូវបានរាជរដ្ឋាភិបាលធ្វើការដោះស្រាយយ៉ាងទាន់ពេលវេលា ដោយកន្លែងខ្លះត្រូវកាត់ខ្វៀលដីពីក្រុមហ៊ុនជូនទៅប្រជាជនវិញ។ ករណីខ្លះទៀតត្រូវរកដីថ្មីមកសងជូនប្រជាជន ក្នុងករណីដែលក្រុមហ៊ុនខ្លះបានធ្វើការដាំដុះ ឬធ្វើការអភិវឌ្ឍនៅលើដីសម្បទានសេដ្ឋកិច្ចដែលខ្លួនទទួលបាននោះរួចហើយ។

ប៉ុន្តែអ្វីដែលជាការកត់សម្គាល់នោះ គឺក្រុមហ៊ុនខ្លះដែលយកដីសម្បទានទៅទុកចោល ធ្វើឲ្យរដ្ឋទទួលការខាតបង់កំពុងត្រូវបានរដ្ឋាភិបាលដកហូតជាបន្តបន្ទាប់មកជាសម្បត្តិរដ្ឋវិញ ។ ជាក់ស្តែង យោងតាមរបាយការណ៍ ស្តីពីលទ្ធផលនៃកិច្ចប្រជុំរបស់គណៈកម្មការអន្តរក្រសួងដើម្បីពិនិត្យវាស់វែងនិងវាយតម្លៃសម្បទានដីសេដ្ឋកិច្ចចុះថ្ងៃទី ១៤ ខែតុលា ឆ្នាំ ២០១៤ និងយោងតាមចំណាររបស់សម្តេចតេជោ **ហ៊ុន សែន** ចុះថ្ងៃទី ១៤ ខែតុលា ឆ្នាំ ២០១៤ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចដកហូតមកវិញនូវដីសម្បទានសេដ្ឋកិច្ចជាច្រើនម៉ឺនហិកតាដែលមាននៅក្នុងខេត្តមណ្ឌលគីរីចំនួន ៣ ខេត្តកំពង់ស្ពឺខេត្តព្រះសីហនុខេត្តកោះកុងចំនួន៣ខេត្តបន្ទាយមានជ័យចំនួន ១ ខេត្តព្រះវិហារ និងខេត្តកំពង់ធំចំនួន ១ ខេត្តឧត្តរមានជ័យចំនួន ១ ខេត្តបាត់ដំបងចំនួន ១ និងខេត្តក្រចេះចំនួន ១។ម៉្យាងទៀតគួររំឭកថា កាលពីខែកញ្ញា ឆ្នាំ ២០១៤រាជរដ្ឋាភិបាលកម្ពុជាក៏បានសម្រេចដកហូតដីសម្បទានសេដ្ឋកិច្ចប្រមាណជាង ១ ម៉ឺនហិកតាពីក្រុមហ៊ុនចំនួន ៨ យកមករក្សាទុកជាសម្បត្តិរដ្ឋ បន្ទាប់ពីរកឃើញថា ដីសម្បទានសេដ្ឋកិច្ចទាំងអស់នោះមានផលប៉ះពាល់ដល់ធនធានធម្មជាតិ។

ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថានបានប្រាប់អ្នកកាសែតកាលពីថ្ងៃទី ១៧ ខែតុលា ឆ្នាំ ២០១៤ ថា ដីសម្បទានសេដ្ឋកិច្ចដែលត្រូវបានរាជរដ្ឋាភិបាលធ្វើការដកហូតនេះ ដោយសារដីទាំងនេះ ក្រុមហ៊ុនសុំគោលការណ៍វិនិយោគយូរហើយប្រមាណ ១១ឆ្នាំតែពុំមានការអភិវឌ្ឍអ្វីទាល់តែសោះ។ការដកហូតនេះ គឺស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន។ឯកឧត្តម **សាយសំអាល់**បានបញ្ជាក់ដែរថារយៈពេលនៃការស្នើសុំសម្រាប់ដីសម្បទានសេដ្ឋកិច្ច ៩៩ ឆ្នាំ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាសម្រេចលុបចោលហើយ។ ចំពោះក្រុមហ៊ុនដែលទទួលបានសិទ្ធិរួចហើយ គឺនៅបន្តដដែល។ ប៉ុន្តែសម្រាប់ក្រុមហ៊ុនថ្មីរាជរដ្ឋាភិបាលនឹងផ្តល់សិទ្ធិត្រឹម ៥០ ឆ្នាំប៉ុណ្ណោះ ប៉ុន្តែគេមានសិទ្ធិសុំបន្តនៅពេលដែលរយៈពេលនៃការធ្វើវិនិយោគបានដល់គម្រប់ ៤០ ដល់ ៤៥ ឆ្នាំឡើងទៅ។

ការដកហូតយកមកវិញនូវដីសម្បទានសេដ្ឋកិច្ចទាំងនេះ គឺជាគំរូដ៏ល្អមួយសម្រាប់ក្រុមហ៊ុនដទៃទៀត ដែលទទួលបានសិទ្ធិធ្វើការវិនិយោគ ប៉ុន្តែបែរជាគ្រាន់តែមកទាញយកផលប្រយោជន៍ពីដីទាំងនោះ ហើយបោះបង់ចោលគម្រោងនៃការអភិវឌ្ឍ។ ប្រជាជនគ្រប់មជ្ឈដ្ឋាន អង្គការ សង្គមស៊ីវិល ដៃគូសហប្រតិបត្តិការអន្តរជាតិនានាបានសម្តែងការសាទរ ចំពោះការប្តេជ្ញាចិត្តរបស់ក្រសួងបរិស្ថានក្នុងការងារនេះ ដែលផ្តល់ផលវិជ្ជមានក្រៃលែងដល់ការដោះស្រាយបញ្ហាបរិស្ថានសង្គម និងសេដ្ឋកិច្ចរបស់ប្រជាជន។

ភាពម៉ឺងម៉ាត់របស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងបរិស្ថានជាសេនាធិការដ៏ស្មោះត្រង់ វៀងវៃក្នុងការពុះពារលុបបំបាត់ល្បិចកលដ៏អាក្រក់របស់ម្ចាស់ក្រុមហ៊ុនមួយចំនួន ដែលឆ្លៀតកេងប្រវ័ញ្ចផលប្រយោជន៍របស់រដ្ឋ និងប្រជាជន តាមរយៈដីសម្បទានសេដ្ឋកិច្ចដូចខាងលើនេះ បានបង្ហាញច្បាស់នូវជំហរដាច់ខាតរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តកំណែទម្រង់ការគ្រប់គ្រងដីធ្លី និងការគ្រប់គ្រងប្រើប្រាស់ធនធានធម្មជាតិ និងបរិស្ថានប្រកបដោយចីរភាពយ៉ាងច្បាស់លាស់ពិតប្រាកដ៕

# សម្តេចប្រធានព្រឹទ្ធសភា ទទួលជួបសវនាការ ជាមួយឯកអគ្គរដ្ឋទូតថ្មីនៃប្រទេសវៀតណាម ប្រចាំកម្ពុជា



*សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ទទួលជួបសវនាការជាមួយឯកឧត្តម **ថាច់ហ៊្សា** ឯកអគ្គរដ្ឋទូតថ្មីនៃប្រទេសវៀតណាមប្រចាំកម្ពុជា*

ឯកឧត្តម **ថាច់ហ៊្សា** ឯកអគ្គរដ្ឋទូតថ្មីនៃប្រទេសវៀតណាមប្រចាំកម្ពុជា បានអញ្ជើញចូលជួបសម្តែងការគួរសម និងសួរសុខទុក្ខ សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៅភូមិគ្រឹះរបស់សម្តេច កាលពីព្រឹកថ្ងៃទី១៣ ខែតុលា ឆ្នាំ ២០១៤ ។

ក្នុងកិច្ចសន្ទនា ឯកឧត្តមឯកអគ្គរដ្ឋទូតបានជម្រាបជូនសម្តេចធម្មពោធិសាលថា ឯកឧត្តមនឹងប្តេជ្ញាខិតខំបំពេញការងារការទូតដើម្បីពង្រឹងពង្រីកទំនាក់ទំនង កិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ វៀតណាម-កម្ពុជា ឲ្យបានល្អ ដើម្បីឧត្តមប្រយោជន៍នៃប្រទេសទាំងពីរ ។

ឯកឧត្តម **ថាច់ ហ៊្សា** បានសំណូមពរសម្តេច និងស្ថាប័នព្រឹទ្ធសភាជួយគាំទ្រដល់បេសកកម្មការទូត របស់ឯកឧត្តមនៅកម្ពុជា ហើយរំពឹងថានឹងបានទទួលការគាំទ្រ និងកិច្ចសហប្រតិបត្តិការបង្គួលក្ខណៈល្អ ពីគ្រប់ស្ថាប័នរបស់កម្ពុជា ដើម្បីឲ្យបេសកកម្មការទូត របស់ឯកឧត្តមនៅកម្ពុជាទទួលបានជោគជ័យ។ ឯកអគ្គ-រដ្ឋទូតថ្មី ប្រទេសវៀតណាមបានជូនពរឲ្យសម្តេចធម្មពោធិសាល មានសុខភាពល្អ ដើម្បីបន្តដឹកនាំស្ថាប័នព្រឹទ្ធសភា សម្រេចបានជោគជ័យថ្មីៗបន្តទៀត។

សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា បានសម្តែងក្តីសោមនស្សរីករាយក្រៃលែង ចំពោះកិច្ចសវនាការនេះ ក្នុងឱកាសដែលឯកឧត្តមអគ្គរដ្ឋទូតចាប់ផ្តើមបេសកកម្មការទូតនៅកម្ពុជា ។ សម្តេចបានសម្តែងក្តីសង្ឃឹមថាតាមរយៈបេសកកម្មការទូតនេះនឹងជំរុញឲ្យទំនាក់ទំនងមិត្តភាពជាប្រពៃណី និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យរវាងប្រទេសទាំងពីរ កម្ពុជា-វៀតណាមកាន់តែរីកចម្រើន និងរឹងមាំឡើងដើម្បីជាគុណប្រយោជន៍របស់ប្រជាជននៃប្រទេសទាំងពីរ។

តាមរយៈប្រមុខការទូតថ្មីរបស់ប្រទេសវៀតណាមប្រចាំកម្ពុជា សម្តេចធម្មពោធិសាលក៏បានផ្តាំផ្ញើសួរសុខទុក្ខ និងជូនពរដល់ថ្នាក់ដឹកនាំ និងប្រជាជនប្រទេសវៀតណាម បានសម្រេចជោគជ័យធំៗថ្មីទៀតក្នុងការកសាងប្រទេស៕





សូមគោរពឯកឧត្តម លោកជំទាវ និងប្រិយមិត្តអ្នកអានជាទីគោរព
សូមចូលមក Facebook Page : Pracheachun Magazine-ទស្សនាវដ្តីប្រជាជន
ហើយចុច Like និង Share ដើម្បីទទួលបានព័ត៌មានសំខាន់ៗប្រចាំថ្ងៃ ព្រមទាំងផ្តល់ទស្សនៈ ឬ មតិផ្សេងៗ

# កិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប លើកទី ១០ ក្រោមប្រធានបទ ភាពជាដៃគូទទួលខុសត្រូវសម្រាប់កំណើនដោយចីរភាព និងសន្តិសុខ





*កិច្ចប្រជុំអាស៊ី-អឺរ៉ុប (ASEM) លើកទី ១០ បានប្រព្រឹត្តទៅដោយមានប្រមុខរដ្ឋ និងរដ្ឋាភិបាលចំនួន ៥១ ប្រទេសមកពីប្រទេសអាស៊ី និងអឺរ៉ុប នៅទីក្រុងមីឡង់ ប្រទេសអ៊ីតាលី*

ចាប់ពីថ្ងៃទី១៦ ដល់ទី១៧ ខែតុលា ឆ្នាំ ២០១៤ នៅទីក្រុងមីឡង់នៃប្រទេសអ៊ីតាលីកិច្ចប្រជុំអាស៊ី-អឺរ៉ុប (ASEM) លើកទី ១០ បានប្រព្រឹត្តទៅដោយមានប្រមុខរដ្ឋ និងរដ្ឋាភិបាលចំនួន ៥១ ប្រទេសមកពីប្រទេសអាស៊ី និងអឺរ៉ុប ប្រធានក្រុមប្រឹក្សាអឺរ៉ុប ប្រធានគណៈកម្មការអឺរ៉ុប និងអគ្គលេខាធិការអាស៊ានបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំនេះ។ មាន ឯកឧត្តម **ម៉ាតេអូ រ៉េនហ្ស៊ី** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋអ៊ីតាលី ជាអ្នករៀបចំកិច្ចប្រជុំ ឯកឧត្តម **អ៊ែរមែន វ៉ាន់រំពុយ** ប្រធានក្រុមប្រឹក្សាអឺរ៉ុបជាប្រធាននៃកិច្ចប្រជុំ។ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាក៏បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំនេះដែរ។ កិច្ចប្រជុំបានប្រព្រឹត្តទៅក្រោមប្រធានបទ ភាពជាដៃគូទទួលខុសត្រូវសម្រាប់កំណើនដោយចីរភាព និងសន្តិសុខ។

ថ្នាក់ដឹកនាំអឺរ៉ុប-អាស៊ី បានផ្លាស់ប្តូរទស្សនៈអំពីបញ្ហាសេដ្ឋកិច្ចហិរញ្ញវត្ថុតំបន់ និងសកល ក៏ដូចជាបញ្ហាប្រឈមអំពីសន្តិសុខជាប្រពៃណី និងសន្តិសុខសម័យថ្មី ក្នុងស្មារតីនៃភាពជាដៃគូរវាងអាស៊ី និងអឺរ៉ុប ដោយផ្តោតជាសំខាន់អំពីវិធានការទៅថ្ងៃមុខ ដើម្បីបង្កើតបរិយាកាសសមស្របមួយសម្រាប់វិបុលភាពរបស់ប្រជាជន តាមរយៈការលើកកម្ពស់ការតភ្ជាប់គ្នារវាងអាស៊ីនិងអឺរ៉ុប។ ថ្នាក់ដឹកនាំបានបញ្ជាក់សាជាថ្មីអំពីសារៈសំខាន់នៃការបន្តការកែទម្រង់សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធានាកំណើនសេដ្ឋកិច្ចពិភពលោកមួយដែលរឹងមាំប្រកបដោយចីរភាព និងតុល្យភាពសំដៅសម្រេចឲ្យបាននូវការបង្កើនកម្រិតបង្កើតការងារដ៏សមស្របមួយ ។ ក្នុងពេលស្ថានភាពសេដ្ឋកិច្ចពិភពលោក កំពុងតែត្រូវបានពង្រឹងជាបណ្តើរៗ ទោះបីមិនទាន់មានលក្ខណៈរលូនក្តី ប៉ុន្តែសេដ្ឋកិច្ចអាស៊ីបានបង្ហាញនូវភាពរស់រវើកហើយនៅតែជាកម្លាំងចលករមួយដ៏រឹងមាំសម្រាប់ជំរុញសេដ្ឋកិច្ចពិភពលោក។ នៅអឺរ៉ុបមានការរីកចម្រើនក្នុងការអនុវត្តគោលនយោបាយសេដ្ឋកិច្ច និងការកែទម្រង់រចនាសម្ព័ន្ធដែលចាំបាច់ដើម្បីធានាកំណើនសេដ្ឋកិច្ចឲ្យកាន់តែរឹងមាំក្នុងរយៈពេលមធ្យម។ អង្គប្រជុំបានកត់សម្គាល់ឃើញថា ហានិភ័យសេដ្ឋកិច្ចនៅតែមាន ហើយបានបន្តការប្តេជ្ញាលើការជំរុញកំណើនសេដ្ឋកិច្ចមួយដែលមានភាពរឹងមាំ ប្រកបដោយចីរភាព តុល្យភាព និងមានការចូលរួមពីគ្រប់មជ្ឈដ្ឋាន ដូចជាក្នុងបរិបទចីរភាពនៃវិស័យសារពើពន្ធ ទាំងក្នុងប្រទេស និងអន្តរជាតិ ព្រមទាំងសហការគ្នាយ៉ាងសកម្ម ដើម្បីបង្រួញគម្លាតអភិវឌ្ឍន៍ និងដើម្បីដោះស្រាយបញ្ហាប្រឈមផ្នែកសេដ្ឋកិច្ច និងសង្គម។ ទាក់ទងការបង្កើនការតភ្ជាប់អាស៊ី-អឺរ៉ុប អង្គប្រជុំបានកត់សម្គាល់ថា ការតភ្ជាប់ប្រព័ន្ធឌីជីថលដែលមានល្បឿនលឿនមានសមត្ថភាពខ្ពស់គ្មានខ្សែតភ្ជាប់និងអ៊ីនធើណេតគឺជាធាតុគន្លឹះនៃហេដ្ឋារចនាសម្ព័ន្ធរបស់សង្គមសម័យទំនើប ហើយក៏បានសម្តែងការចាប់អារម្មណ៍ ដើម្បីពិនិត្យមើលលើមធ្យោបាយជំរុញការតភ្ជាប់ប្រព័ន្ធឌីជីថលរវាងអឺរ៉ុបនឹងអាស៊ី។ អង្គប្រជុំបានធ្វើការប្តេជ្ញាចិត្តសាជាថ្មី ក្នុងការខិតខំបើកចំហសេដ្ឋកិច្ចពិភពលោក និងពង្រឹងទំនាក់ទំនងពាណិជ្ជកម្ម និងវិនិយោគ សម្រាប់តភ្ជាប់សេដ្ឋកិច្ចឲ្យបានខ្លាំងក្លារវាងតំបន់ទាំងពីរ ។ ដើម្បីឲ្យមានកំណើនប្រកបដោយចីរភាព និងការបង្កើតការងារឲ្យបានសមរម្យ គឺចាំបាច់ត្រូវតែទាញយកផលប្រយោជន៍ពីសក្តានុពលនៃពាណិជ្ជកម្ម និងវិនិយោគបរទេសដែលក្នុងនោះ គឺទាមទារឲ្យមានការបើកប្រព័ន្ធពាណិជ្ជកម្មពហុភាគីចំហ មានស្ថិរភាព និងមានមូលដ្ឋានច្បាប់ដែលអាចព្យាករណ៍បាន។ អង្គប្រជុំបានយល់ស្របគ្នាលើបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរដែលបានកើតឡើងដោយសារការប្រែប្រួលអាកាសធាតុ ដោយបានឯកភាពគ្នាត្រូវចាត់វិធានការបន្ទាន់បន្ថែមជាចាំបាច់ពីគ្រប់ភាគីទាំងអស់ ក្នុងគោលបំណងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ជាសកល ដើម្បីសម្រេចគោលដៅរួមក្នុងការដាក់កំហិតការកើនឡើងសីតុណ្ហភាពមធ្យមជាសកល ក្រោម ០២ អង្សាសេ លើកម្រិតមុនសម័យឧស្សាហកម្ម។

អង្គប្រជុំបានបញ្ជាក់សាជាថ្មីពីការប្តេជ្ញាចិត្តជំរុញ និងការពារសិទ្ធិមនុស្ស ដោយផ្អែកលើធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស និងសន្ធិសញ្ញាអន្តរជាតិសិទ្ធិមនុស្ស ដោយបញ្ជាក់ពីឆន្ទៈរបស់ខ្លួន ដើម្បីជំរុញកិច្ចសហប្រតិបត្តិការនៅក្នុងរង្វង់ ASEM លើវិស័យសិទ្ធិមនុស្ស តាមរយៈការចែករំលែកបទពិសោធន៍ និងការអនុវត្តឲ្យបានល្អ។ ថ្កោលទោសរាល់ទម្រង់នៃការញុះញង់ឲ្យស្អប់ និងមិនមានភាពអត់ឱនរួមមានការស្អប់ជនបរទេស ការស្អប់ខ្ពើមសាសនា និងអំពើហិង្សា។ អង្គប្រជុំបានសង្កត់ធ្ងន់ពីសារៈសំខាន់នៃការគោរព និងការយោគយល់គ្នានៃវប្បធម៌ និងសាសនាចម្រុះ លើកកម្ពស់ការអត់ធ្មត់ ការគោរព ការសន្ទនា និងសហប្រតិបត្តិការក្នុងចំណោមវប្បធម៌ អរិយធម៌ និងប្រជាជនផ្សេងៗគ្នា។ ទទួលស្គាល់កិច្ចផ្តួចផ្តើមទាំងឡាយដែលជំរុញភាពកណ្តាល ជាពិសេសដូចមានចែងនៅក្នុងចលនាពិភពលោកនៃអ្នកកណ្តាល Global Movement of Moderates ដើម្បីប្រយុទ្ធប្រឆាំងទល់នឹងគ្រប់រូបភាពនៃក្រុមជ្រុលនិយម គាំទ្រដល់កិច្ចខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍបើកចំហ និងកិច្ចសន្ទនាស្តីពីអន្តរវប្បធម៌ និងសាសនាដោយមានការចូលរួមពីគ្រប់មជ្ឈដ្ឋាន គ្រប់ទម្រង់នានាក្នុងក្របខណ្ឌអាស៊ាន។

អង្គប្រជុំបានយល់ស្របពីសក្តានុពល ដែលមាននៅក្នុងក្របខណ្ឌ ASEM សម្រាប់កិច្ចសហការលើវិស័យសុខាភិបាល ជាពិសេសកុមារ ស្ត្រី និងមនុស្សចាស់។ ជំរុញឲ្យមានកិច្ចសហប្រតិបត្តិការកាន់តែប្រសើរឡើងក្នុងក្របខណ្ឌ ASEM ក្នុងការលើកកម្ពស់ចំណីអាហារ ទឹក និងសន្តិសុខថាមពល។ ដោះស្រាយរាល់បញ្ហាប្រឈម តាមរយៈការខិតខំប្រឹងប្រែងរួម



*សម្តេចតេជោ **ហ៊ុន សែន** ទទួលជួបពិភាក្សាការងារជាមួយ ឯកឧត្តម **ប្រាយុទ្ធ ចាន់អូចា***

គ្នា និងកិច្ចសហប្រតិបត្តិការឆ្លងដែន ក្នុងទស្សនទានជំរុញការគ្រប់គ្រងទឹកដោយចីរភាព រាប់បញ្ចូលការគ្រប់គ្រងអាងទន្លេរួម និងការគ្រប់គ្រងហានិភ័យដោយទឹកជំនន់ និងធានាការទទួលបាននូវទឹកស្អាតសម្រាប់បរិភោគដោយសុវត្ថិភាព និងមានអនាម័យ។

អង្គប្រជុំបានប្តេជ្ញាចិត្ត ក្នុងការពង្រឹងគោលនយោបាយកម្មវិធី និងសហប្រតិបត្តិការ ដើម្បីសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងក្នុងការធានាកម្លាំងពលកម្ម និងជំនាញ លើកកម្ពស់លទ្ធផលការងារនៃកម្មវិធីទីផ្សារការងារសកម្ម ការបណ្តុះបណ្តាល ការពង្រឹងសុខភាព និងសុវត្ថិភាពនៅកន្លែងធ្វើការ និងគោលការណ៍ជាមូលដ្ឋាននៃការគោរពសិទ្ធិនៅកន្លែងការងារទាក់ទងនឹងឧស្សាហកម្ម និងជំរុញការការពារសុវត្ថិភាពសង្គមកិច្ច។

អង្គប្រជុំបានប្តេជ្ញាចិត្តពង្រឹងកិច្ចសហប្រតិបត្តិការសង្គមវប្បធម៌ និងជំរុញឲ្យមានអន្តរកម្មរវាងប្រជាជន និងប្រជាជនឲ្យកាន់តែប្រសើរឡើងតាមរយៈការបង្កើនការផ្លាស់ប្តូរវប្បធម៌ ការអប់រំ បញ្ញវន្ត យុវជន កីឡា និងការផ្លាស់ប្តូរអាហារូបករណ៍។ ពង្រីកឲ្យកាន់តែស៊ីជម្រៅវិស័យទេសចរណ៍រវាងអាស៊ី-អឺរ៉ុប ដែលជាកម្លាំងសម្រាប់កំណើនសេដ្ឋកិច្ច និងការបង្កើតការងារសមរម្យ ហើយក៏ជាឧបករណ៍ដ៏សំខាន់សម្រាប់បង្កើនទំនាក់ទំនងរវាងប្រជាជន និងប្រជាជន។

អង្គប្រជុំបានទទួលស្គាល់ពីសារៈសំខាន់ នៃការដោះស្រាយការគំរាមផ្នែកសន្តិសុខ រួមមានការប្រើអំពើហិង្សានៅក្នុងរដ្ឋ និងឆ្លងដែន អន្តោប្រវេសន៍ខុសច្បាប់ និងការធ្វើបម្លាស់ទីមិនប្រក្រតីរបស់ប្រជាជន អំពើហិង្សាជ្រុលនិយម ការជួញដូរខុសច្បាប់អាវុធ និងគ្រឿងញៀន ការលាងលុយកខ្វក់ ចោរសមុទ្រនិងអំពើប្លន់តាមសមុទ្រ ការរីកសាយអាវុធនុយក្លេអ៊ែរ អាវុធប្រល័យលោក និងប្រព័ន្ធផ្គត់ផ្គង់អាវុធទាំងនោះ។ ការរីករាលដាលវីរុសអេបូឡា គឺជាការគំរាមកំហែងដ៏ខ្លាំងក្លាទៅលើសន្តិសុខ និងសុខាភិបាលសកលលោក។ អង្គប្រជុំបានទទួលស្គាល់នូវការប្រឹងប្រែងរបស់ប្រទេសដៃគូ ASEM ក្នុងការផ្តល់ជំនួយទៅដល់តំបន់រាតត្បាត។

អង្គប្រជុំបានស្វាគមន៍កិច្ចខិតខំប្រឹងប្រែងរបស់អាស៊ាន ចំពោះការធ្វើសមាហរណកម្មតំបន់ និងទន្ទឹងមើលចំពោះការចាប់ផ្តើមសហគមន៍អាស៊ាននៅឆ្នាំ ២០១៥ ។ គាំទ្រចំពោះចក្ខុវិស័យក្រោយឆ្នាំ ២០១៥ របស់សហគមន៍អាស៊ាន និងភាពជាស្នូលរបស់អាស៊ាន នៅក្នុងទំនាក់ទំនងនិម្មាបនកម្មតំបន់នៅអាស៊ី និងវាយតម្លៃតួនាទីអាស៊ានក្នុងការជំរុញកិច្ចសន្ទនា ការកសាងទំនុកចិត្ត និងកិច្ចសហប្រតិបត្តិការដើម្បីសន្តិភាព សន្តិសុខស្ថិរភាពនិងវិបុលភាពនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកនិងតំបន់ផ្សេងដទៃទៀត។

តាមប្រសាសន៍របស់ឯកឧត្តម **កៅ គឹមហួន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីបានថ្លែងថា នៅក្នុងកិច្ចប្រជុំនេះ សម្តេចតេជោ **ហ៊ុន សែន** ក៏បានមានប្រសាសន៍ ដោយផ្តោតទៅលើការជំរុញការតភ្ជាប់រវាងអាស៊ីអឺរ៉ុប ជាពិសេសការជំរុញផ្នែកពាណិជ្ជកម្ម វិនិយោគ និងទេសចរណ៍។ ធ្វើយ៉ាងណាពង្រឹងបន្ថែមទៀតការតភ្ជាប់រវាងទ្វីបទាំង ២ នេះ ពិសេសហេដ្ឋារចនាសម្ព័ន្ធរវាងស្ថាប័ននឹងស្ថាប័នរវាងប្រជាជននឹងប្រជាជន។ ធ្វើឲ្យមានការកែលម្អក្នុងផលិតកម្ម ពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យអប់រំ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងការផ្ទេរបច្ចេកវិទ្យាពីប្រទេសអភិវឌ្ឍន៍ មកប្រទេសកំពុងអភិវឌ្ឍន៍ ។ ជំរុញឲ្យទ្វីបទាំងពីរនេះក្លាយជាដៃគូដ៏សំខាន់ ដើម្បីចូលរួមក្នុងការជំរុញផលប្រយោជន៍ទាំងសងខាង។ គួរបញ្ជាក់ថា ប្រទេសម៉ុងហ្គោលីនឹងទទួលធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំអាស៊ី-អឺរ៉ុប លើកទី ១១ នៅឆ្នាំ ២០១៦ ខាងមុខ ដែលត្រូវនឹងខួបលើកទី ១០ នៃការបង្កើតកិច្ចប្រជុំអាស៊ី-អឺរ៉ុបនេះផងដែរ។

ក្នុងឱកាសស្នាក់នៅទីក្រុងមីឡែននាថ្ងៃទី ១៦ ខែតុលា សម្តេចតេជោ **ហ៊ុន សែន** ក៏បានទទួលជួបពិភាក្សាការងារជាមួយឯកឧត្តម **ប្រាយុទ្ធ ចាន់អូចា** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ។ ប្រមុខរដ្ឋាភិបាលនៃប្រទេសទាំងពីរបានឯកភាពគ្នាថា នឹងមិនត្រូវទុកបញ្ហាព្រំដែនដែលនៅសេសសល់ឲ្យក្លាយជាឧបសគ្គដល់ការធ្វើកិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងនៃវិស័យដទៃទៀតរបស់ប្រទេសទាំងពីរនោះឡើយ ។ ត្រូវខិតខំពង្រីកកិច្ចសហប្រតិបត្តិការនៃប្រទេសទាំងពីរឲ្យកាន់តែរឹងមាំទ្វេឡើងថែមទៀត ពិសេសបំពេញឲ្យគ្នាទៅវិញទៅមក។ ក្នុងបញ្ហាសំខាន់គឺខិតខំជំរុញការអភិវឌ្ឍនៅតាមតំបន់ព្រំដែននៃប្រទេសទាំងពីរ។ បន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការក្នុងការទប់ស្កាត់ការឆ្លងដែនកាប់ឈើខុសច្បាប់ ការគាំពារថែរក្សានិរន្តរភាពព្រៃឈើនៅតាមព្រំដែន ការទប់ស្កាត់រួមគ្នាក្នុងការបង្ក្រាបបទឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ ពិសេសការរិះរកគ្រប់មធ្យោបាយក្នុងការអភិវឌ្ឍតំបន់ព្រំដែនមួយ ប្រកបដោយសន្តិភាព សហប្រតិបត្តិការពាណិជ្ជកម្ម និងវិនិយោគ ការផ្លាស់ប្តូរទេសចរណ៍ វប្បធម៌ កីឡា និង ភាពរីកចម្រើនរបស់ប្រជាជនរស់នៅតាមតំបន់ព្រំដែននៃប្រទេសទាំងពីរ។ ត្រូវបង្កើតស្មារតីថ្មីដើម្បីពង្រឹង និងពង្រីកកិច្ចសហការនៃប្រទេសទាំងពីរដោយសារយើងមានមោទនភាព ព្រោះជញ្ជីងពាណិជ្ជកម្មនៃប្រទេសទាំងពីរបានឈានដល់ជាង ៤០០០ លានដុល្លារអាមេរិកទៅហើយ។ ដោយឡែកនៅថ្ងៃទី ១៧ ខែតុលា សម្តេចតេជោ **ហ៊ុន សែន** ក៏បានអនុញ្ញាតឲ្យលោកជំទាវ **ជូលី ប៊ីស្សប** រដ្ឋមន្ត្រីក្រសួងការបរទេសអូស្ត្រាលី ចូលជួបសម្តែងការគួរសម និងបានពិភាក្សាគ្នាទៅលើអនុស្សរណៈនៃការយោគយល់គ្នាក្នុងការទទួលយកជនភៀសខ្លួនពីប្រទេសអូស្ត្រាលី មកតាំងទីលំនៅក្នុងប្រទេសកម្ពុជាកាលពីពេលកន្លងទៅនេះ។ សម្តេចតេជោ **ហ៊ុន សែន** បានមានប្រសាសន៍ថា ដោយសារតែកម្ពុជាជាភាគីហត្ថលេខីរបស់អង្គការសហប្រជាជាតិស្តីពីកាតព្វកិច្ចទទួលជនភៀសខ្លួននោះ កម្ពុជានឹងទទួលជនភៀសខ្លួនដោយគោលការណ៍ស្ម័គ្រចិត្តគ្មានការបង្ខិតបង្ខំនោះឡើយ។ ដោយអនុវត្តនូវគោលការណ៍ដែលបានចែងនោះ កម្ពុជានឹងប្រកាន់នូវគោលជំហរជាកាតព្វកិច្ចផង និងជាលក្ខណៈមនុស្សធម៌ផង។ប្រទេសទាំងពីរនឹងបន្តអនុវត្តលើកិច្ចព្រមព្រៀង និងអនុស្សរណៈ ដែលបានចុះហត្ថលេខារួចមកហើយ ក្នុងស្មារតីមនុស្សធម៌ គ្មានការបង្ខិតបង្ខំក្នុងន័យជំរុញកិច្ចសហប្រតិបត្តិការនៃប្រទេសទាំងពីរកម្ពុជា-អូស្ត្រាលី ឲ្យកាន់តែរឹងមាំរីកចម្រើនទ្វេឡើងថែមទៀត។

នៅព្រឹកថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០១៤ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ព្រមទាំងគណៈប្រតិភូជាន់ខ្ពស់បានធ្វើមាតុភូមិនិវត្តន៍ប្រកបដោយសុខសុវត្ថិភាព៕

# សម្តេចតេជោ : កម្ពុជាមិនអាចស្កប់ស្កល់នៅស្ងៀមទេ ត្រូវតែបន្តកែទម្រង់



*សម្តេចតេជោ **ហ៊ុន សែន** ថ្លែងសន្ទរកថាក្នុងសន្និសីទវិនិយោគអន្តរជាតិក្រោមប្រធានបទ កម្ពុជា:សករាជថ្មីនៃកាលានុវត្តភាព កំណើន ការផ្លាស់ប្តូរ និងសមាហរណកម្ម អាស៊ាន*

នៅក្នុងខែតុលានេះ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមក្នុងកម្មវិធីដ៏មានសារសំខាន់មួយចំនួននៅក្នុងប្រទេស។ វត្តមានរបស់សម្តេចបានភ្ជាប់ជាមួយនូវការកត់សម្គាល់អំពីវឌ្ឍនភាព និងការលើកឡើងនូវអនុសាសន៍ដ៏ខ្ពង់ខ្ពស់ដែលជាទស្សនវិស័យរបស់រាជរដ្ឋាភិបាលផងដែរ។

◆ព្រឹកថ្ងៃទី ៦ ខែតុលា ឆ្នាំ ២០១៤ សម្តេចតេជោ **ហ៊ុន សែន** បានអញ្ជើញចូលរួមក្នុងសន្និសីទវិនិយោគអន្តរជាតិក្រោមប្រធានបទ កម្ពុជា: សករាជថ្មីនៃកាលានុវត្តភាព កំណើន ការផ្លាស់ប្តូរ និងសមាហរណកម្ម អាស៊ាន ដែលរៀបចំឡើងដោយសភាពាណិជ្ជកម្មអន្តរជាតិនៃកម្ពុជានៅសណ្ឋាគារអាំងទែរកុងទីណង់តាល់ រាជធានីភ្នំពេញ។នាពេលនោះសម្តេចបានបញ្ជាក់លើចំណុចមួយចំនួន ក្នុងនោះផ្តោតសំខាន់ទៅលើការគាំទ្រការវិនិយោគទុននៅកម្ពុជា។

សម្តេចតេជោបានមានប្រសាសន៍ថា ខ្ញុំក៏សូមយកឱកាសនេះបញ្ជាក់ជូនថាកម្ពុជានៅតែមានជំហរបន្តស្វាគមន៍ និងបន្តជំរុញលើកទឹកចិត្ត


*ភ្ញៀវជាតិ-អន្តរជាតិ អញ្ជើញចូលរួមក្នុងសន្និសីទវិនិយោគអន្តរជាតិក្រោមប្រធានបទ កម្ពុជា:សករាជថ្មីនៃកាលានុវត្តភាព កំណើនការផ្លាស់ប្តូរ និងសមាហរណកម្ម អាស៊ាន*

ចំពោះបណ្តាគម្រោងវិនិយោគបរទេសមកកម្ពុជា ហើយរាជរដ្ឋាភិបាលនឹងបន្តកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ក្នុងគោលដៅបន្តពង្រឹងកិច្ចសហប្រតិបតិការសេដ្ឋកិច្ច ការបើកទូលាយ ព្រមទាំងការបង្កើតនូវបរិយាកាសវិនិយោគឱ្យកាន់តែល្អប្រសើរ មានការទាក់ទាញមានលក្ខណៈទុកចិត្តបានសម្រាប់វិនិយោគិន និងធុរជន ។ ខ្ញុំសូមបញ្ជាក់ជាថ្មីម្តងទៀតជូនថ្នាក់ដឹកនាំមន្ត្រីនៃក្រសួង ស្ថាប័នពាក់ព័ន្ធនឹងការងារធុរកិច្ចវិនិយោគថា ពេលនេះជាងពេលណាៗទាំងអស់ ដែលយើងត្រូវធ្វើការរួមគ្នាដើម្បីការអភិវឌ្ឍ និងវិបុលភាពរបស់កម្ពុជា និងកម្រិតតំបន់ទាំងមូល ។

សម្តេចបន្តថា ជាការពិតសេដ្ឋកិច្ចកម្ពុជានៅមានសក្តានុពលរីកលូតលាស់ខ្ពស់ និងមានកាលានុវត្តភាពធ្វើពិពិធកម្មក្នុងវិស័យជាច្រើនទៀត ដែលនេះអាចបញ្ជាក់យ៉ាងច្បាស់ថាកម្ពុជា នៅមានលំហសម្រាប់ការវិនិយោគក្នុងចំនួនដ៏ច្រើននាពេលខាងមុខ។បច្ចុប្បន្នវិស័យកាត់ដេរ ទេសចរណ៍ សំណង់ និងវិស័យកសិកម្ម ជាជន្ទល់នៃកំណើនរបស់កម្ពុជា ។ ប្រការនេះ ចង្អុលបង្ហាញពីភាពចាំបាច់ត្រូវវិនិយោគច្រើនថែមទៀត ក្នុងវិស័យផ្សេងៗទៀត ដើម្បីបង្កើតក្បាលម៉ាស៊ីននៃកំណើនថ្មីៗរបស់កម្ពុជា។ នេះជាតម្រូវការរបស់កម្ពុជា ហើយជាកាលានុវត្តភាពរបស់វិនិយោគិនទាំងឡាយ ពីព្រោះខណៈនេះ កម្ពុជាត្រូវធ្វើទំនើបកម្មនៃវិស័យឧស្សាហកម្មរបស់ខ្លួនដែលជាកិច្ចការដ៏ចាំបាច់មួយដោយសារវិស័យនេះនឹងដើរតួនាទីសំខាន់ក្នុងយុទ្ធសាស្ត្រកំណើន ។ ជាកម្លាំងចលករក្នុងការទ្រទ្រង់ដល់កំណើនរយៈពេលមធ្យមនិងរយៈពេលវែង។ជាវិស័យសក្តានុពលសម្រាប់បង្កើតការងារដល់យុវជន និងជាជន្ទល់កំណើនសេដ្ឋកិច្ចថ្មី ដែលអាចស្រូបយកការវិនិយោគបន្ថែមក្រៅពីវិស័យកសិកម្ម និងទេសចរណ៍ ។

សន្និសីទវិនិយោគអន្តរជាតិឆ្នាំ ២០១៤ បានប្រព្រឹត្តទៅក្រោមប្រធានបទ កម្ពុជា : សករាជថ្មីនៃកាលានុវត្តភាពកំណើន ការផ្លាស់ប្តូរ និងសមាហរណកម្មអាស៊ាន ត្រូវបានរៀបចំដោយសភាធុរកិច្ចអន្តរជាតិនៃកម្ពុជា នៅពេលនេះ និងគឺជាសន្និសីទវិនិយោគអន្តរជាតិធំបំផុតលើកទី១នាឆ្នាំ ២០១៤ ដែលរៀបចំឡើងក្រោយការបង្កើតឡើងនូវរាជរដ្ឋាភិបាលនីតិកាលទី ៥ ។

យោងតាមឯកសារដែលបង្ហាញនៅក្នុងសន្និសីទនេះ បានបញ្ជាក់ថា ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កម្ពុជាត្រូវបានគេទទួលស្គាល់ថាបានឆ្លងកាត់ការផ្លាស់ប្តូរយ៉ាងច្រើន មិនត្រឹមតែនៅក្នុងផ្នែកនយោបាយ និងសន្តិសុខប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានការផ្លាស់ប្តូរខាងផ្នែកសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសង្គមផងដែរ ។ ជាក់ស្តែង សេដ្ឋកិច្ចកម្ពុជាចាប់ពីឆ្នាំ ២០០៩ ដល់ឆ្នាំ ២០១៣ បានកើនឡើងជាមធ្យមប្រមាណ ៦,៧%បើទោះបីជាមានការធ្លាក់ចុះនៅក្នុងឆ្នាំ២០០៩ដោយសារតែវិបត្តិហិរញ្ញវត្ថុ និងការធ្លាក់ចុះនៃសេដ្ឋកិច្ចសកលលោកក្តី ។ នៅឆ្នាំ២០០៩សេដ្ឋកិច្ចកម្ពុជារក្សា



*សម្តេចតេជោ **ហ៊ុន សែន** ប្រគល់សញ្ញាបត្រ*
*ជូនដល់និស្សិតជ័យលាភីនៃសាកលវិទ្យាល័យឯកទេសនៃកម្ពុជា*

បាននូវកំណើនវិជ្ជមានក្នុងកម្រិត០,១% ខណៈប្រទេសមួយចំនួនធំមានកំណើនអវិជ្ជមាន។ កំណើនសេដ្ឋកិច្ចកម្ពុជាបានងើបឡើងវិញភ្លាមដោយសម្រេចបាននូវអត្រាកំណើនជាមធ្យមប្រមាណ ៧% ពីឆ្នាំ ២០១០-២០១៣ អាស្រ័យដោយភាពរឹងមាំនៃវិស័យនាំចេញទំនិញវាយនភណ្ឌ ទេសចរណ៍ និងវិស័យសំណង់ បើទោះបីជាការងើបឡើងនៃសេដ្ឋកិច្ចពិភពលោកនៅមានកម្រិតខ្សោយ ហើយកម្ពុជាបានជួបប្រឈមនឹងគ្រោះទឹកជំនន់ និងបញ្ហាមួយចំនួនទៀតដែលកើតឡើងបន្ទាប់ពីការបោះឆ្នោតក៏ដោយ ។ សន្ទុះកំណើនខ្ពស់នៃសេដ្ឋកិច្ចក្នុងតំបន់ និងការងើបឡើងវិញនៃសេដ្ឋកិច្ចសហរដ្ឋអាមេរិក និងតំបន់អឺរ៉ុប គួបផ្សំនឹងសមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការរក្សាបានកត្តាសុខសន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គមបានផ្តល់ផលជាវិជ្ជមានចំពោះសេដ្ឋកិច្ចកម្ពុជា ដែលក្នុងឆ្នាំ ២០១៣ កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចប្រមាណ៧,៦%។ សម្រាប់ឆ្នាំ ២០១៤ នេះ និងក្នុងរយៈពេលមធ្យមទៅមុខកំណើនសេដ្ឋកិច្ចត្រូវបានព្យាករណ៍ថា នឹងកើនលើសពី ៧ % ដោយផ្អែកលើការរីកចម្រើនក្នុងវិស័យថាមពល និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តដទៃទៀត ការលើកកម្ពស់សមត្ថភាពប្រកួតប្រជែង ការកែលម្អកិច្ចសម្រួលពាណិជ្ជកម្ម និងបរិយាកាសវិនិយោគជាដើម។ ដោយឡែក តាមការប៉ាន់ប្រមាណចំពោះអតិផរណាវិញ គឺស្ថិតនៅក្នុងកម្រិតទាបត្រឹមប្រមាណ៣ -៤% ក្នុងឆ្នាំ ២០១៤ នេះ ទោះបីអត្រាអតិផរណាក្នុងតំបន់មានកំណើនខ្ពស់ គួបផ្សំនឹងការកើនឡើងនៃថ្លៃម្ហូបអាហារ និងប្រេងឥន្ធនៈក៏ដោយ ។ ចំណែកឯអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារវិញគឺមានស្ថិរភាពល្អ និងមានការផ្លាស់ប្តូរតិចតួចប៉ុណ្ណោះ ។ ប្រព័ន្ធធនាគារ ជារួមមានភាពរឹងមាំល្អ ដោយមានប្រភពមូលធនគ្រប់គ្រាន់ និងមានសន្ទិធិសាច់ប្រាក់សមរម្យ ។ ប្រាក់បញ្ញើ និងកម្ចីក្នុងធនាគារបន្តកើនឡើងក្នុងឆ្នាំ ២០១៣ ដែលឆ្លុះបញ្ចាំងពីទំនុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធធនាគារកម្ពុជា ។ ទុនបម្រុងអន្តរជាតិក្នុងឆ្នាំ២០១៣មានកំណើនប្រមាណ៥,២% ហើយត្រូវបានរំពឹងថានឹងកើនឡើងរហូតដល់ប្រមាណ ៥.០០០ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៤នេះ ដែលមានចំនួនគ្រប់គ្រាន់សម្រាប់ចំណាយលើការនាំចូលប្រមាណ ៤ ខែកន្លះ ។

សម្តេចនាយករដ្ឋមន្ត្រីមានប្រសាសន៍ទៀតថា ដើម្បីរួមចំណែកសម្រេចគោលដៅគាំពារភាពអំណោយផលនៃកំណើនសេដ្ឋកិច្ច សម្រាប់ថ្ងៃខាងមុខ ដែលនឹងធ្វើឱ្យកម្ពុជាអាចនឹងគ្រប់គ្រង និងរក្សាចីរភាពនៃកំណើនសេដ្ឋកិច្ចរបស់ខ្លួនបាននោះ រាជរដ្ឋាភិបាលក្នុងនីតិកាលទី ៥ នៃរដ្ឋសភា បានប្តេជ្ញាចិត្តខ្ពស់ក្នុងការបន្តអនុវត្តនូវការកែទម្រង់ស៊ីជម្រៅ និងមានប្រសិទ្ធភាពលើការងារសំខាន់ៗ រួមមាន៖ ១.ការកែលម្អបរិស្ថានវិនិយោគ និងកិច្ចសម្រួលពាណិជ្ជកម្ម ។ ២.ការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ។ ៣.ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រយុទ្ធប្រឆាំងអំពើពុករលួយ ។ ៤.ការសម្របសម្រួលឱ្យមានភាពស៊ីចង្វាក់គ្នារវាងវិស័យអប់រំ វិស័យបណ្តុះបណ្តាលវិជ្ជាជីវៈ និងបន្តបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និង៥.ការបន្តជំរុញធ្វើពិពិធកម្មប្រភពនៃកំណើនសេដ្ឋកិច្ចឱ្យមានប្រសិទ្ធភាព តាមរយៈការអនុម័ត និងជំរុញគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម។

សម្តេចតេជោបញ្ជាក់ទៀតថា ចំពោះមុខនេះក្នុងការធ្វើសមាហរណកម្មសេដ្ឋកិច្ចអាស៊ានក្នុងឆ្នាំ ២០១៥ កម្ពុជាត្រូវត្រៀមខ្លួនលើកិច្ចការមួយដែលមិនអាចខ្វះបានគឺការអភិវឌ្ឍមូលធនមនុស្ស។កម្ពុជាត្រូវការធនធានមនុស្សប្រកបដោយគុណភាព និងសមត្ថភាព ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការក្នុងការប្រកួតប្រជែងនាអនាគតវែងឆ្ងាយខាងមុខ។ការកែទម្រង់ការងារអប់រំផ្សេងៗទៀតដើម្បីធានាថា ធនធានមនុស្សនៅកម្ពុជាត្រូវមានគុណភាពពិតប្រាកដ ដែលអាចឆ្លើយតបទៅនឹងតម្រូវការនៃការរីកចម្រើនលូតលាស់របស់ប្រទេស និងពិសេស តម្រូវការរបស់វិស័យឯកជន។ក្នុងចំណុចនេះរាជរដ្ឋាភិបាលនឹងបន្តពង្រឹងគុណភាពអប់រំ និងការអភិវឌ្ឍជំនាញបច្ចេកទេសសម្រាប់យុវជន កម្មករ និងនិយោជិត ដើម្បីអាចឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃទីផ្សារការងារ និងដើម្បីធានានូវការបន្តវេន



*និស្សិតជ័យលាភីនៃសាកលវិទ្យាល័យឯកទេសនៃកម្ពុជា*
*ចូលរួមក្នុងពិធីប្រគល់សញ្ញាបត្រ*



*សម្ដេចតេជោ **ហ៊ុន សែន** អញ្ជើញត្រួតពលក្នុងឱកាសប្រារព្ធពិធីខួបអនុស្សាវរីយ៍លើកទី ២០ នៃថ្ងៃបង្កើតកងពលតូចថ្មើរជើងលេខ ៧០*

ក្នុងការដឹកនាំ និងការអភិវឌ្ឍប្រទេសប្រកបដោយចីរភាព។

◆ព្រឹកថ្ងៃទី ៩ ខែតុលា សម្ដេចតេជោនាយករដ្ឋមន្ត្រីបានអញ្ជើញចូលរួមក្នុងពិធីប្រគល់សញ្ញាបត្រជូនដល់និស្សិតជ័យលាភី នៃសាកលវិទ្យាល័យឯកទេសនៃកម្ពុជាចំនួន ៦.៧៤៨ នាក់ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ នៅទីនោះ សម្ដេចបានថ្លែងទាក់ទងទៅដល់ការបន្តជំរុញកំណែទម្រង់ និងការព្យាករណ៍អំពីភាពឈានឡើងជាជំហានៗរបស់កម្ពុជា ។

សម្ដេចមានប្រសាសន៍ថា ពិតមែនតែយើងនៅមានបញ្ហានេះបញ្ហានោះមិនចប់ ប៉ុន្តែនៅក្នុងដំណាក់កាលនៃការឈានឡើងរបស់ប្រទេសគឺគ្មានប្រទេសណាមួយដែលនិយាយថាស្កប់ស្កល់បានទេ ។ ត្រូវនិយាយពីការកែទម្រង់ ។ សូម្បីតែនៅសហរដ្ឋអាមេរិកដែលជាប្រទេសជឿនលឿនណាស់ទៅហើយក៏និយាយពីការកែទម្រង់។ នៅអឺរ៉ុបក៏និយាយពីការកែទម្រង់។ នៅជប៉ុនក៏និយាយពីការកែទម្រង់។ ដូច្នេះសម្រាប់នៅកម្ពុជាការកែទម្រង់វាជាការចាំបាច់ ដើម្បីដើរឲ្យទាន់តម្រូវការនៃការអភិវឌ្ឍប្រទេសគឺមិនអាចនៅស្កប់ស្កល់នៅស្ងៀមបានទេ។ ដូចនេះគ្រប់ស្ថាប័នរបស់រដ្ឋបុគ្គលម្នាក់ៗជាមន្ត្រីរាជការក្តី ឬក្នុងចំណោមយុវជនក្តី គឺត្រូវតែមានការរួមចំណែកដើម្បីធ្វើកំណែទម្រង់។ គោលដៅនៃការកែទម្រង់របស់យើងគឺដើម្បីរក្សាឱ្យបាននូវល្បឿននៃកំណើនសេដ្ឋកិច្ចក៏ដូចជាចីរភាពនៃការអភិវឌ្ឍ រាប់ទាំងបញ្ហាធនធានធម្មជាតិ និងបញ្ហាបរិស្ថានផងដែរ ។

សម្ដេចតេជោបន្តថា នៅប្រទេសដទៃប្លែកពីប្រទេសកម្ពុជានៅត្រង់ថាប្រទេសគេមានការផ្លាស់ប្តូរ ទោះបីជាការផ្លាស់ប្តូរនោះតាមរយៈការបោះឆ្នោតក្តី ឬតាមរយៈការផ្តួលរំលំដោយកម្លាំងប្រដាប់អាវុធក្តី ក៏ប៉ុន្តែប្រទេសរបស់គេនៅមានធនធានមនុស្ស នៅមានរចនាសម្ព័ន្ធ ទោះបីជាក្នុងរូបិយប័ណ្ណគេហាមបន្តប្រើរូបិយប័ណ្ណចាស់នៃរបបមុន ឬគេអាចបោះរូបិយប័ណ្ណថ្មីដើម្បីប្តូររូបិយប័ណ្ណចាស់ ។ ប៉ុន្តែសម្រាប់ប្រទេសរបស់យើងវិញគឺត្រូវរៀបចំឡើងវិញទាំងអស់រាប់ទាំងរូបិយប័ណ្ណ។ កម្ពុជាគ្មានរូបិយប័ណ្ណដែលបន្សល់ទុកដោយរបបលន់ណុល សម្រាប់ប្តូរជាមួយរូបិយប័ណ្ណដែលយើងបោះផ្សាយក្រោយថ្ងៃ ៧ មករាឆ្នាំ ១៩៧៩ ទេ។ នេះជាបញ្ហាខុសគេនៅលើពិភពលោក ហើយកម្ពុជាខ្លួនឯងក៏មិននឹកស្មានផងដែរថានៅចុងសតវត្សរ៍ទី ២០ មានរឿងនេះកើតឡើងនៅក្នុងប្រទេសមួយនៃអាស៊ាននេះ គឺប្រទេសកម្ពុជា ។

សម្ដេចបន្តទៀតថា ឥឡូវនេះគឺយើងបានឆ្លងកាត់ជាបណ្តើរៗអស់រយៈពេលជាង ៣៥ ឆ្នាំ រួចមកហើយ។ គឺមានការលំបាកណាស់ទម្រាំតែបានមកដល់ពេលនេះ។ កម្ពុជាយើងបានស្ថិតនៅក្នុងស្ថានភាពស្មើមុខស្មើមាត់ជាមួយនឹងគេ។ កម្ពុជាមិនត្រឹមតែដោះស្រាយនូវបញ្ហារបស់ខ្លួននោះទេក៏ប៉ុន្តែយើងក៏បានរួមចំណែកដោះស្រាយបញ្ហាជាមួយនឹងប្រទេសដទៃផងដែរ។

ក្នុងបញ្ហាកំណែទម្រង់នេះដែរ សម្ដេចនាយករដ្ឋមន្ត្រីក៏បានរំលឹកពីវីរនារី ស៊ន សៀវម៉ី កីឡាការិនីតេក្វាន់ដូដែលបាននាំមកនូវមេដាយមាសពីកីឡាអាស៊ីលើកដំបូងមកកាន់ព្រះរាជាណាចក្រកម្ពុជា។ សម្ដេចបញ្ជាក់ថាត្រង់ចំណុចនេះយើងអាចព្យាករណ៍បានថា កម្ពុជាកំពុងឈានជើងបន្តិចម្តងៗនៃដំណើរវិវឌ្ឍន៍នៅក្នុងក្របខណ្ឌប្រទេសរបស់ខ្លួនផង និងនៅក្នុងក្របខណ្ឌតំបន់ផង ។ កម្ពុជាបានឈានឡើងបន្តិចម្តងៗក្នុងនោះមានវិស័យកីឡាផងដែរ។ យើងមានមោទនភាពថាយើងនឹងឈានឡើងបន្តិចម្តងៗ។ គ្មានអ្នកណាមួយដែលមិនឆ្លងកាត់ដំណាក់កាលអន្តរកាលឈានឡើងនោះទេ។ ដំណើររាប់រយគីឡូម៉ែត្រ ឬរាប់ពាន់គីឡូម៉ែត្រ ត្រូវចាប់ផ្តើមពីមួយជំហានដំបូង។ដូចនេះ យើងនឹងបន្តកិច្ចខិតខំរបស់យើងបន្តទៀតហើយចំណងទាក់ទងរបស់យើង ជាមួយសហគមន៍អន្តរជាតិកាន់តែធំៗទៅ តំបន់ភាវូបនីយកម្ម និងសាកលភាវូបនីយកម្ម តម្រូវឲ្យកម្ពុជាត្រូវតែជំរុញនូវការអភិវឌ្ឍ ក្នុងនោះធនធានមនុស្សគឺជាបញ្ហាដ៏មានសារសំខាន់។ ធនធានមនុស្សនេះមិនត្រឹមតែត្រូវការសម្រាប់ការអភិវឌ្ឍដាច់ដោយឡែករបស់កម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែត្រូវការសម្រាប់ការប្រកួតប្រជែងក្នុងក្របខណ្ឌតំបន់ និងអន្តរជាតិ ហើយបើទោះបីមិនមានការប្រកួតប្រជែងក្នុងតំបន់ និងពិភពលោកក៏ដោយ ក៏យើងត្រូវការអភិវឌ្ឍប្រទេសរបស់យើងតាមរយៈចំណេះដឹងរបស់ពលរដ្ឋកម្ពុជាយើង។ យើងអាចព្យាករណ៍បានថាកម្ពុជាកំពុងឈានជើងបន្តិចម្តងៗ ក្នុងដំណើរវិវឌ្ឍន៍នៅក្នុងក្របខណ្ឌប្រទេសរបស់ខ្លួនផង និងនៅក្នុងក្របខណ្ឌតំបន់ផងដែរ។

◆ព្រឹកថ្ងៃទី១៣ ខែតុលា សម្ដេចតេជោបានអញ្ជើញចូលរួមក្នុងពិធីប្រារព្ធខួបអនុស្សាវរីយ៍លើកទី២០នៃថ្ងៃបង្កើតកងពលតូចថ្មើរជើង លេខ ៧០ នៅបញ្ជាការដ្ឋានកងពលតូចថ្មើរជើងលេខ៧០(ចោមចៅ) ។ ក្នុងឱកាសនោះ សម្ដេចបានបញ្ជាក់អំពីការជំរុញកំណែទម្រង់កងទ័ពនៅកម្ពុជាឲ្យកាន់តែរីកចម្រើនទាំងសមត្ថភាព និងគុណភាព។

សម្ដេចមានប្រសាសន៍ថា ទន្ទឹមនឹងអ្វីដែលកងទ័ពរបស់យើងសម្រេចបានមកនេះ រាជរដ្ឋាភិបាលនឹងបន្តខិតខំប្រឹងប្រែងក្នុងការអនុវត្តកម្មវិធីកែទម្រង់នានា ដើម្បីបន្តពង្រឹង និងពង្រីកសមត្ថភាពការធ្វើទំនើបកម្មការកសាងសំណាញ់សុវត្ថិភាពសម្រាប់កងយោធពលខេមរភូមិន្ទដើម្បីឱ្យការបំពេញភារកិច្ចរបស់កងទ័ពកាន់តែមានប្រសិទ្ធភាព ជាកងកម្លាំងមានវិជ្ជា-





*ក្បួនព្យុះហយាត្រារបស់កងពលតូចថ្មើរជើងលេខ ៧០ ក្នុងឱកាសប្រារព្ធពិធីខួបអនុស្សាវរីយ៍លើកទី ២០ នៃថ្ងៃបង្កើតកងពលតូចថ្មើរជើងលេខ ៧០*

ជីវៈជំនាញ មានសមត្ថភាពពេញលេញ កាន់តែមោះមុត ដើម្បីចូលរួមក្នុងបេសកកម្មនានាឱ្យបានជោគជ័យ ។

សម្តេចបន្តថា ការប្រារព្ធខួបនៃកំណើតកងពលតូចលេខ ៧០ នេះ គឺមិនត្រឹមតែបានឆ្លុះបញ្ចាំងពីឆន្ទៈដ៏មោះមុតរបស់រាជរដ្ឋាភិបាលក្នុងការបន្តគាំទ្រនិងលើកទឹកចិត្តខ្ពស់ដល់មេបញ្ជាការ មេបញ្ជាការរង និងពលទាហានទាំងអស់នៃកងពលតូចលេខ ៧០ ប៉ុណ្ណោះទេ ប៉ុន្តែក៏ជាឱកាសក្រើនរំឭកពីភាពចាំបាច់ខានពុំបាននៃការពង្រឹងផែនសាមគ្គីជាតិឯកភាពជាតិ ការពួតដៃគ្នាជាធ្លុងមួយក្នុងស្មារតីដើម្បីរួមចំណែកបន្តលើកកម្ពស់ការថែរក្សាឱ្យបានគង់វង្សនូវកត្តាសុខសន្តិភាព ភាពសុខដុមរមនា និងសុខុមាលភាពរបស់ប្រជាជាតិទាំងមូល។ យើងទាំងអស់គ្នាបានយល់ច្បាស់ណាស់អំពីកត្តាសុខសន្តិភាពនេះ ពីព្រោះជាបុព្វលក្ខខណ្ឌមិនអាចខ្វះបាននៃរាល់កិច្ចអភិវឌ្ឍន៍ និងភាពរីកចម្រើននៃប្រជាជាតិនីមួយៗ។ ពិសេសការធ្វើឱ្យជីវភាពរបស់ប្រជាជនកាន់តែល្អប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃ។ តាមរយៈនេះ យើងអាចមើលឃើញអំពីគុណបំណាច់ដ៏ធំធេងមិនអាចកាត់ថ្លៃបានរបស់កងយោធពលខេមរភូមិន្ទ ដែលតែងបានបូជាសាច់ស្រស់ឈាមស្រស់ ហ៊ានធ្វើពលិកម្មជីវិតក្នុងការបំពេញបេសកកម្មដ៏ឧត្តុង្គឧត្តមរបស់ខ្លួនក្នុងបុព្វហេតុដើម្បីជាតិសាសនាព្រះមហាក្សត្រនៅគ្រប់ដំណាក់កាល។

សម្តេចបន្តថា ពិតណាស់ថាភាពរីកចម្រើនលូតលាស់ជាលំដាប់នៃកងទ័ពកម្ពុជាយើងនេះ បានផ្តើមចេញពីឆន្ទៈនៃកម្លាំងមហាសាមគ្គីរបស់កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលបានផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត នៅថ្ងៃ ៧ មករា ១៩៧៩ ដែលជាចំណុចចាប់ផ្តើមនៃការកសាងឡើងវិញនូវរាល់សមិទ្ធផលគ្រប់បែបយ៉ាងទាំងអស់របស់ប្រជាជន និងសង្គមកម្ពុជារួមទាំងអាយុជីវិត សិទ្ធិសេរីភាព ប្រពៃណី ទំនៀមទម្លាប់ ជំនឿសាសនា លទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍលើគ្រប់វិស័យដូចដែលយើងទាំងអស់គ្នាកំពុងមើលឃើញនាពេលសព្វថ្ងៃនេះ ។ ចំពោះមុខនេះ រាជរដ្ឋាភិបាលនៅតែប្រកាន់ជំហរបន្តគាំទ្រឥតងាករេ ចំពោះការពង្រឹង និងពង្រីកបន្ថែមទៀតនូវកិច្ចសហការរបស់អង្គភាពកងទ័ពនីមួយៗជាមួយនឹងស្ថាប័នស៊ីវិលផ្សេងៗទៀត ក្នុងគោលដៅរួមចំណែកលើកកម្ពស់សមត្ថភាពកងទ័ពកម្ពុជា ។

សម្តេចបានសង្កត់ធ្ងន់ថា តាមរយៈការអភិវឌ្ឍសមត្ថភាពកងទ័ពជាបន្តបន្ទាប់ កងទ័ពកម្ពុជានឹងមិនត្រឹមតែជាកម្លាំងស្នូលទទួលរ៉ាប់រងការងារថែរក្សាការពារបូរណភាពទឹកដី និងរួមចំណែកក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិប៉ុណ្ណោះទេ ប៉ុន្តែនឹងបានក្លាយខ្លួនជាកម្លាំងយ៉ាងរឹងមាំជួយរក្សាសន្តិភាពនៅបណ្តាប្រទេសមួយចំនួន តាមសំណើរបស់អង្គការសហប្រជាជាតិទៀតផង។ ដូច្នេះ ចាំបាច់ណាស់ដែលកងទ័ពនៃកងពលតូចលេខ៧០និយាយដោយឡែកនិងនិយាយរួមកងយោធពលខេមរភូមិន្ទត្រូវបន្តការងារអភិវឌ្ឍន៍សមត្ថភាពកងទ័ពឱ្យបានជាប់ជាប្រចាំ។ ត្រៀមកម្លាំងត្រៀមស្មារតីដោះស្រាយឱ្យបាននៅគ្រប់សភាពការណ៍ ។ យើងក៏ដឹងហើយថាគ្រោះមហន្តរាយធម្មជាតិអាចនឹងកើតឡើងជាយថាហេតុ និងបង្កឱ្យខូចខាតទ្រព្យសម្បត្តិផលប្រយោជន៍ជាតិ និងប្រជាជនដោយមិនអាចគិតទុកជាមុនបាន។ បញ្ហាមួយនេះបានតម្រូវឱ្យយើងត្រូវមានការឆ្លើយតបក្នុងប្រតិបត្តិការនេះឱ្យបានទាន់ពេលវេលា ជាពិសេសពីសំណាក់កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទរបស់យើង ។ កងទ័ពយើងត្រូវត្រៀមមធ្យោបាយសម្រាប់ដឹកជញ្ជូនសម្ភារៈនិងជនរងគ្រោះ។ ផ្តល់ជំនួយស្បៀងអាហារ និងសម្ភារៈប្រើប្រាស់។ រៀបចំក្រុមពេទ្យចល័តដើម្បីផ្តល់សេវាថែទាំព្យាបាលសុខភាព ។ បង្កើនកិច្ចសហការសម្របសម្រួលជាមួយសមភាគីផ្នែកស៊ីវិលក្នុងប្រតិបត្តិការសង្គ្រោះនានា ដូចអ្វីដែលកងទ័ពបានអនុវត្តរួចមកហើយក្នុងប្រតិបត្តិការសង្គ្រោះនានាដូចជាគ្រោះទឹកជំនន់គ្រោះរាំងស្ងួតគ្រោះអគ្គិភ័យការដោះមីនរំដោះដីស្រែជូនប្រជាជនសម្រាប់បង្កបង្កើនផល និងការបញ្ជូនក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យព្យាបាលជំងឺជូនប្រជាជននៅតាមជនបទជាដើម។

អ្វីដែលសម្តេចតេជោនាយករដ្ឋមន្ត្រីបានលើកឡើង នូវកម្មវិធីនានាដែលសម្តេចបានអញ្ជើញចូលរួម មិនត្រឹមតែជាការឆ្លុះបញ្ចាំងអំពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលប៉ុណ្ណោះទេ តែក៏បានបញ្ជាក់យ៉ាងច្បាស់អំពីឆន្ទៈដ៏មោះមុតរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការដឹកនាំនាវាកម្ពុជាឈានទៅរកវឌ្ឍនភាព សុខសន្តិភាព និងវិបុលភាពយ៉ាងពិតប្រាកដ៕

# គណបក្សប្រជាជនទទួលបានភាពជាអ្នកដឹកនាំនៅក្នុងតួនាទីរបស់គណបក្សនយោបាយនៅអាស៊ី



*គណៈប្រតិភូចូលរួមក្នុងមហាសន្និបាតលើកទី៨របស់ ICAPP នៅទីក្រុងកូឡុំបូ ប្រទេសស្រីលង្កា នាថ្ងៃទី១៨-២១ ខែកញ្ញា ឆ្នាំ ២០១៤*

ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល នៃគណបក្សប្រជាជនកម្ពុជា និងជាអនុប្រធានគណៈអចិន្ត្រៃយ៍នៃសន្និសីទអន្តរជាតិ នៃគណបក្សនយោបាយនៅអាស៊ី (ICAPP) បានដឹកនាំគណៈប្រតិភូគណបក្សប្រជាជនកម្ពុជាទៅចូលរួមក្នុងមហាសន្និបាតលើកទី ៨ របស់ ICAPP ក្រោមប្រធានបទ ការបង្កើតសហគមន៍អាស៊ី ដែលប្រព្រឹត្តិទៅនៅទីក្រុងកូឡុំបូ ប្រទេសស្រីលង្កា នាថ្ងៃទី ១៨-២១ ខែកញ្ញា ឆ្នាំ ២០១៤ ដែលមានអ្នកចូលរួមពីប្រតិភូបរទេសជាង ៣០០នាក់ មកពីគណបក្សនយោបាយចំនួន ៦៧ មកពី ២៩ ប្រទេស។

គួរបញ្ជាក់ថា ICAPP ត្រូវបានបង្កើតឡើងនៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន នាឆ្នាំ ២០០០ ចេញពីសមាជិកស្ថាបនិកដែលមកពីប្រមាណ ៤០ គណបក្សនយោបាយនៅអាស៊ី ។ បច្ចុប្បន្ននេះ ICAPP មានសមាជិកប្រមាណ ៣៤០ គណបក្សនយោបាយ ដែលមានមនោគមវិជ្ជានយោបាយខុសៗគ្នាមកពីប្រទេសចំនួន ៥២ នៅទ្វីបអាស៊ី។

ICAPP និងអង្គការប្រជាធិបតេយ្យនិយមកណ្ដាលអាស៊ីប៉ាស៊ីហ្វិក-អន្តរជាតិ (CAPDI) ដែលជាអង្គការបងប្អូនប្រកាន់ខ្ជាប់នូវគោលការណ៍ប្រជាធិបតេយ្យតាមបែបប្រទេសនីមួយៗនៅអាស៊ី និងបដិសេធនូវគ្រប់ទម្រង់នៃទស្សនវិជ្ជាជ្រុលនិយម។

ឯកឧត្តមបណ្ឌិតសភាចារ្យបានថ្លែងនៅក្នុងសម័យប្រជុំ ដោយបានលើកឡើងពីបទពិសោធន៍នៃការបញ្ចប់សង្គ្រាមស៊ីវិលនៅកម្ពុជា ជាពិសេសកិច្ចព្រមព្រៀងទីក្រុងប៉ារីសនាឆ្នាំ១៩៩១ និងនយោបាយឈ្នះឈ្នះនាឆ្នាំ១៩៩៨ជោគជ័យនៃសាលាក្ដីខ្មែរក្រហម (ECCC) នាខែសីហាឆ្នាំ២០១៤ ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមដ៏ឆាប់រហ័ស ការធ្វើជាម្ចាស់ផ្ទះនាសម័យប្រជុំលើកទី៣៧នៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោកនាឆ្នាំ២០១៣ និងការត្រៀមធ្វើជាម្ចាស់ផ្ទះនៃសន្និសីទពិភពលោកលើកទី ១ រវាងអង្គការទេសចរណ៍ពិភពលោក (UNWTO) និងអង្គការ UNESCO ស្ដីពីទេសចរណ៍ និងវប្បធម៌នាឆ្នាំ ២០១៥ ខាងមុខនេះ។

ឯកឧត្តមបណ្ឌិតសភាចារ្យបានលើកឡើងដោយមោទនភាពថាសមិទ្ធផលនៃការបង្រួបបង្រួមជាតិ និងការអភិវឌ្ឍជាតិ ចាប់ពីដើមឆ្នាំ១៩៨០ មកដល់បច្ចុប្បន្ននេះ អាចសម្រេចបាន ដោយមានគណបក្សប្រជាជនកម្ពុជា ដើរតួនាទីជាស្នូល និងមានរាជរដ្ឋាភិបាលដឹកនាំដោយសម្ដេចតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី។

ចំពោះការបង្កើត សហគមន៍អាស៊ីវិញ ឯកឧត្តមបណ្ឌិតសភាចារ្យបានអំពាវនាវ ឲ្យអ្នកដឹកនាំក្នុងទ្វីបអាស៊ីទាំងអស់ គួរធ្វើអ្វីៗគ្រប់បែបយ៉ាងដើម្បីលុបបំបាត់ភាពក្រីក្រដែលជាប្រភពនៃទំនាស់ ដោយជួយជនក្រីក្រឲ្យទទួលបានផលនៃកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍសតវត្សរបស់អាស៊ីប្រកបទៅដោយសមធម៌។ឯកឧត្តមបណ្ឌិតសភាចារ្យក៏បានបញ្ជាក់ផងដែរថាដើម្បីសម្រេចបាននូវកិច្ចការទាំងនេះ សន្តិភាព សន្តិសុខ និងស្ថិរភាព នយោបាយនៅតែជាមូលដ្ឋានគ្រឹះសម្រាប់ការកសាងជាតិ ដែលត្រូវតែរក្សាឲ្យខាងតែបាន។

ឯកឧត្តម **សួស យ៉ារ៉ា** អ្នកតំណាងរាស្ត្រ ក្នុងនាមអនុប្រធានជាន់ខ្ពស់នៃយុវជន ICAPP ត្រូវបានអញ្ជើញធ្វើជាអ្នកសម្របសម្រួលនៅក្នុងកិច្ចប្រជុំលើកទី ៣ ស្ដីពីយុវជន ICAPP ក្រោមប្រធានបទ តួនាទីរបស់អ្នកនយោបាយវ័យក្មេងក្នុងការបង្កើតសហគមន៍អាស៊ី ។ វេទិកាយុវជនក៏បានបើកទូលាយឲ្យមានការពិភាក្សាយ៉ាងចំហពីទស្សនៈនៃការធ្វើដំណើរឆ្ពោះទៅរកការបង្កើតសហគមន៍អាស៊ី ហើយតំណាងយុវជនមកពីគ្រប់តំបន់បានធ្វើបទអន្តរាគមន៍។ ដោយឡែកយុវជនសម្រាប់តំបន់អាស៊ីអាគ្នេយ៍ត្រូវបានថ្លែងដោយលោក សុខ សូកាន (អគ្គលេខាធិការរងរាជរដ្ឋាភិបាល)។ ក្នុងឱកាសនោះ ឯកឧត្តម **សួស យ៉ារ៉ា** ក៏បានលើកឡើងថាការបង្កើតសហគមន៍អាស៊ីត្រូវតែចាប់ផ្ដើមចេញពីការបង្កើតអត្តសញ្ញាណអាស៊ីមួយ និងជាការពិតណាស់ការចូលរួមរបស់យុវជន គឺជាកត្តាចាំបាច់ដើម្បីសម្រេចនូវបេសកកម្មទាំងនេះ ។ ក្នុងនាមជាជំនាន់បន្តវេនរបស់ ICAPP អ្នកនយោបាយវ័យក្មេងបានប្ដេជ្ញាចិត្តថានឹងប្រកាន់ខ្ជាប់នូវគតិបណ្ឌិតរបស់អ្នកជំនាន់មុន និងគោលការណ៍ធម្មនុញ្ញរបស់ ICAPP ដើម្បីបង្កើតជាវេទិកាមួយសម្រាប់ផ្លាស់ប្ដូរយោបល់ និងបង្កើតជាបណ្ដាញក្នុងចំណោមអ្នកនយោបាយវ័យក្មេង និងជំរុញវប្បធម៌អហិង្សា ការពិភាក្សាអន្តរសាសនា និងអន្តរវប្បធម៌ដើម្បីរស់នៅក្នុងសន្តិសហវិជ្ជមាន និងវិបុលសុខរួមគ្នាក្នុងគ្រួសារនៃទ្វីបអាស៊ីយើងនេះ។

អង្គសន្និបាតក៏បានផ្ដល់អាទិភាពដល់វេទិកា ស្ដីពីតួនាទីស្ត្រីផងដែរ ដែលបានអនុញ្ញាតឲ្យតំណាងស្ត្រីមកពីគ្រប់មជ្ឈដ្ឋាន ថ្លែងអំពីទស្សនៈ និងតួនាទីស្ត្រីក្នុងសង្គម ពិសេសវាគ្មិននីមួយៗបានចាប់អារម្មណ៍ខ្លាំងលើការបំបាត់អំពើហិង្សាលើស្ត្រី និងការជួញដូរស្ត្រី និងកុមារនៅក្នុងតំបន់។

# សកម្មភាពសមាជិកព្រឹទ្ធសភា_រដ្ឋសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស



ថ្ងៃទី១៧-១៩ ខែតុលា ឆ្នាំ២០១៤ ឯកឧត្តមបណ្ឌិត **ខួន ញិល** អនុប្រធានទី ២ រដ្ឋសភា សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តកំពង់ធំ បានអញ្ជើញជាអធិបតីក្នុងពិធីប្រណាំងទូក ង នៅថ្នាក់ខេត្ត ដើម្បីត្រៀមលក្ខណៈចូលរួមក្នុងព្រះរាជពិធីបុណ្យអុំទូក លយប្រទីប អកអំបុក និងសំពះព្រះខែ នៅរាជធានីភ្នំពេញ នាថ្ងៃទី ៥.៦.៧ ខែវិច្ឆិកា ឆ្នាំ ២០១៤ ។ ក្នុងឱកាសនោះដែរ ឯកឧត្តមបណ្ឌិត **ខួន ញិល** បានអញ្ជើញថ្វាយបង្គំព្រះសង្ឃ និងជួបសំណេះសំណាលជាមួយកីឡាករអុំទូក ដែលជាទូកពិសេសចំនួន ៣ របស់ឯកឧត្តមបណ្ឌិត គឺទូកឈ្មោះ សែនសិរីមានជ័យ ស្ថិតក្នុងវត្តសែនសិរី សង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន ទូកឈ្មោះ តេជោសែនជ័យ ស្ថិតក្នុងវត្តក្តីដូង ឃុំក្តីដូង ស្រុកកំពង់ស្វាយ និងទូកឈ្មោះស្ទឹងសែនមានជ័យ ស្ថិតក្នុងវត្តស្លែង ឃុំក្តីដូង ស្រុកកំពង់ស្វាយ ។ ឯកឧត្តមបណ្ឌិត **ខួន ញិល** បានចំណាយផ្ទាល់ឧបត្ថម្ភដល់គណៈកម្មការរៀបចំបុណ្យជាតិ-អន្តរជាតិខេត្តកំពង់ធំ ដែលបានរៀបចំពិធីប្រណាំងទូកងថ្នាក់ខេត្តនូវថវិកាចំនួន ២.០០០ ដុល្លារ និងមី ២០ កេសធំ ។ ប្រគេនបច្ច័យចៅអធិការវត្តទាំងបីក្នុងមួយវត្ត ១.០០០ ដុល្លារ ។ ឧបត្ថម្ភកីឡាករអុំទូកពិសេសទាំងបីចំនួន ៣០០ នាក់ គឺខោ ៣០០ អាវ ៣០០ មួក ៣០០ សារុង ៣០០ និងថវិកាក្នុងមួយនាក់ចំនួន ៤០.០០០ រៀល។



*ថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៤ ឯកឧត្តម **តាត ឈន់** ឧបនាយករដ្ឋមន្ត្រីប្រចាំការ សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងលោកជំទាវ ព្រមទាំងបុត្រាបុត្រី ចៅប្រុសចៅស្រី រួមនឹងមិត្តញាតិសណ្តាន បានដង្ហែអង្គកឋិនទានទៅកាន់វត្តវាលកន្សែង ឃុំកំពង់ដំរី ស្រុកឆ្លូង ខេត្តក្រចេះ។ អង្គកឋិនទទួលបានបច្ច័យចំនួន ១៨០ លានរៀល។*



ចាប់ពីថ្ងៃទី ១៤ ដល់ ១៨ ខែតុលា ឆ្នាំ ២០១៤ ឯកឧត្តម **ប៊ូ ថង** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ប្រធានក្រុមការងារថ្នាក់កណ្តាល ចុះជួយខេត្តរតនគិរី និងលោកជំទាវ បានផ្តួចផ្តើមពិធីបុណ្យកឋិនទានដើម្បីប្រមូលបច្ច័យកសាងសមិទ្ធផលនានាក្នុងវត្តសាមគ្គីរតនារាម (វត្តភូមិថ្មី) ស្ថិតនៅភូមិថ្មី សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ។ បច្ច័យដែលទទួលបានសរុបចំនួន ៣២ លានរៀល។ ឯកឧត្តមបានចែកអំណោយដល់សិស្សានុសិស្សចំនួន ៦០ នាក់ ក្នុងម្នាក់ៗសៀវភៅ ២ ក្បាល ប៊ិច ២ ដើម ថវិកា ៥ ពាន់រៀល។ ជូនលោកគ្រូ អ្នកគ្រូ ៥ នាក់ ក្នុងម្នាក់ៗទទួលបាន ៣ ម៉ឺនរៀល និងបាន អញ្ជើញចូលរួមក្នុងពិធីបុណ្យកឋិនទានដែលផ្តួចផ្តើមដោយឯកឧត្តម **ថង សាវុន** អភិបាលនៃគណៈអភិបាលខេត្តរតនគិរី ដើម្បីប្រមូលបច្ច័យកសាងសមិទ្ធផលនានាក្នុងវត្តអារញ្ញរាម ស្ថិតនៅស្រុកលំផាត់ ខេត្តរតនគិរី ។ ឯកឧត្តម **ប៊ូ ថង** បានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំផ្សព្វផ្សាយបូកសរុបលទ្ធផលការងាររយៈពេល ៩ ខែ ឆ្នាំ ២០១៤ និងទិសដៅសម្រាប់អនុវត្តការងារបន្ត នៅសាលប្រជុំគណបក្សខេត្តរតនគិរី ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម **ប៊ូ ឡាំ** តំណាងរាស្ត្រខេត្តរតនគិរី ឯកឧត្តម **មួង ប៉យ** ប្រធានក្រុមប្រឹក្សាខេត្ត និងឯកឧត្តម **ថង សាវុន** អភិបាលនៃគណៈអភិបាលខេត្ត ព្រមទាំងមន្ទីរជុំវិញខេត្ត និងក្រុមការងារថ្នាក់ខេត្តចុះជួយស្រុកទាំង ៩ ។



*ថ្ងៃទី ២០ ខែតុលា ឆ្នាំ ២០១៤ លោក ជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច សមាជិកាគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលបានទទួលជួបសំណេះសំណាលជាមួយកញ្ញា ស៊ន សៀវម៉ី កីឡាការិនីកម្ពុជាដែលទទួលបានជ័យលាភីមេដាយមាសនៅក្នុងការប្រកួតកីឡាអាស៊ីលើកទី ១៧ នៅប្រទេសកូរ៉េ ផ្នែកតេក្វាន់ដូ។ ក្នុងឱកាសនោះ ក្នុងនាមសមាគមនារីដើម្បីសន្តិភាព និងអភិវឌ្ឍន៍ លោកជំទាវបានផ្តល់ថវិកាលើកទឹកចិត្តដល់កញ្ញា ស៊ន សៀវម៉ី ចំនួន ២០០០ ដុល្លារ ។*



ថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៤ ឯកឧត្តម **អ៊ុក រ៉ាប៊ុន** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ បានអញ្ជើញចូលរួមទិវាស្បៀងអាហារពិភពលោកឆ្នាំ ២០១៤ ដែលជាឆ្នាំអន្តរជាតិនៃកសិកម្មជាលក្ខណៈគ្រួសារ ក្រោមប្រធានបទ កសិកម្មជាលក្ខណៈគ្រួសារ ចិញ្ចឹមពិភពលោក និងថែរក្សាភពផែនដី នៅក្នុងបរិវេណសាលាឃុំអូរឬស្សី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង។



*ថ្ងៃទី ២ ខែតុលា ឆ្នាំ២០១៤ ឯកឧត្តម **មិន ឃិន** រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ព្រមទាំងក្រុមហ៊ុនម៉ុងឫទ្ធី និងព្រះសង្ឃ បាននាំយកអំណោយជាគ្រឿងឧបភោគបរិភោគ និងសម្ភារប្រើប្រាស់មួយចំនួន ផ្តល់ជូនបញ្ជាការដ្ឋានទ័ពបញ្ជូនសារ ស្ថិតនៅសង្កាត់កន្ទោក ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ ។*

# សកម្មភាពសមាជិកព្រឹទ្ធសភា_រដ្ឋសភា_រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស



*ថ្ងៃទី១៨ខែតុលាឆ្នាំ២០១៤ឯកឧត្តម **ខងសួត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា សមាជិកគណៈកម្មាធិការកណ្តាលគណបក្ស ប្រជាជនកម្ពុជា បានអញ្ជើញសួរសុខទុក្ខ និងចែកអំណោយដល់កុមារកំព្រានៅបុរីទារក និងកុមារជាតិ នៅភូមិដំណាក់ធំ ៣ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។*

ថ្ងៃទី០៥ ខែតុលា ឆ្នាំ ២០១៤ ឯកឧត្តម **ម៉ម ប៊ុននាង** អនុប្រធានទី ២ គណៈអចិន្ត្រៃយ៍គណៈពង្រឹងមូលដ្ឋានស្រុកកណ្តាលស្ទឹង-ស្រុកគៀនស្វាយ ខេត្តកណ្តាល បានអញ្ជើញជាអធិបតីក្នុងពិធីប្រកាសកែសម្រួល និងតែងតាំងគណៈពង្រឹងមូលដ្ឋានឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ ក្នុងពេលនោះ ឯកឧត្តមបានឧបត្ថម្ភដល់សមាជិកក្រុមការងារពង្រឹងមូលដ្ឋានភូមិទាំង៩ មេឃុំ និងមន្ត្រីប៉ូលីសចំនួន ១២៧ នាក់ ដោយម្នាក់ៗទទួលបានទឹកប្រាក់ចំនួន ២០០០០ រៀល ។ ឯកឧត្តម **ម៉ម ប៊ុននាង** បានបន្តចុះពិនិត្យប្រឡាយរំដោះទឹកមួយកន្លែងនា៣ភូមិគឺភូមិព្រៃករកា ស្ថិតក្នុងឃុំព្រៃករកា ភូមិត្រស់ ស្ថិតក្នុងឃុំទ្រា និងភូមិគោកព្រីង ស្ថិតក្នុងឃុំគោកត្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដោយឯកឧត្តមបានចំណាយថវិកាផ្ទាល់ខ្លួនចំនួន ២០០ ដុល្លារអាមេរិក លើគ្រឿងចក្រកាយប្រឡាយជួយរំដោះទឹកកុំឱ្យទឹកលិច ភូមិ ផ្ទះ និងស្រែចំការរបស់បងប្អូនប្រជាពលរដ្ឋ ។





*ថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៤ ឯកឧត្តម **សុខ ផេង** រដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិកក្រុមការងារគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជាចុះខេត្តតាកែវ បានអញ្ជើញចូលរួមវេទិកាសាធារណៈរវាងថ្នាក់ដឹកនាំខេត្ត ជាមួយមន្ត្រីគ្រប់លំដាប់ថ្នាក់របស់ស្រុកគីរីវង់ ។*

ថ្ងៃទី២ ខែតុលា ឆ្នាំ ២០១៤ ឯកឧត្តម **ម៉ៅ ធនិន** អភិបាលខេត្តពោធិសាត់ បានផ្តល់បណ្ណកម្មសិទ្ធដីធ្លីជូនប្រជាជនចំនួន ៣៥២ គ្រួសារនៅភូមិ បឹងឈូក និងភូមិ បឹងក្រសាំងលើ និងបិទផ្សាយឯកសារទិន្នន័យក្បាលដីនៅភូមិ កំពង់ក្រសាំងក្រោម និងភូមិព្រៃក្តីក្រោម ឃុំកណ្តៀង ស្រុកកណ្តៀង ខេត្តពោធិសាត់។





*នៅថ្ងៃទី៤ខែតុលាឆ្នាំ២០១៤ឯកឧត្តម **សួស យ៉ារ៉ា** អ្នកតំណាងរាស្ត្រមណ្ឌលព្រះវិហារ អញ្ជើញជាអធិបតីចូលរួមប្រារព្ធពិធីស្រង់ព្រះ និងបើកព្រះនេត្រព្រះពុទ្ធរូបចំនួន៣អង្គ ដែលនិមន្តមកតំកល់ក្នុងសាលាឆាន់ ក្នុងវត្តមរតកតេជោបុរីស្វរៈ មានប្រភពពីព្រះអង្គកុកសន្ធោ ព្រះអង្គភ្នំដា និងព្រះអង្គគោកឆ្លកកសាងក្នុងរចនាបថបាយ័ន។*

*ពិធីនេះ មានព្រះសង្ឃនិមន្តមកពីវត្តចំនួន៤ និងមានការអញ្ជើញចូលរួមពីអភិបាលនៃគណៈអភិបាលខេត្តព្រះវិហារប្រធានអាជ្ញាធរជាតិព្រះវិហារអ្នកតំណាងរាស្ត្រខេត្តព្រះវិហារ ក្រុមប្រឹក្សាខេត្ត និងប្រជាពលរដ្ឋប្រមាណ២០០នាក់បានចូលរួមប្រកបដោយក្តីរីករាយ។*



ថ្ងៃទី១៥ ខែតុលា ឆ្នាំ ២០១៤ លោក **កែវ ពិសិដ្ឋ** សមាជិកក្រុមការងារយុវជនគណៈបក្សថ្នាក់កណ្តាលចុះជួយស្រុកពញាក្រែក ទទួលបន្ទុកឃុំពពេលស្រុកពញាក្រែកខេត្តត្បូងឃ្មុំ និងក្រុមការងារស្នាក់ការគណបក្សឃុំពពេល ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ បានអញ្ជើញជាអធិបតីក្នុងពិធីបញ្ចុះបឋមសិលាសាងសង់ស្នាក់ការគណបក្សឃុំពពេលស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ដែលមានបណ្តោយ ១២ ម៉ែត្រ ទទឹង ៩ ម៉ែត្រ កម្ពស់ ៦ ម៉ែត្រ សាងសង់លើបរិវេណដីទំហំ ១៨ គុណនឹង ៣៦ ម៉ែត្រ និងបញ្ចប់ការសាងសង់ក្នុងរយៈពេល ៣ ខែ ។

# លទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច

**ចំណូលពន្ធដារខែកញ្ញា :**

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឲ្យដឹងថា នៅក្នុងខែកញ្ញាឆ្នាំ ២០១៤ នេះ ពន្ធដាររកបានចំណូលពន្ធចំនួនជាង ៣១៧,៨៨ ពាន់លានរៀលឬប្រមាណ ៧៩,៥ លានដុល្លារអាមេរិក។ ចំនួននេះបានបង្ហាញឲ្យឃើញថាមានកំណើន ១០,៨% បើប្រៀបធៀបនឹងចំណូលប្រចាំខែកញ្ញានាឆ្នាំ ២០១៣ ។

ដោយឡែកក្នុងរយៈពេល ៩ ខែ នៃឆ្នាំនេះ ពន្ធដាររកចំណូលបានសរុបស្មើនឹង ៨០,៦% នៃគោលដៅកំណត់ក្នុងច្បាប់ថវិកា ក្នុងនោះថវិការដ្ឋសម្រេចបាន ៨១,៩% និងថវិកាថ្នាក់ក្រោមជាតិសម្រេចបាន ៧២,៥%។ បើប្រៀបធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំ ២០១៣ គឺចំណូល ៩ ខែនៃឆ្នាំ ២០១៤ មានកំណើនស្មើនឹង ១៨,២ %។

បើតាមការវិភាគប្រភេទពន្ធឃើញថា ចំណូលក្នុងឆ្នាំ ២០១៤ មានការកើនឡើងគ្រប់ប្រភេទពន្ធ ក្នុងនោះប្រភេទពន្ធសំខាន់ៗដែលមានការកើនឡើងមានដូចជា ពន្ធលើប្រាក់បៀវត្សរ៍កើនឡើងប្រមាណ ៣០,៦%។ ពន្ធលើប្រាក់ចំណេញកើនឡើងប្រមាណ ២៦,៧%។ អាករលើតម្លៃបន្ថែមកើនឡើងប្រមាណ ១៣,៩% និងអាករពិសេសកើនឡើងប្រមាណ ១០,៩ %។

បើពិនិត្យតាមវិស័យក៏ឃើញថា ចំណូលក្នុងឆ្នាំ ២០១៤ មានការកើនឡើងស្ទើរគ្រប់សកម្មភាព ក្នុងនោះផ្នែកសេវាហិរញ្ញវត្ថុកើនឡើងប្រមាណ ២១,៣%។ ទូរគមនាគមន៍កើនឡើង ៣,៧%។ ផ្នែកស្ថាបត្យកម្ម និងសំណង់កើនឡើង ៦៣,៧%។ ផលិតភេសជ្ជៈកើនឡើង១៧,៣% ។ ផ្នែកផលិតគ្រឿងប្រើប្រាស់កើនឡើង ៣២,៤%។ផ្នែកផលិតសម្លៀកបំពាក់កើនឡើង ៤៥,៣៥%។ នីហរ័ណអាហរ័ណកើនឡើង ១៣,៩%។ ផ្នែកសណ្ឋាគារ ផ្ទះសំណាក់កើនឡើង ៤៦%។ផ្នែកផលិតថ្នាំជក់កើន៣,៨%។ លក់ភេសជ្ជៈកើន៣៣,៦%។ ផលិតម្ហូបអាហារកើនឡើង៧៧,៧%។ផ្នែកលក់សំភារៈការិយាល័យកើនឡើង ៤៣,៣%។ផ្នែកលក់គ្រឿងយន្តកើនឡើង៦០,៩%និងផ្នែកលក់ឱសថកើនឡើង១៨៣,៤%និងគ្រឿងសំណង់ក៏កើនឡើងខ្លាំងរហូតដល់ ១១៥៨,២%។

**ចំនួនយានយន្តចុះបញ្ជីរយៈពេល ៩ ខែ :**



*រថយន្ត និងម៉ូតូដែលចរាចរណ៍លើដងផ្លូវ មានចំនួនកើនឡើងឥតឈប់ឈរ*

នាយកដ្ឋានដឹកជញ្ជូនផ្លូវគោកនៃក្រសួងសាធារណការ និងដឹកជញ្ជូនបានបញ្ជាក់ថា រថយន្ត និងម៉ូតូដែលបានចុះបញ្ជីត្រឹមត្រូវក្នុងរយៈពេល៩ខែឆ្នាំ២០១៤នេះមានចំនួន២៥២០០៦គ្រឿងក្នុងនេះមានរថយន្តចំនួន ៣២ ០១៦ គ្រឿងនិងម៉ូតូចំនួន ២១៩ ៩៩០ គ្រឿង។ ចំនួនយានយន្តដែលបានចុះបញ្ជីនេះ បើប្រៀបធៀបរយៈពេលដូចគ្នានៃឆ្នាំ២០១៣ ឃើញថាមានការកើនឡើងចំនួន២៩៧៦៧ គ្រឿងឬស្មើនឹង១៣,៣៩%។

រយៈពេល ៩ ខែនេះម៉ូតូកើនឡើង២៩១៩២ គ្រឿងស្មើនឹង ១៥,២៩% និងរថយន្តកើនឡើង ៥៧៥ គ្រឿងស្មើនឹង ១,៨២%។

បច្ចុប្បន្ន យានយន្តដែលកំពុងធ្វើចរាចរនៅលើផ្លូវសាធារណៈក្នុងព្រះរាជាណាចក្រកម្ពុជាមានប្រមាណ ២,៧ លានគ្រឿង ក្នុងនេះមានម៉ូតូចំនួន ២,៥ លានគ្រឿង។ តួលេខនេះមិនបានគិតបញ្ចូលយានយន្តដែលបានចុះបញ្ជីនៅក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃនោះទេ។

**ទំហំពាណិជ្ជកម្មកម្ពុជា-អាមេរិករយៈពេល ៨ ខែ :**

យោងតាមតួលេខពីការិយាល័យស្ថិតិពាណិជ្ជកម្មអាមេរិកបានឲ្យដឹងថា ទំនាក់ទំនងពាណិជ្ជកម្មរវាងកម្ពុជា និងអាមេរិកនៅក្នុងរយៈពេល ៨ ខែ ឆ្នាំ ២០១៤ នេះ មានទំហំ ២ ១០៨,៨ លានដុល្លារ គឺមានការកើនឡើងប្រមាណ៦,១៨%ធៀបនឹងរយៈពេលដដែលកាលពីឆ្នាំ២០១៣ដែលមានទំហំទឹកប្រាក់សរុប ១ ៩៨៦ លានដុល្លារ។

ទំហំពាណិជ្ជកម្មសរុបរវាងកម្ពុជា និងអាមេរិកនៅក្នុងរយៈពេលនេះកើនឡើងប្រមាណ ១២២,៨ លានដុល្លារ ក្នុងនោះកំណើននៃការនាំចេញទំនិញកម្ពុជាទៅកាន់អាមេរិកក៏កើន និងទំនិញដែលអាមេរិកនាំចេញមកកាន់ប្រទេសកម្ពុជាវិញ ក៏មានការកើនឡើងផងដែរ។

ការនាំចេញរបស់កម្ពុជាទៅកាន់ទីផ្សារអាមេរិក កើនឡើងប្រមាណ ៥៨,៦ លានដុល្លារ ឬប្រមាណ ៣,២១%។ រយៈពេល ៨ ខែឆ្នាំនេះកម្ពុជានាំចេញទៅអាមេរិកមានតម្លៃ ១ ៨៨៣,៣ លានដុល្លារ ។ រយៈពេលដូចគ្នាកាលពីឆ្នាំ ២០១៣ មានចំនួន ១ ៨២៤,៧ លានដុល្លារ។

ដោយឡែក សម្រាប់ទំនិញដែលអាមេរិកនាំចេញមកកាន់ប្រទេសកម្ពុជាវិញមានកំណើនរហូតដល់ទៅ៣៩,៨៨%។ រយៈពេល ៨ ខែឆ្នាំនេះអាមេរិកនាំចេញមកកាន់កម្ពុជាមានតម្លៃ២២៥,៥លានដុល្លារខណៈដែលនាឆ្នាំទៅមិញក្នុងរយៈពេលដូចគ្នាមានត្រឹមតែ ១៦១,២ លានដុល្លារ ។

រហូតមកដល់ពេលនេះ អាមេរិកគឺជាទីផ្សារនាំចេញដ៏សំខាន់របស់កម្ពុជា។ កាលពីឆ្នាំ ២០១៣ ទំហំពាណិជ្ជកម្មសរុបប្រទេសទាំងពីរមានតម្លៃប្រមាណ ៣ ០១២,៨ លានដុល្លារ ក្នុងនោះទំនិញកម្ពុជានាំចេញមានតម្លៃ ២ ៧៧១,៦ លានដុល្លារ។ ចំណែកទំនិញដែលអាមេរិកនាំចេញមកកាន់កម្ពុជាមានតម្លៃ ២៤១,២ លានដុល្លារ ។

ទំនិញដែលកម្ពុជានាំចេញទៅកាន់ទីផ្សារអាមេរិក មានដូចជា ផលិតផលឧស្សាហកម្មកាត់ដេរ និងស្បែកជើង ផលិតផលកសិកម្ម ដូចជាអង្ករ។ ចំណែកកម្ពុជានាំចូលពីអាមេរិកមកវិញមានដូចជា យានយន្ត គ្រឿងម៉ាស៊ីន ថ្នាំនិងបរិក្ខាពេទ្យ ជាដើម។

**វិស័យធនាគាររយៈពេល ៨ ខែ :**

ធនាគារជាតិនៃកម្ពុជាបញ្ជាក់ថា គិតមកត្រឹមខែសីហាឆ្នាំ ២០១៤ នេះ ទ្រព្យសកម្មនៃធនាគារបានកើនឡើងដល់ប្រមាណ ១៥ ពាន់លានដុល្លារ អាមេរិកគឺកើនឡើងប្រមាណ៧២ដងធៀបនឹង២០ឆ្នាំមុន។ទំហំទឹកប្រាក់បញ្ញើបានកើនឡើងដល់ប្រមាណ ៩ ពាន់លានដុល្លារ ស្មើនឹង១២៨ ដង និងទំហំឥណទានបានកើនឡើងដល់ប្រមាណ ៨ ពាន់លានដុល្លារ ស្មើនឹង ១៣៦ ដង ។ ទ្រព្យសកម្មក្នុងវិស័យធនាគារស្មើនឹងប្រមាណ៩៣%នៃ ផ.ស.ស(ផលិតផលសរុបក្នុងស្រុក)ហើយប្រាក់បញ្ញើស្មើនឹង៥២%និង ឥណទានស្មើនឹង ៤៧%។

រីឯប្រព័ន្ធទូទាត់មានលក្ខណៈទំនើបទាន់សម័យដូចបណ្ដាប្រទេសក្នុង តំបន់ដែរដោយគ្រឹះស្ថានធនាគារទាំងអស់ពង្រីកបណ្ដាញសេវា និងផលិតផលហិរញ្ញវត្ថុរបស់ខ្លួន ដូចជាការកើនឡើងនៃសេវាដកប្រាក់ដោយស្វ័យប្រវត្តិតាមម៉ាស៊ីន ATM ដោយប្រើប័ណ្ណឥណទានពន្ធ និងប័ណ្ណឥណទាន សេវាទូទាត់ដោយម៉ាស៊ីនឆូតកាត(POS) និងសេវាធនាគារតាមទូរស័ព្ទចល័តជាដើម។

គិតត្រឹមខែសីហាឆ្នាំនេះនៅទូទាំងប្រទេស ប្រព័ន្ធធនាគារកម្ពុជាមាន ម៉ាស៊ីន ATM ចំនួន ៨៨៦ កន្លែង ធៀបនឹងឆ្នាំ ២០០៥ មានតែមួយកន្លែងប៉ុណ្ណោះ។ប័ណ្ណឥណទានពន្ធមានចំនួន១,២៣លាន ប័ណ្ណឥណទានមាន ចំនួន ៣០ ម៉ឺន ម៉ាស៊ីនឆូតកាតចំនួន ៥ ៦១៣ និងប៉ុស្ដិ៍សេវាផ្ទេរប្រាក់រឹង មានភ្នាក់ងារចំនួន ១.៩២៧ កន្លែង និងមានចំនួនអ្នកប្រើប្រាស់ប្រមាណ ៥៣ ម៉ឺននាក់។

### វិស័យកាត់ដេររយៈពេល ៩ ខែ ៖

យោងតាមរបាយការណ៍របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្មស្ដីពីសកម្មភាពការងាររយៈពេល ៩ ខែឆ្នាំ ២០១៤ បានបង្ហាញថា តម្លៃសរុបបរិមាណផលិតផលក្នុងរយៈពេល ៩ ខែ មានចំនួន ៤ ៧៣០ លានដុល្លារ អាមេរិក ក្នុងនោះ ឧស្សាហកម្មបម្រើទីផ្សារក្នុងស្រុកមានចំនួន ៧៤០ លានដុល្លារ។ ក្រៅពីនេះគឺជាឧស្សាហកម្មនាំចេញ (កាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងផ្សេងៗ)មានចំនួន ៣ ៩៩០ លានដុល្លារ។ ដូច្នេះតម្លៃសរុបបរិមាណផលិតផលមានកំណើន ១១%ដែលរួមមានចំនួន ១១% សម្រាប់ឧស្សាហកម្មនាំចេញ និង ១១,៥% សម្រាប់បម្រើទីផ្សារក្នុងស្រុក បើធៀបនឹងឆ្នាំ ២០១៣ ក្នុងរយៈពេលដូចគ្នា។

ការចុះបញ្ជីរោងចក្រនៅក្រសួងឧស្សាហកម្ម និងសិប្បកម្មមានចំនួន ១៤៩ រោងចក ស្មើនឹងកំណើន ២១% បើធៀបនឹងឆ្នាំ ២០១៣ ។ ចំនួនរោងចក្រសរុបកើនឡើងដល់ ១ ២៥៧ រោងចក្រ គិតមកត្រឹមខែកញ្ញា ឆ្នាំ ២០១៤។ ក្រៅពីការចុះបញ្ជី ក្រសួងបានផ្ដល់វិញ្ញាបនប័ត្រអនុញ្ញាតឲ្យដំណើការរោងចក្រចំនួន ៥២ បន្តវិញ្ញាបនប័ត្រអនុញ្ញាតឲ្យដំណើការរោង-ចក្រចំនួន ៣៤ ប្ដូរប្រកាសថ្មីចំនួន ៧ ប្ដូរទីតាំងចំនួន ៦ ប្ដូរនាមករណ៍ក្រុម-ហ៊ុនចំនួន ៨ និងទិញភាពជាម្ចាស់គម្រោងតាមរូបភាព (Acquisittion) ចំនួនមួយ ពង្រីកផលិតកម្មចំនួន ៤ និងផ្ទេរភាគហ៊ុនចំនួន ១០ ។

មកដល់ពេលនេះ ពលកម្មសរុបមានចំនួន ៧៦១ ៣០០ នាក់ គឺមានកំណើនរហូតដល់ទៅ ១៧,៣៨%។ ប៉ុន្តែចំពោះចំនួនពលកម្មដែលបានបង្កើតថ្មីក្នុងរយៈពេល ៩ ខែនៃឆ្នាំនេះ រាប់បញ្ចូលទាំងពលកម្មស្ថិតក្នុងគម្រោងផែនការផងនោះ មានចំនួន ៧៥ ១៥៣ នាក់ គឺមានការធ្លាក់ចុះបន្តិចបន្តួច បើប្រៀបធៀបនឹងឆ្នាំ ២០១៣ ក្នុងរយៈពេលដូចគ្នា បើទោះបីជាចំនួនរោងចក្រមានការកើនឡើងក៏ដោយ។ មូលហេតុដោយសារតែរោងចក្រដែលបានបង្កើតថ្មីនាពេលនេះ ជាប្រភេទឧស្សាហកម្មកែច្នៃ ផ្គុំដំឡើង និងម្ហូបអាហារច្រើនជាងឆ្នាំកន្លងទៅ ដែលពុំសូវប្រើប្រាស់កម្លាំងពលកម្មច្រើន។

### ទំហំពាណិជ្ជកម្មកម្ពុជានិងដៃគូរយៈពេល ៨ ខែ ៖

ក្រសួងពាណិជ្ជកម្មអះអាងថា ទំហំពាណិជ្ជកម្មរបស់កម្ពុជាជាមួយនឹងដៃគូគឺការនាំចេញ និងការនាំចូលសរុបរបស់កម្ពុជានៅក្នុងរយៈពេល៨ខែនៃឆ្នាំ ២០១៤ នេះ មានទំហំទឹកប្រាក់ជាង ១២ ពាន់លានដុល្លារអាមេរិក ពោលកើនឡើងជាង ១៥% ធៀបនឹងចំនួនទឹកប្រាក់ជាង១០ពាន់លាន-ដុល្លារ នាឆ្នាំ ២០១៣ ក្នុងរយៈពេលដូចគ្នា។

ការនាំចេញរបស់កម្ពុជាចន្លោះពីខែមករារហូតដល់ខែសីហាមានចំនួនទឹកប្រាក់ជាង ៥ ពាន់លានដុល្លារ មានការកើនឡើងប្រមាណ ១៥% បើធៀបនឹងរយៈពេលដដែលនាឆ្នាំ ២០១៣។ ឆ្នាំ ២០១៣ មានតម្លៃត្រឹមតែ ៤,៥២ ពាន់លានដុល្លារ ។

ដោយឡែកសម្រាប់ការនាំចូលវិញនៅក្នុងរយៈពេល៨ខែឆ្នាំនេះមានទឹកប្រាក់ចំនួន ៦,៩០ ពាន់លានដុល្លារ គឺកើនឡើងប្រមាណ ១៦ % ធៀបនឹងទឹកប្រាក់នៃការនាំចូលដូចគ្នានាឆ្នាំ ២០១៣ ដែលមានតម្លៃត្រឹមតែ ៥,៩៣ ពាន់លានដុល្លារ ។

### អគ្គិសនីរយៈពេល ៨ ខែ ៖

ក្រសួងរ៉ែ និងថាមពលបានបញ្ជាក់ថា ជារួមគិតមកដល់ខែសីហា ឆ្នាំ ២០១៤ នេះ បណ្ដាញផ្គត់ផ្គង់អគ្គិសនីដែលបានអភិវឌ្ឍរួចបានគ្របដណ្ដប់លើភូមិចំនួន ៧ ៧៥៥ ភូមិ ស្មើនឹង ៥៥,១០% នៃចំនួនភូមិសរុបទូទាំងប្រទេស។ ចំពោះការតភ្ជាប់ចរន្តឱ្យអ្នកប្រើប្រាស់ (លំនៅដ្ឋាន សិប្បកម្ម អាជីវកម្ម។ល។)នៅចុងឆ្នាំ ២០១៣ មានតែ ១ ១៧៥ ៦៧៩ តែមកដល់ខែសីហាឆ្នាំនេះបានកើនឡើងដល់ ១ ៣៣៦ ២៤៦។

ដោយឡែក តម្លៃអគ្គិសនីបានថយចុះជាបន្តបន្ទាប់ ហើយនៅពេលឆាប់ៗខាងមុខនេះ តម្លៃអគ្គិសនីនឹងចុះថ្លៃមកក្នុងកម្រិតមួយសមរម្យជាងបច្ចុប្បន្ននៅទូទាំងប្រទេស។

អគ្គិសនីកម្ពុជា កំពុងតែរកមធ្យោបាយបន្តពង្រីកបណ្ដាញបញ្ជូនរងទៅតំបន់ដែលនៅសេសសល់បន្ថែមទៀតលើដែនអាជ្ញាប័ណ្ណផ្គត់ផ្គង់អគ្គិសនីដែលបច្ចុប្បន្នដែលកំពុងគ្របដណ្ដប់លើ១១ ៥៥៧ភូមិស្មើនឹង៨២,១៧% នៃភូមិសរុបទូទាំងប្រទេស។

ក្រសួងរ៉ែនិងថាមពល ក៏បានស្នើសុំការគាំទ្របន្ថែមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនិងដៃគូអភិវឌ្ឍន៍ សម្រាប់សាងសង់ខ្សែបញ្ជូនតង់ស្យុងខ្ពស់មួយចំនួនដែលមានខ្សែតភ្ជាប់ពីខេត្តបាត់ដំបងទៅខេត្តសៀមរាប ពីខេត្តសៀមរាបទៅខេត្តកំពង់ចាម ពីខេត្តក្រចេះទៅខេត្តមណ្ឌលគិរី និងពីខេត្តស្ទឹងត្រែងទៅខេត្តរតនគិរី ដែលមានតម្លៃវិនិយោគសរុបប្រមាណ ២៥០ លានដុល្លារ។

គម្រោងអភិវឌ្ឍន៍វិស័យអគ្គិសនីខាងលើគឺដើម្បីបំពេញសេចក្ដីត្រូវការរបស់ប្រជាជន ជាពិសេសធានាបាននូវតម្លៃអគ្គិសនីមួយសមរម្យ និងមានតម្លៃអគ្គិសនីប្រហាក់ប្រហែលគ្នារវាងទីក្រុង និងជនបទ។ ផែនការវិនិ-យោគលើវិស័យអគ្គិសនីនេះ គ្រោងនឹងបញ្ចប់ការរៀបចំផែនការឱ្យបានមុនដំណាច់ឆ្នាំនេះ៕

# រាជរដ្ឋាភិបាលចាប់ផ្ដើមបង្កើតប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពចំណីអាហារ ឱ្យមានកម្រិតស្ដង់ដារអន្តរជាតិ

ដើម្បីបញ្ចៀសផលប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋដែលជាអ្នកបរិភោគ ឆ្លើយតបទៅនឹងតម្រូវការចាំបាច់ក្នុងបុព្វហេតុការពារសុខភាពប្រជាជន ក្នុងនីតិកាលទី ៥ នេះ រាជរដ្ឋាភិបាលបានជំរុញឱ្យក្រសួងឧស្សាហកម្ម និងសិប្បកម្ម ចាប់ផ្ដើមបង្កើនការផលិតចំណីអាហារប្រកបដោយសុវត្ថិភាពក្នុងកម្រិតស្ដង់ដារអន្តរជាតិ ដោយបង្កើតក្រុមអធិការកិច្ចដើម្បីចុះទៅត្រួតពិនិត្យដល់កន្លែងផលិតផ្ទាល់ តាមសហគ្រាសធុនតូច និងមធ្យមនៅទូទាំងប្រទេស។

ជាក់ស្ដែង ក្រសួងឧស្សាហកម្ម និងសិប្បកម្មបានចាប់ផ្ដើមបណ្ដុះបណ្ដាលគ្រូបង្គោលប្រមាណជាង ៤០ នាក់ មកពីស្ថាប័នពាក់ព័ន្ធ និងសហគ្រាសផលិតចំណីអាហារមួយចំនួន ដើម្បីធ្វើជាអ្នកប្រឹក្សាយោបល់ដល់សហគ្រាសធុនតូច និងមធ្យម ប្រហែលជាង ៥ សែនសហគ្រាសនៅទូទាំងប្រទេស សំដៅឈានទៅអនុវត្តសុវត្ថិភាពចំណីអាហារល្អ ស្របតាមស្ដង់ដារជាតិ និងអន្តរជាតិ។

ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានមានប្រសាសន៍ក្នុងពិធីបើកវគ្គបណ្ដុះបណ្ដាលគ្រូបង្គោលកាលពីពេលថ្មីៗកន្លងមកនេះថា វគ្គបណ្ដុះបណ្ដាលនេះជាជំហានទី ១ ឆ្ពោះទៅរកការគ្រប់គ្រងសុវត្ថិភាពចំណីអាហារនៅគ្រប់សហគ្រាសទាំងអស់នៅទូទាំងប្រទេសឱ្យមានប្រសិទ្ធភាពខ្ពស់ តាមរយៈការគ្រប់គ្រងតាមបែបទំនើប ដោយអ្នកដែលមានគំរូល្អត្រូវបង្រៀនបន្តដល់សហគ្រាសដែលនៅមានភាពទន់ខ្សោយ ហើយជនបង្គោលទាំងនេះនឹងជួយផ្ដល់ប្រឹក្សាយោបល់ដល់គ្រប់សហគ្រាសទាំងអស់ដោយមិនគិតកម្រៃ ដើម្បីធ្វើយ៉ាងណាឱ្យការផលិតចំណីអាហារទាំងអស់ធានាបានគុណភាពល្អ គ្មានជាតិគីមី ហើយអាចប្រកួតប្រជែងបានយ៉ាងពេញលេញ ទាំងនៅទីផ្សារក្នុងស្រុក និងធ្វើការនាំចេញ។

ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានបន្ថែមថា ការលើកកម្ពស់សមត្ថភាពពាក់ព័ន្ធទៅនឹងសុវត្ថិភាពចំណីអាហារ គឺជាកត្តាសំខាន់មិនអាចមើលរំលងបានឡើយ ហើយទាមទារឱ្យមានការចូលរួមដោះស្រាយទាំងអស់គ្នា ដោយគិតចាប់ពីអ្នកដាំ អ្នកចិញ្ចឹម អ្នកកែច្នៃបន្ត អ្នកផលិត អ្នកចែកចាយ អ្នកលក់ដុំ អ្នកលក់រាយ ផ្សារទំនើប និងភោជនីយដ្ឋាន ជាដើម។

ផលិតផលដែលគ្មានសុវត្ថិភាព មានដូចជាការប្រើប្រាស់ថ្នាំកសិកម្មលើសកម្រិតអនុញ្ញាត ការប្រើប្រាស់សារធាតុបន្ថែមលើម្ហូបអាហារមិនត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស ការប្រើមិនសមស្របនូវសារធាតុរក្សាគុណភាពម្ហូបអាហារទុកបានយូរ ការរៀបចំ និងការរក្សាទុកក្នុងឃ្លាំងដោយមិនគោរពតាមតម្រូវការ និង លក្ខខណ្ឌស្ដង់ដារអនាម័យ ។ឯកឧត្តមបានបញ្ជាក់ថាសារធាតុទាំងនេះនឹងបង្កឱ្យ មានគ្រោះថ្នាក់ដល់សុខភាពអ្នកប្រើប្រាស់ ហើយចុងក្រោយបង្កជាជំងឺដម្កាត់ផ្សេងៗ ដែលនាំឱ្យមានការបាត់បង់ជីវិតជាដើម។ គម្រោងបណ្ដុះបណ្ដាលជនបង្គោលពេលនេះត្រូវបានធ្វើឡើងខណៈដែលរាជរដ្ឋាភិបាលបានអនុម័តឱ្យមានស្ដង់ដារជាតិរួមមួយសម្រាប់ត្រួតពិនិត្យសុវត្ថិភាពចំណីអាហារនៅតាមសហគ្រាសធុនតូច និងមធ្យម និងនៅតាមភោជនីយដ្ឋាន ហើយនេះជាជំហានដំបូងនៃការផ្សព្វផ្សាយ ដើម្បីឈានទៅធ្វើការចាប់បង្ខំឱ្យអនុវត្តតាមនាពេលខាងមុខ។

ឯកឧត្តម **ហេង សុខគង់** រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្មបានឱ្យដឹងថា ក្រុមអធិការកិច្ចរបស់ក្រសួងគ្រោងចាប់ផ្ដើមចុះត្រួតពិនិត្យគុណភាពសុវត្ថិភាពចំណីអាហារនៅតាមរោងចក្រ និងសហគ្រាសនៅពេលឆាប់ៗខាងមុខនេះដើម្បីការពារសុខុមាលភាពអ្នកប្រើប្រាស់ ។ ការចុះត្រួតពិនិត្យនេះនឹងអនុវត្តមុនដំបូងគេនៅ





*សហគ្រាសផលិតធំ និងសិប្បកម្មផលិតចំណីអាហារ នៅរាជធានីភ្នំពេញ*




*ចំណីអាហារជាប្រអប់ និងកំប៉ុង ត្រូវបានដាក់លក់នៅតាមហាងនានា*

កន្លែងដែលផលិតកម្មមានហានិភ័យខ្ពស់ជាងគេ ហើយត្រួតពិនិត្យផ្អែកទៅលើប្រពន្ធ័ផលិតកម្មល្អ អនាម័យល្អ និងប្រពន្ធ័គុណភាពចំណីអាហារស្របតាមស្តង់ដារអន្តរជាតិ ។ ក្រុមអធិការកិច្ចនេះមានតួនាទីសំខាន់ណាស់ក្នុងការវាយតម្លៃតាមដានរាល់ខែសង្វាក់ផលិតកម្មរបស់រោងចក្រ សហសគ្រាសឱ្យអនុវត្តទៅតាមគោលការណ៍របស់រាជរដ្ឋាភិបាល ។

គម្រោងចុះត្រួតពិនិត្យសុវត្ថិភាពចំណីអាហារនេះនឹងធ្វើឡើងក្នុងលក្ខណៈទ្រង់ទ្រាយធំនៅទូទាំងប្រទេស បន្ទាប់ពីក្រុមមន្ត្រីអធិការកិច្ចត្រូវបានពង្រឹងសមត្ថភាពបន្ថែម ហើយមានកិច្ចសហការជាមួយក្រសួងពាណិជ្ជកម្ម និងក្រសួងសុខាភិបាល ដើម្បីធានាឱ្យការចុះត្រួតពិនិត្យនេះប្រព្រឹត្តទៅប្រកបដោយជោគជ័យ ។

កម្ពុជាចាំបាច់ណាស់ត្រូវតែអនុវត្តយន្តការនេះឱ្យបានល្អប្រសើរដោយវាមិនត្រឹមតែជួយជំរុញការអភិវឌ្ឍផលិតកម្ម និងទាញយកចំណែកទីផ្សារបានកាន់តែច្រើនប៉ុណ្ណោះទេ ថែមទាំងធ្វើឱ្យអ្នកប្រើប្រាស់មានសុខភាពល្អទៀតផង ។ ក្នុងការចុះត្រួតនិត្យនេះ ក្រុមអធិការកិច្ចត្រូវតែគោរពទៅតាមជំនាញវិជ្ជាជីវៈ និងក្រមសីលធមិ ដើម្បីធានាបាននូវភាពថ្លៃថ្នូរ គ្មានអំពើពុករលួយ រួមជាមួយនឹងការ សម្រេចបានជោគជ័យខ្ពស់ ។

អ្នកជំនាញការអង្គការផលិតភាពអាស៊ី APO ដែលជាអ្នកផ្ដល់បច្ចេកទេសសម្រាប់កម្មវិធីនេះបានឱ្យដឹងថា នេះជាមធ្យោបាយដោះស្រាយដ៏ល្អ សម្រាប់សហគ្រាសធុនតូច និងមធ្យមទាំងអស់នៅកម្ពុជាធានាបាននិរន្តរភាពនៅពេលដែលអាស៊ានធ្វើសមាហរណកម្មនាឆ្នាំ ២០១៥ ខាងមុខ ។



ការផលិតកសិផល ការកែច្នៃ និងការនាំចេញស្បៀងអាហារ បានរួមចំណែកដល់កំណើនសេដ្ឋកិច្ចជាតិឱ្យសម្រេចបានជាមធ្យមប្រមាណ ៧% ក្នុងមួយឆ្នាំ ។ ដូច្នេះការជំរុញការអភិវឌ្ឍវិស័យនេះ គឺជារឿងសំខាន់បំផុតដែលត្រូវគិតគូរចាប់ពីពេលនេះតទៅ ។

សូមបញ្ជាក់ថា សម្រាប់ជំហានទី ២ នៃកម្មវិធីនេះនឹងត្រូវបណ្ដុះបណ្ដាលជនបង្គោលផ្សេងៗទៀតនៅពាក់កណ្ដាលខែកញ្ញា ហើយនឹងឈានទៅផលិតឯកសារបណ្ដុះបណ្ដាលតាមស្ថានីយទូរទស្សន៍ទាំងអស់នៅក្នុងស្រុក ដើម្បីកាន់តែបង្កលក្ខណៈងាយស្រួលដល់ម្ចាស់សហគ្រាសធុនតូច និងមធ្យមទាំងអស់បានសិក្សា និងប្រតិបត្តិតាមគោលការណ៍ត្រឹមត្រូវ ។

គួររំឭកផងដែរថា ការចុះត្រួតពិនិត្យបែបនេះធ្លាប់បានធ្វើឡើងតាំងចាប់ពីឆ្នាំ ២០១០ កន្លងមក ប៉ុន្តែស្ថិតក្នុងទ្រង់ទ្រាយតូច ហើយក៏បាននាំឱ្យមានការបិទសហគ្រាសមួយចំនួនផងដែរដោយការផលិតគ្មានគុណភាព និងធ្វើឱ្យប៉ះពាល់ដល់សុខភាពប្រជាពលរដ្ឋ ក្នុងនោះមានដូចជា សហគ្រាសផលិតសសៃគុយទាវ ទឹកស៊ីអ៊ីវ ទឹកម្ទេស និងរោងចក្រផលិតទឹកកកជាដើម ។/



*ការលក់ដូរចំណីអាហារនៅតាមដងផ្លូវដ៏មានប្រជាប្រិយ*



# ទេសចរណ៍កម្ពុជា ក្នុងចក្ខុវិស័យ នៃដំណាក់កាលរីកចម្រើន



*ភ្ញៀវទេសចរជាតិ-អន្តរជាតិ ចូលទស្សនាប្រាង្គប្រាសាទនានា នៅខេត្តសៀមរាប*

វិស័យទេសចរណ៍នៅកម្ពុជាកំពុងតែមានការរីកចម្រើនជាលំដាប់ ។ ដោយឈរលើសក្ដានុពលទេសចរណ៍ដ៏ទាក់ទាញ ទាំងវប្បធម៌ និងធម្មជាតិដ៏សម្បូរបែប **កម្ពុជាព្រះរាជាណាចក្រអច្ឆរិយៈ** មានតំបន់បេតិកភណ្ឌអង្គរ តំបន់ទេសចរណ៍ឆ្នេរសមុទ្រ តំបន់អេកូទេសចរណ៍ភូមិភាគឦសាន និងតំបន់អេកូទេសចរណ៍ជីវៈចម្រុះបឹងទន្លេសាបដ៏ទាក់ទាញបំផុត ។ ក្រៅពីនេះវិស័យទេសចរណ៍កម្ពុជាក៏កំពុងតែផ្ដោតយ៉ាងខ្លាំងទៅលើទស្សនទានអភិវឌ្ឍន៍បៃតង( គំរូអភិវឌ្ឍន៍ដែលគិតគូរដល់ការអភិរក្ស ថែរក្សាបេតិកភណ្ឌវប្បធម៌ ធនធានធម្មជាតិ និងបរិស្ថានប្រកបដោយនិរន្តរភាព) ដែលមានសារៈសំខាន់ស្របនឹងពេលវេលា និងតម្រូវការបច្ចុប្បន្នក្នុងការធានានិរន្តរភាព ។

បច្ចុប្បន្ននេះ ក្នុងពេលដែលបណ្ដាប្រទេសជិតខាងខ្លះកំពុងជួបវិបត្តិនយោបាយ ប្រទេសកម្ពុជាយើងកំពុងមានសុខសន្តិភាព ស្ថិរភាព ដែលបង្កលក្ខណសម្បត្តិដើម្បីសម្រេចគោលដៅរក្សាឱ្យបាននូវអត្រាកំណើនទេសចរ២ខ្ទង់ ។ក្រសួងទេសចរណ៍បានដាក់ចេញនូវវិធានការ ៨ចំណុច ដើម្បីធ្វើឱ្យគោលដៅនោះសម្រេចបានជោគជ័យ គឺទី ១-ជំរុញបង្កើនការផ្សព្វផ្សាយទេសចរណ៍តាមគ្រប់រូបភាព និងមធ្យោបាយទៅកាន់ទីផ្សារទេសចរណ៍ធំៗដែលមានសក្ដានុពល និងដែលមានលទ្ធភាពតភ្ជាប់ការហោះហើរមកកម្ពុជា ពិសេសទីផ្សារចិន កូរ៉េ ជប៉ុន និងទីផ្សារក្នុងតំបន់អាស៊ាន ទី ២-រៀបចំគោលនយោបាយគន្លឹះចាំបាច់មួយចំនួនដើម្បីបង្កើនជើងហោះហើរពីទីផ្សារទេសចរណ៍ធំៗមកកម្ពុជា ទី ៣-បញ្ចុះតម្លៃកញ្ចប់ទស្សនកិច្ចសម្រាប់ក្នុងមួយរយៈពេល ទី ៤-ជំរុញការបង្កើតព្រឹត្តិការណ៍ និងផលិតផលទេសចរណ៍ទាក់ទាញថ្មីៗ( នៅតំបន់ឆ្នេរ រាជធានីភ្នំពេញ និងតំបន់អេកូទេសចរណ៍ធម្មជាតិ) ទី៥-ជំរុញពង្រឹងគុណភាពសេវាកម្ម និងផលិតផលទេសចរណ៍ ទី ៦-ជំរុញយន្តការសម្រួលការធ្វើដំណើរ និងដឹកជញ្ជូនទេសចរណ៍ ដោយខិតខំបន្តកាត់បន្ថយនូវរបាំងនៃការធ្វើដំណើរមិនចាំបាច់នានា ទី ៧-ជំរុញចលនាទេសចរណ៍ក្នុងស្រុក និងទី ៨-បន្តពង្រឹងសន្តិសុខ និងសុវត្ថិភាពទេសចរណ៍ ។ ទាក់ទងនឹងវិធានការទាំង ៨ ចំណុចនេះ ឯកឧត្តម **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍បានថ្លែងថា ក្រសួងទេសចរណ៍កំពុងអនុវត្តទទួលបានលទ្ធផលល្អដោយបានបង្កើនការផ្សព្វផ្សាយទៅកាន់ទីផ្សារចិន និងបានជំរុញឱ្យមានការហោះហើរបន្ថែមពីទីក្រុងហុងកុងមកកាន់តំបន់សៀមរាប អង្គរ ( បច្ចុប្បន្ននេះមានក្រុមហ៊ុនអាកាសចរណ៍ Dragon Airline ហោះផ្ទាល់ពីទីក្រុងហុងកុងមកខេត្តសៀមរាប ចំនួន ២ ជើងក្នុងមួយសប្ដាហ៍) ព្រមទាំងមានការហោះហើរជាលក្ខណៈអន្តរជាតិដំបូងរបស់ក្រុមហ៊ុនអាកាសចរណ៍ជាតិកម្ពុជាអង្គរអ៉ែរ និងក្រុមហ៊ុនអាកាសចរស្កាយវីងអ៉ែរឡាញ ដែលនឹងធ្វើការហោះហើរទៅមករវាងខេត្តព្រះសីហនុ-សាធារណរដ្ឋប្រជាមានិតចិន និងខេត្តព្រះសីហនុ-សាធារណរដ្ឋកូរ៉េ នៅចុងខែកក្កដា ឆ្នាំ ២០១៤ នេះ ។ ដំណើរការតភ្ជាប់ជើងហោះហើររវាងកម្ពុជា-ជប៉ុនក៏កំពុងមានការវិវឌ្ឍជាវិជ្ជមាន ។ ជាក់ស្តែងក្រុមហ៊ុនអាកាសចរណ៍កម្ពុជាអង្គរអ៉ែរនឹងចាប់ហោះហើរត្រង់ពីខេត្តសៀមរាបទៅកាន់ទីក្រុងតូក្យូ ចាប់ពីចុងខែតុលា ឆ្នាំ ២០១៤ ព្រមជាមួយនឹងការតភ្ជាប់ជើងហោះហើរជាលក្ខណៈ Charter Flights ជាច្រើន ដោយក្រុមហ៊ុនអាកាសចរណ៍កម្ពុជា Skywings Asia Airlines( ៨ ជើង ពីខេត្តសៀមរាបទៅខេត្តផ្សេងៗរបស់ជប៉ុនកាលពីដើមឆ្នាំ ២០១៤ ហើយរក្សាគម្រោងហោះហើរជាបន្តទៀត) ។ ក្រុមហ៊ុនអាកាសចរណ៍ជប៉ុន Japan Airlines (១០ ជើង ពីជប៉ុនមកខេត្តសៀមរាប កាលពីដើមឆ្នាំ ២០១៤ ក្នុងនោះខែមករាមាន៨ជើងនិងខែមីនាមាន២ជើង) ។ក្រុមហ៊ុនអាកាសចរណ៍ Asia Atlantic Airlines ( ២ ជើង ពីតូក្យូមកសៀមរាប ក្នុងខែឧសភា ឆ្នាំ ២០១៤ ហើយ រក្សាគម្រោងហោះហើរជាបន្តទៀត) ។ ក្រុមហ៊ុនទេសចរណ៍ជប៉ុនមួយទៀតឈ្មោះ ANA ក៏គ្រោងនឹងបង្កើតការហោះហើរត្រង់មកកាន់ព្រះរាជាណាចក្រកម្ពុជាផងដែរ ។ ឯកឧត្តម **ថោង ខុន** មានប្រសាសន៍ថា ក្រុមហ៊ុនអាកាសចរណ៍ជប៉ុនដែលហោះហើរត្រង់មកកាន់ប្រទេសកម្ពុជា នឹងជួយបង្កើនចំនួនភ្ញៀវទេសចរជប៉ុនមកកាន់កម្ពុជាឱ្យកាន់តែច្រើន ខណៈដែលមានភ្ញៀវទេសចរជប៉ុនជាង ៤ លាននាក់ បាន



*ភ្ញៀវទេសចរជាតិ-អន្តរជាតិ ចូលទស្សនាប្រាង្គប្រាសាទនានា នៅខេត្តសៀមរាប*



*ភ្ញៀវទេសចរជាតិ-អន្តរជាតិ មុជទឹកកម្សាន្តនៅតំបន់រមណីយដ្ឋានធម្មជាតិបឹងយក្សឡោម ខេត្តរតនគិរី*



*ភ្ញៀវទេសចរជាតិ-អន្តរជាតិ កម្សាន្តនៅតំបន់ឆ្នេរសមុទ្រ ខេត្តព្រះសីហនុ*

មកកម្សាន្តនៅបណ្តាប្រទេសក្នុងតំបន់របស់យើងកន្លងមក តែកម្ពុជាបានស្រូបយកភ្ញៀវទេសចរជប៉ុនបានត្រឹមតែជាង ២០ម៉ឺននាក់ប៉ុណ្ណោះ ។

កំណើនទេសចរណ៍នៅកម្ពុជាមានការកើនឡើងគួរឱ្យកត់សម្គាល់ ដោយក្នុងឆ្នាំ ២០១៣ កម្ពុជាសម្រេចបានកំណើនទេសចរ ១៧,៥% ធៀបនឹងឆ្នាំ ២០១២ ជាមួយនឹងការមកដល់នៃទេសចរណ៍អន្តរជាតិប្រមាណ ៤,២ លាននាក់ ដោយបាននាំមកនូវចំណូលជាតិប្រមាណជាង ២ ៥០០ លានដុល្លារ និងបានផ្តល់ឱកាសការងារដោយផ្ទាល់ប្រមាណជាង ៥០ ម៉ឺន-នាក់ រួមចំណែកប្រមាណជាង ១៥% នៃ GDP ។ តាមការព្យាករណ៍នៅឆ្នាំ ២០១៤ កម្ពុជាអាចទទួលបានទេសចរណ៍អន្តរជាតិប្រមាណ ៤,៦ ទៅ ៤,៧ លាននាក់ ក្នុងឆ្នាំ ២០១៥ អាចទទួលបាន ៥ លាននាក់ និងក្នុងឆ្នាំ ២០២០ អាចទទួល បានពី ៧,៥ ទៅ ៨ លាននាក់ ។ គួរកត់សម្គាល់ថា ក្នុងរយៈពេល ៨ ខែ ដើមឆ្នាំ ២០១៤ នេះ ភ្ញៀវទេសចរអន្តរជាតិមកកម្សាន្តនៅកម្ពុជាមានចំនួន ២ លាន ៩ សែន នាក់ បើប្រៀបរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៣ មានការកើនឡើង ៤,២% ។

ដោយសារកំណើនភ្ញៀវទេសចរចេះតែកើនឡើងជាលំដាប់ការគិតគូរទៅដល់អ្នកបម្រើក្នុងវិស័យទេសចរណ៍កំពុងក្លាយជាប្រធានបទមួយដែលត្រូវយកចិត្តទុកដាក់ ។ បើសិនជាមិនមានធនធានមនុស្សគ្រប់គ្រាន់នោះ វិស័យទេសចរណ៍អាចជួបនឹងវិបត្តិ ។ កម្ពុជាត្រូវការអ្នកបម្រើការក្នុងវិស័យនេះប្រមាណពី ៣ ទៅ ៤ ម៉ឺននាក់បន្ថែមក្នុងមួយឆ្នាំ ហើយតាមការប៉ាន់ស្មានដល់ឆ្នាំ ២០២០ ត្រូវការដល់ទៅ ៨០ ម៉ឺននាក់ ។

ឯកឧត្តម **ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍បានថ្លែងថា ដើម្បីធា-នាឱ្យបានជោគជ័យកាន់តែធំធេងថែមទៀត ក្នុងវិស័យទេសចរណ៍ទាមទារឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងការអភិវឌ្ឍ ការគ្រប់គ្រង និងការធ្វើធុរកិច្ចក្នុងឧស្សាហកម្មទេសចរណ៍ ។ ការចូលរួមនៅទីនេះមិនមែនត្រឹមតែផ្តោតលើផ្នែករដ្ឋដែលជាអ្នកដាក់ចេញយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទេសចរណ៍ប៉ុណ្ណោះទេ ។ ក៏ប៉ុន្តែក៏សំដៅផងដែរដល់តួនាទីរបស់ប្រតិបត្តិករទេសចរណ៍ ព្រមទាំងអ្នកផ្តល់សេវាកម្មនានា ដែលទ្រទ្រង់ដល់វិស័យទេសចរណ៍ បណ្តាដៃគូអភិវឌ្ឍន៍នានា និងប្រជាពលរដ្ឋនៅមូលដ្ឋានផងដែរ ដោយត្រូវផ្សារភ្ជាប់នឹងការទទួលខុសត្រូវខាងផ្នែកបរិស្ថាន ។ ជាមួយគ្នានេះ ក្រសួងទេសចរណ៍ក៏បាន និងកំពុងផ្តោតការយកចិត្តទុកដាក់ថែមទៀតក្នុងការអភិវឌ្ឍផលិតផលទេសចរណ៍ ដូចជា ទេសចរណ៍បែបសហគមន៍ ទេសចរណ៍ជនបទ កសិទេសចរណ៍ និងទេសចរណ៍តាមដង-ទន្លេជាដើម ។/



*ភ្ញៀវទេសចរជាតិ-អន្តរជាតិ មុជទឹកកម្សាន្តនៅតំបន់រមណីយដ្ឋានធម្មជាតិទឹកជ្រោះប៊ូស្រា ខេត្តមណ្ឌលគិរី*



*ភ្ញៀវទេសចរជាតិ-អន្តរជាតិ មុជទឹកកម្សាន្តនៅតំបន់រមណីយដ្ឋានធម្មជាតិទឹកជ្រោះភ្នំគូលែន ខេត្តសៀមរាប*

# វិស័យការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈរួមចំណែកយ៉ាងសំខាន់ ក្នុងការកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយចីរភាព



*ឯកឧត្តម **អ៊ិត សំហេង** ថ្លែងទៅកាន់កម្មករ កម្មការិនី បញ្ជាក់អំពីការខិតខំប្រឹងប្រែងរបស់ក្រសួង ក្នុងការដោះស្រាយសំណូមពរកម្មករ*




*ឯកឧត្តម **អ៊ិត សំហេង** អញ្ជើញជាអធិបតីក្នុងពិធីបើកសិក្ខាសាលាស្ដីពីកិច្ចពិភាក្សាប្ដូរយោបល់លើសេចក្ដីព្រាងច្បាប់ស្ដីពីសហជីព*

រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី ៥ នៃរដ្ឋសភា កំពុងបន្តផ្ដោតការយកចិត្តទុកដាក់យ៉ាងខ្លាំងលើគ្រប់វិស័យ ជាពិសេសវិស័យការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈដោយធ្វើខិតខំធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារបង្កើនឱកាសការងារ បង្កើតបរិយាសការងារ ពង្រឹងភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ និងពង្រឹងការបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈឱ្យសមស្របតាមតម្រូវការទីផ្សារ ការងារសំដៅរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ និងលើកស្ទួយជីវភាពប្រជាជន និងអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព ។ដើម្បីសម្រេចទិសដៅនេះ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈបានដាក់ចេញនូវយុទ្ធសាស្ត្រអាទិភាព ៥ រួមមាន :១-ការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ ២-ការអភិវឌ្ឍការអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ៣-ការអភិវឌ្ឍមុខរបរ និងការងារ ៤-ការអភិវឌ្ឍរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ និង ៥-ការពង្រឹងអភិបាលកិច្ចល្អ ។

អាស្រ័យដោយមានផែនការកម្មវិធីច្បាស់លាស់ ទើបក្នុងរយៈពេល ៦ ខែដើមឆ្នាំ ២០១៤ នេះ ការអភិវឌ្ឍវិស័យការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ។ សកម្មភាពរបស់សហគ្រាសគ្រឹះស្ថានកាត់ដេរទូទាំងរាជធានី ខេត្ត មានចំនួនសរុប ៥២២ មានកម្មករនិយោជិតសរុប ៤៧៧ ៥២១ នាក់ ក្នុងនោះ ស្រីមាន ២៨០ ៨២៨ នាក់ សហគ្រាស គ្រឹះស្ថានក្រៅពីកាត់ដេរមានចំនួនសរុប ៥ ២៥៤ មានកម្មករនិយោជិតសរុប ២០៦ ២៨២ នាក់ ក្នុងនោះ ស្រីមាន ៩៦ ២៩៦ នាក់ ។ សហគ្រាសគ្រឹះស្ថានបើកថ្មីក្នុងឆមាសទី ១ នេះ មាន ៥៩ មានកម្មករនិយោជិត ១២ ៥៦៧ នាក់ ក្នុងនោះ ស្រីមាន ៨ ៨៧៨ នាក់ ។ សហគ្រាសគ្រឹះស្ថានបិទលែងដំណើរការមាន ១៥ មានកម្មករ និយោជិតរងការប៉ះពាល់មាន ៨ ៤០៥ នាក់ ក្នុងនោះ ស្រីមាន ៣៦២៩ នាក់ ។ សហគ្រាសគ្រឹះស្ថានព្យួរការងារមានចំនួន ៣ កម្មករ និយោជិតរងផលប៉ះពាល់មាន ១៦៦៥ នាក់ ក្នុងនោះស្រីមាន ១២០ នាក់ ។ ចំពោះការងារគ្រប់គ្រង និងបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសក្នុងឆមាសទី ១ នេះ តាមរយៈទីភ្នាក់ងារជ្រើសរើសឯកជនចំនួន ២៨ ក្រសួង បានបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសសរុបចំនួន ៦៨៣០ នាក់ ក្នុងនោះស្រីមាន ២៧២៣ នាក់ ។ គួរបញ្ជាក់ថា មកដល់ពេលនេះ (ខែតុលា ឆ្នាំ ២០១៤) មានពលករកម្ពុជាសរុបចំនួនជាង ៣០ ម៉ឺននាក់បានកំពុងធ្វើការនៅតាមប្រទេសចំនួន ៥ ក្នុងនោះ មានប្រទេសថៃ ២៧ ម៉ឺននាក់ សាធារណរដ្ឋកូរ៉េជាង ៣៤ ម៉ឺននាក់ ម៉ាឡេស៊ីជាង ១ ម៉ឺននាក់ ជប៉ុនជិត ១ ពាន់នាក់ និងសិង្ហបុរីប្រមាណជាង ៤០០ នាក់ ។

ឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈបានថ្លែងថា ក្នុងចំនួនពលករជាង ៣០ ម៉ឺននាក់នេះ មួយឆ្នាំៗ គេរកប្រាក់ចំណូលផ្ញើមកឱ្យក្រុមគ្រួសារមានជាង ៣០០ លានដុល្លារ ។ ទឹកប្រាក់នេះបានជួយដល់ក្រុមគ្រួសាររបស់ពួកគេមានកម្រិតជីវភាពរស់នៅកាន់តែល្អប្រសើរ ហេតុនេះហើយទើបរាជរដ្ឋាភិបាលយើងយកចិត្តទុកដាក់ខ្លាំងណាស់ចំពោះពលករដែលទៅធ្វើការនៅក្រៅប្រទេស ។ ដោយឡែកគិតមកដល់ដើមខែកញ្ញាឆ្នាំ២០១៤ពលករបរទេសមកសុំបែបបទការងារនៅក្រសួងការងារមានចំនួនជិត ១ ម៉ឺននាក់ កើនឡើង ៣០% បើធៀបនឹងឆ្នាំ ២០១៤ មានតែ ៨ ពាន់នាក់ប៉ុណ្ណោះ ។ ក្រសួងបានខិតខំក្នុង



*ឧស្សាហកម្មកាត់ដេរ និងផលិតស្បែកជើង បានផ្ដល់ការងារដល់ពលករកម្ពុជាជិត ៧ សែននាក់*



ការបណ្តុះបណ្តាលវិជ្ជាជីវៈត្បាញកន្ទេល



វិជ្ជាជីវៈតម្បាញ បង្កើតជាការងារ ដោយមិនបាច់ធ្វើចំណាកស្រុក

ការទប់ស្កាត់ការប្រើប្រាស់កម្លាំងពលកម្មកុមារ ដោយបានចុះធ្វើអធិការកិច្ចការងារសាមញ្ញបាន៥៦៦លើករកឃើញសហគ្រាសប្រើប្រាស់ពលកម្មកុមារចំនួន ២៥ ហើយបានជួយសង្គ្រោះកុមារ ៨៩៩៣ នាក់។ ចុះធ្វើអធិការកិច្ចពេទ្យការងារសរុបចំនួន ៥១៩ លើក នៅតាមរោងចក្រ សហគ្រាស គ្រឹះស្ថានសរុប ៦០៦ កន្លែង ដោយបានផ្តល់ដំបូន្មានអំពីអនាម័យ និងសុវត្ថិសុខការងារ និងសេវាពេទ្យការងារដល់ម្ចាស់រោងចក្រ សហគ្រាស គ្រឹះស្ថាន រោងសិប្បកម្មដែលពុំទាន់មានលក្ខខណ្ឌស្តង់ដារអនាម័យ និងសុវត្ថិភាពការងារនៅកន្លែងធ្វើការ ។ ក្រសួងបានយកចិត្តទុកដាក់អនុវត្តយ៉ាងខ្ជាប់ខ្ជួនរបបធានារ៉ាប់រង ហានិភ័យការងារ។

ចាប់តាំងពីដំណើរការដំបូងនាខែវិច្ឆិកាឆ្នាំ ២០០៨ រហូតមកដល់ឆមាសទី២ ឆ្នាំ២០១៤ នេះ បេឡាជាតិរបបសន្តិសុខសង្គមបានចុះ បញ្ជិកាសហគ្រាស គ្រឹះស្ថានសរុបចំនួន ៦៥៧៧ មានកម្មករនិយោជិតចំនួន ៨៦៨២៨៨ នាក់។ ដោយឡែកសម្រាប់ឆមាសទី១ ឆ្នាំ២០១៤ នេះ បេឡាជាតិរបបសន្តិសុខសង្គមបានទទួលចុះបញ្ជិកាសហគ្រាស គ្រឹះស្ថានចំនួន ៥៧៨ មានកម្មករនិយោជិតចំនួន ២៦ ៣៣៥ នាក់។ ចំពោះហានិយភ័យការងារសម្រាប់ឆមាសទី ១ នេះ បេឡាជាតិរបបសន្តិសុខសង្គមបានទទួលរបាយការណ៍ហានិភ័យការងារពីបណ្តាសហគ្រាស គ្រឹះស្ថានតាមបណ្តារាជធានី ខេត្ត នៅទូទាំងប្រទេសចំនួន ៨០៧២ ករណី មានកម្មករ និយោជិតចំនួន ៩៣៦៧ នាក់ក្នុងនោះស្រីចំនួន ៦៨៤០ នាក់។ តាមរយៈលទ្ធផលនៃការអង្កេតមានគ្រោះថ្នាក់ការងារចំនួន ៨៧៣៤ នាក់ ក្នុងនោះគ្រោះថ្នាក់កន្លែងធ្វើការមាន ៦២០០ នាក់ និងគ្រោះថ្នាក់ពេលធ្វើដំណើរមាន ២៥៣៤ នាក់។ ចំពោះកម្រិតនៃរបួសវិញ មានរបួសស្រាលចំនួន៧៩៣៨នាក់ របួសធ្ងន់៧៥០នាក់និងស្លាប់៤៦នាក់។ ករណីនិយោជិតដួលសន្លប់ក្នុងឆមាសទី ១ ឆ្នាំ ២០១៤ កើតមាននៅ ១៤ សហគ្រាស កម្មករ និយោជិតដួលសន្លប់មាន ៨០៦ នាក់ ក្នុងនោះស្រីមាន ៨០៤ នាក់ បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៣ មានតែ ៦ សហគ្រាស ឯកម្មករដួលសន្លប់មាន ៣៩៨ នាក់។ ទាក់ទិននឹងបញ្ហានេះ ទាមទារតម្រូវឱ្យមានការកែសម្រួលលក្ខខណ្ឌនៅក្នុងសហគ្រាសរោងចក្រមួយចំនួន ពីព្រោះថាមានមូលហេតុសំខាន់ដែលធ្វើឱ្យប៉ះពាល់ដល់សុខភាពកម្មករ ដូចជា បរិយាកាសក្នុងរោងចក្រមិនល្អ កម្តៅឡើងខ្លាំង ខ្វះខ្យល់ចេញចូលគ្រប់គ្រាន់ សារជាតិគីមី កម្មករធ្វើការថែមម៉ោងច្រើន។ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានបង្កើតគណៈកម្មការទប់ស្កាត់ និងស្រាវជ្រាវការដួលសន្លប់របស់កម្មកររោងចក្រតាំងពីឆ្នាំ ២០១១ ហើយមន្ត្រីអធិការកិច្ចបានចុះធ្វើការត្រួតពិនិត្យសហគ្រាស គ្រឹះស្ថានការងារ និងរោងចក្រកាត់ដេរជាប្រចាំ។ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានធ្វើការព្រមានចាត់វិធានការតាមផ្លូវច្បាប់ចំពោះរោងចក្រសហគ្រាសណាដែលនៅតែមានកម្មករដួលសន្លប់ដដែលជាដដែល។

ក្រសួងក៏បានដាក់ចេញផែនការមេលើកទី ២ ឆ្នាំ ២០១៤-២០១៨ ដើម្បីធ្វើឱ្យសុខភាព និងសុវត្ថិភាពការងារនៅតាមរោងចក្រសហគ្រាសនានាកាន់តែមានលក្ខណៈល្អប្រសើរ។ ផែនការមេនេះ មានកម្មវិធីអាទិភាពចំនួន៦រួមមានទី១-ជំរុញការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិសុខភាព និងសុវត្ថិភាពការងារ ទី២-កែលម្អការធ្វើអធិការកិច្ចស្តីពីសុខភាព និងសុវត្ថិភាពការងារ ទី៣-ពង្រឹងរបាយការណ៍ប្រព័ន្ធគ្រោះថ្នាក់ការងារ និងវិជ្ជាជីវៈ ទី៤-ពង្រឹងកម្មវិធីបណ្តុះបណ្តាលសុខភាព និងសុវត្ថិភាពការងារថ្នាក់ជាតិ ទី៥-ពង្រីកការការពារផ្នែកសុខភាព និងសុវត្ថិភាពការងារទៅដល់សហគ្រាសខ្នាតតូច មធ្យម និងសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងទី៦-អនុវត្តកម្មវិធីពិសេសគ្រប់គ្រងមុខរបរងាយគ្រោះថ្នាក់ លុបបំបាត់ពលកម្មកុមារ និងកម្មវិធីបង្ការជំងឺអេដស៍នៅកន្លែងធ្វើការ។

ក្នុងឆមាសទី ១ ឆ្នាំ ២០១៤ នេះដែរ ក្នុងស្ថានភាពដែលបញ្ហានយោបាយមិនសូវល្អដោយសារតែគណបក្សប្រឆាំងញុះញង់បង្កឱ្យមានចលាចលក្នុងសង្គម ក៏មានការកើតឡើងនូវបាតុកម្ម កូដកម្ម ក្នុងចំណោមកម្មករផងដែរ។ កូដកម្មកើតមានចំនួន ១៣៤ លើក ក្នុងនោះ រាជធានីមាន ៨៨ លើក ចំនួនកូដករចូលរួម ៦៦៩៥៨ នាក់ ក្នុងនោះ រាជធានីភ្នំពេញមាន ៤០៨៨៧ នាក់។ បាតុកម្មកើតមានចំនួន ១៤ ករណី ក្នុងនោះ រាជធានីមាន ៩ ករណី ចំនួនបាតុករសរុប ១០៩១៧ នាក់ ក្នុងនោះរាជធានីមាន ៧៨១៧ នាក់។

ទោះបីជាមានការខិតខំប្រឹងប្រែងក្នុងការជំរុញអនុវត្តវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានលទ្ធផលដ៏ច្រើនបែបនេះក្តី ក៏នៅមានបញ្ហាប្រឈមជាច្រើនដែលត្រូវដោះស្រាយនៅក្នុងការបន្តដំណើរការនៃការអភិវឌ្ឍរបស់យើង។ បញ្ហាប្រឈមទាំងនោះដូចជាការអនុវត្តច្បាប់ស្តីពីការងារមិនទាន់មានប្រសិទ្ធភាពខ្ពស់ ករណីកូដកម្ម បាតុកម្ម និងការរំលោភបំពានច្បាប់កើតឡើងជាបន្តបន្ទាប់ លក្ខខណ្ឌការងាររបស់កម្មករ

និយោជិតនៅមានកម្រិត ការអនុវត្តសេរីភាពអង្គការវិជ្ជាជីវៈនៅខ្វះភាពទទួលខុសត្រូវមិនទាន់ស្របទៅតាមបទដ្ឋានគតិយុត្តិ ក្រមសីលធម៌វិជ្ជាជីវៈនិងមិនបម្រើផលប្រយោជន៍របស់កម្មករ និយោជិត និងសមាជិករបស់ខ្លួនពិតប្រាកដ ការផ្ដល់សេវាការងារ និងព័ត៌មានទីផ្សារការងារនៅមិនទាន់គ្រប់ដណ្ដប់បានទូលំទូលាយនៅឡើយ ការគ្រប់គ្រងពលករខ្មែរក្នុង និងក្រៅប្រទេស និងការរៀបចំបទដ្ឋានការងារ និងការគ្រប់គ្រងកម្លាំងពលកម្មបរទេសនៅមានចំណុចខ្វះចន្លោះ ការអប់រំបណ្ដុះបណ្ដាលបច្ចេកទេសវិជ្ជាជីវៈពុំមានភាពស៊ីចង្វាក់គ្នាល្អរវាងការបណ្ដុះបណ្ដាលជំនាញ និងតម្រូវការទីផ្សារ ការចូលរួមរបស់ផ្នែកឯកជនលើវិស័យអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈនៅទាប ការអនុវត្តរបបសន្តិសុខសង្គមមិនទាន់បានពេញលេញ ។ ទោះជាយ៉ាងនេះក្ដី ក៏បញ្ហាប្រឈមទាំងនេះមិនមែនជាឧបសគ្គដែលអាចរាំងស្ទះមិនឱ្យវិស័យការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈបន្តឈានទៅមុខនោះទេ ។

ក្នុងឆ្នាំ២០១៤ នេះ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈបានដាក់ចេញផែនការសកម្មភាពជាច្រើនដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនោះទៅតាមដំណាក់កាលនីមួយៗ នោះគឺបន្តលើកកម្ពស់លក្ខខណ្ឌការងារឱ្យកាន់តែប្រសើរឡើង ពង្រឹងយន្តការដោះស្រាយវិវាទការងាររួមតាំងពីពេលចាប់ផ្ដើមមានវិវាទរហូតដល់ករណីវិវាទ ត្រូវបានប្ដឹងទៅក្រុមប្រឹក្សាអាជ្ញាកណ្ដាល ។ ពង្រឹងនិងពង្រីកសេរីភាពសហជីព អង្គការវិជ្ជាជីវៈ និងបន្តជំរុញបញ្ចប់ការកសាងសេចក្ដីព្រាងច្បាប់ស្ដីពីសហជីព និងសិក្សាស្រាវជ្រាវសម្រាប់បង្កើតយន្តការក្នុងការបង្កើតតុលាការការងារ ។ ទប់ស្កាត់ឱ្យបានការប្រើប្រាស់កម្លាំងពលកម្មកុមារ ។

ក្រសួងការងារក៏បានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើប្រាក់ឈ្នួលរបស់កម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើង ដោយតែងបានជួបពិភាក្សាជាមួយតំណាងសហជីព តំណាងរោងចក្រ និងផ្នែកពាក់ព័ន្ធទាំងឡាយ ដើម្បីរកវិធីដោះស្រាយដោយអាចទទួលយកបានទាំងអស់គ្នា ។ ប៉ុន្តែរាល់លើកគេសង្កេតឃើញថាមានភាគីខ្លះមានចេតនាឆ្លៀតយកបញ្ហាទៅបម្រើឱ្យផលប្រយោជន៍ផ្ទាល់ខ្លួន ឬក៏ផលប្រយោជន៍នយោបាយ មិនបម្រើឱ្យផលប្រយោជន៍ពិតរបស់កម្មករ ទើបក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈបានណែនាំដល់ក្រុមចរចាទាំងអស់ឱ្យគោរពក្រមសីលធម៌ ៦ ចំណុចរបស់ក្រសួង ក្នុងពេលចរចាតទៅមុខទៀត ។

ដោយឡែក ទាក់ទងនឹងការអនុវត្តកម្មវិធីរោងចក្រកាន់តែល្អប្រសើរ យោងតាមរបាយការណ៍តម្លាភាពទី ៣ របស់អង្គការអន្តរជាតិខាងការងារ (ILO)ដែលបានចេញផ្សាយនៅថ្ងៃទី ២១ ខែតុលា បានបង្ហាញថា លក្ខខណ្ឌការងារនៅក្នុងរោងចក្រកាត់ដេរមានលក្ខណៈល្អប្រសើរជាងមុន ប៉ុន្តែការធ្វើកូដកម្ម និងបាតុកម្មរបស់សហជីពកម្មករ នៅតែមិនគោរពតាមនីតិវិធីច្បាប់ទាល់តែសោះ ។ ការហ៊ឹកហាត់ជម្លៀសចេញពីអគារពេលមានអាសន្នបានកើនឡើង ខណៈដែលការរើសអើងកម្មករនិយោជិតពីសំណាក់រោងចក្រមានការថយចុះ ។ ការផ្ដល់ប្រាក់រង្វាន់បន្ថែមដល់កម្មករដែលមានអតីតភាពការងារត្រឹមត្រូវ ក៏បានកើនឡើងលើសពីមុន ។ បញ្ហាជាច្រើនដែលរោងចក្រមិនបានកែប្រែអស់រយៈពេលជាច្រើនឆ្នាំមកហើយនោះ ឥឡូវនេះបានកែលម្អហើយ ។ ការសិក្សាបានរកឃើញថា ការអនុវតច្បាប់របស់សហជីពកម្មករនៅមានកម្រិតទាប ។ គ្រប់កូដកម្មទាំងអស់ដែលត្រូវបានរួមបញ្ចូលនៅក្នុងទិន្នន័យតម្លាភាពនៅខែតុលាឆ្នាំ ២០១៤ នេះ គ្មានកូដកម្មណាមួយដែលធ្វើឡើងនៅក្នុងរោងចក្របានគោរពនីតិវិធី និងតម្រូវការរបស់ច្បាប់ទេ ។

ប្រទេសកម្ពុជាជាប្រទេសមួយដែលមានកម្លាំងពលកម្មវ័យក្មេងច្រើនជាងគេនៅក្នុងតំបន់ដោយបច្ចុប្បន្ន មានសរុបប្រមាណជាង ៧ លាននាក់ ។ កម្ពុជាមិនមានបញ្ហាកង្វះកម្លាំងពលកម្ម ឬប្រឈមជាមួយកត្តាសង្គមដែលមានមនុស្សចាស់ច្រើនដូចប្រទេសអភិវឌ្ឍន៍មួយចំនួននោះទេ ។ ឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និង បណ្ដុះបណ្ដាលវិជ្ជាជីវៈ បានថ្លែងថា តាមស្ថិតិជំរឿនប្រជាសាស្ត្របានបង្ហាញថា យុវជនអាយុពី ១៥ ដល់ ២៩ ឆ្នាំ មានចំនួន ២២,៥% អាយុ ពី ២៥ ដល់ ៣៤ ឆ្នាំមាន ១៧,៧% អាយុពី ៣៥ ដល់ ៦៤ ឆ្នាំ មាន ២៥,៤% ។ ចំនួននេះ បើធៀបជាមួយបណ្ដាប្រទេសក្នុងតំបន់ឃើញថា កម្ពុជាមានអត្រាយុវជនពេញកម្លាំងចន្លោះពីអាយុ ១៥ ដល់ ២៤ ឆ្នាំ ច្រើនជាងគេគឺរហូតដល់ ៣២% ។ នៅឥណ្ឌូនេស៊ីមាន ១៨% ថៃមាន ១៣% និងវៀតណាមមាន១៩% ។ ប្រជាជនកម្ពុជាដែលឈានដល់អាយុបំពេញការងារ មានប្រមាណចន្លោះពី ២៥០០០០ ទៅ ៣០០០០០ នាក់ រួមជាមួយនឹងកំណើនប្រជាជនប្រមាណជាង ២ សែននាក់ ក្នុង ១ ឆ្នាំ ។

បើតាមការព្យាករណ៍កំណើនប្រជាជនកម្ពុជា និងមានសភាពថេរ គិតចាប់ពីពេលនេះ រហូតដល់ឆ្នាំ ២០៥០ ។ ដូច្នេះបញ្ជាក់ថា កម្ពុជាមិនមានបញ្ហាកង្វះកម្លាំងពលកម្ម ឬប្រឈមជាមួយកត្តាសង្គមដែលមានមនុស្សវ័យចាស់ច្រើនដូចប្រទេសអភិវឌ្ឍន៍មួយចំនួននោះទេ ។ ឯកឧត្តម **អ៊ិត សំហេង** បានជំរុញឱ្យយុវជនយើងត្រៀមខ្លួន តាមរយៈការអប់រំ និងកសាងសមត្ថភាពឱ្យបានពេញលេញ ស្របតាមមុខវិជ្ជាឯកទេសទាំងអស់ ដែលមានតម្រូវការចាំបាច់នៅពេលធ្វើសមាហរណកម្មអាស៊ាន ដើម្បីមានលទ្ធភាពប្រកួតប្រជែងខ្ពស់ក្នុងការចាប់យកឱកាសការងារទាំងក្នុង និងក្រៅប្រទេស ពិសេសត្រូវចេះប្រែក្លាយបញ្ហាប្រឈមទាំងអស់ឱ្យទៅជាឱកាសដ៏សម្បូរបែបនៅក្នុងដំណាក់កាលនៃការធ្វើសមាហរណកម្មនេះ ។

ការអនុវត្តការងារឆមាសទី ៤ នៃឆ្នាំ ២០១៤ ដែលជាឆ្នាំដំបូងនៃការចាប់ផ្ដើមការអនុវត្តតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈឆ្នាំ២០១៤-២០១៨ បានសម្រេចនូវសមិទ្ធផលយ៉ាងច្រើន នោះក៏អាស្រ័យដោយក្រសួងបានអនុវត្តផែនការទាំងឡាយរបស់ខ្លួន ដែលមានភាពទន់ភ្លន់បត់បែនទៅតាមសភាពការណ៍និងស្ថានភាពជាក់ស្ដែង ។ ជោគជ័យនេះ គឺជាផ្នែកមួយនៅក្នុងចំណោមជោគជ័យទាំងឡាយ ដែលសម្រេចបានក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាព នៅកម្ពុជារបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី ៥ នៃរដ្ឋសភា ជាពិសេសនៅក្នុងចតុកោណទី ៣ ស្ដីអំពីការអភិវឌ្ឍន៍វិស័យឯកជន និងការងារ និងចតុកោណទី ៤ ស្ដីអំពីការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស ។/

# អភិរក្ស និងអភិវឌ្ឍបេតិកភណ្ឌវប្បធម៌ជាតិ ដើម្បីចូលរួមអភិវឌ្ឍសេដ្ឋកិច្ចសង្គម



*ប្រាសាទព្រះវិហារដែលត្រូវបានដាក់បញ្ចូលជាសម្បត្តិបេតិកភណ្ឌពិភពលោក*

## សារៈសំខាន់នៃវប្បធម៌សម្រាប់គោលដៅទេសចរណ៍

រាជរដ្ឋាភិបាលបាន និងកំពុងបន្តជំរុញកិច្ចខិតខំប្រឹងប្រែង អភិវឌ្ឍវិស័យសំខាន់ៗជាច្រើន ដើម្បីជួយទ្រទ្រង់ ដល់ការអភិវឌ្ឍលើវិស័យទេសចរណ៍ ។ ជាអាទិ៍ការទាញយកផលប្រយោជន៍ពីចរន្តតំបន់ភាវូបនីយកម្ម និងសាកលភាវូបនីយកម្មវិស័យវប្បធម៌ ការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់ និងលើសកលលោក និង ការប្រើប្រាស់សក្តានុពលនៃសម្បត្តិបេតិកភណ្ឌវប្បធម៌ ដើម្បីទាក់ទាញទេសចរណ៍វប្បធម៌។

ទេសចរណ៍វប្បធម៌ កំពុងដើរតួនាទីកាន់តែសំខាន់ឡើងៗ ក្នុងការអភិវឌ្ឍសង្គម និងកាត់បន្ថយនូវភាពក្រីក្រ តាមរយៈការផ្តល់ឱកាសការងារ និងចំណូលដល់ប្រជាពលរដ្ឋក្នុងសហគមន៍មូលដ្ឋាន។ ទន្ទឹមនេះ ទេសចរណ៍វប្បធម៌ក៏បាន និងកំពុងចូលរួមថែរក្សាការពារសម្បត្តិវប្បធម៌ធនធានធម្មជាតិ និងបរិស្ថានសហគមន៍ឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀតផងដែរ ។

ក្នុងបរិការណ៍នេះរាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកថា សម្បត្តិវប្បធម៌គឺជា ចលករដ៏មានសារៈសំខាន់ ហើយមានទំនាក់ទំនងជិតស្និទ្ធជាមួយផ្នែកពាក់ព័ន្ធផ្សេងៗ ក្នុងទម្រង់យុទ្ធសាស្ត្ររួមមួយសម្រាប់ការ អភិវឌ្ឍប្រទេសជាតិ។

ការភិរក្ស និងអភិវឌ្ឍវប្បធម៌ជាតិ ជាការរួមចំណែកយ៉ាងសំខាន់ដល់ការអនុវត្តយុទ្ធសាស្ត្រផ្សព្វផ្សាយទេសចរណ៍ តាមរយៈការពង្រឹង និងបង្កើតជាផលិតផលឧស្សាហកម្មវប្បធម៌។ នេះជាដំណាក់កាលឈានទៅរកការអភិវឌ្ឍគោលដៅទេសចរណ៍ដោយផ្អែកលើគ្រឹះវប្បធម៌ជាតិ។

ការផ្ទេរចំណេះជំនាញពីជំនាន់មួយទៅជំនាន់មួយ នៅក្នុងសេចក្តីប្រកាសជារួមមួយរបស់អង្គការយូណេស្កូស្តីពីការការពារ និងលើកស្ទួយភាពផ្សេងគ្នានៃវិញ្ញត្តិវប្បធម៌ ដែលកម្ពុជាបានផ្តល់សច្ចាប័នបានចែងថា វប្បធម៌សំដៅលើលក្ខណៈដ៏សំខាន់ខាងផ្នែកផ្លូវចិត្ត សម្ភារៈ បញ្ញា និងអារម្មណ៍របស់មនុស្ស ក្រុមមនុស្ស សង្គម ឬសហគមន៍ ដែលបានឆ្លុះបញ្ចាំងតាមរយៈអក្សរសាស្ត្រ សិល្បៈ វប្បធម៌ របៀបរស់នៅ ប្រព័ន្ធនៃការគ្រប់គ្រងសង្គម រួមទាំងប្រពៃណី និងជំនឿ។ អត្តសញ្ញាណជាតិ និងភាពផ្សេងៗគ្នានៃវប្បធម៌គឺជាប្រភពដ៏សម្បូរបែបរបស់កម្ពុជា បើនិយាយរួម គេអាចថែរក្សាទម្រង់វប្បធម៌ប្រពៃណីទាំងនោះបាន លុះត្រាតែគេអភិរក្សបាននូវចំណេះដឹងតាមលក្ខណៈប្រពៃណីទាំងនោះ និងធានាបានការផ្ទេរចំណេះដឹងទាំងនោះ ទៅអ្នកជំនាន់ក្រោយៗ ដោយសម្តែងបង្ហាញការផ្សព្វផ្សាយ និងការចែកចាយឲ្យ ដល់សាធារណជនបានស្គាល់ ។ ម៉្យាងទៀតអត្តសញ្ញាណវប្បធម៌អាចទទួលបាននូវការថែរក្សាលុះត្រាតែមានការចូលរួមប្រតិបត្តិ ពីសំណាក់យុវជនជំនាន់ក្រោយ



*របាំអប្សរាជារបាំមួយក្នុងចំណោមទម្រង់របាំក្បាច់បុរាណខ្មែរជាបេតិកភណ្ឌវប្បធម៌អរូបី*

ដោយហេតុថា សព្វថ្ងៃនេះ បច្ចេកវិទ្យាបានសម្រួលភ្ជាប់ទំនាក់ទំនង និងជំរុញឲ្យមានការផ្លាស់ប្តូរយ៉ាងលឿន ដែលធ្វើឲ្យយុវជន មានការថ្លឹងថ្លែងរវាងអត្តសញ្ញាណវប្បធម៌ប្រពៃណីពីបុរាណ ជាមួយនិងការបង្កើតគំនិតថ្មី ដោយភាពទាន់សម័យ ព្រមទាំងការបើកចំហទៅរកបរិបទថ្មី ដោយការប្រើប្រាស់របៀបទំនាក់ទំនងថ្មី។

## កិច្ចសហការដើម្បីទ្រទ្រង់ឧស្សាហកម្មច្នៃប្រឌិតរបស់សហគមន៍



*ការជួសជុលប្រាសាទស្ពព៌ត្រ*

ក្រសួងវប្បធម៌ជាមួយ និង ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ក្រសួងពាណិជ្ជកម្ម និងក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល បានធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការ UNESCO UNDP ILO FAO ដើម្បីអនុវត្តកម្មវិធីគាំទ្រឧស្សាហកម្មច្នៃប្រឌិត ក្នុងគម្រោងមូលនិធិ សម្រាប់គោលដៅអភិវឌ្ឍន៍សហស្សវត្សចំពោះប្រជាជនម្ចាស់ស្រុកនៅខេត្តរតនគិរី មណ្ឌលគិរី កំពង់ធំ និងព្រះវិហារ ដូចជា :

-ការពង្រឹងសមត្ថភាពនៃស្ថាប័នជាតិ ដើម្បីអភិរក្ស និងអភិវឌ្ឍសម្បត្តិវប្បធម៌រូបី និងអរូបី ដោយធ្វើឲ្យវប្បធម៌ទាំងនោះ កាន់តែប្រសើរឡើង សំដៅលើកស្ទួយសក្តានុពលសេដ្ឋកិច្ចសង្គម។

-ការបង្កើនឱកាសការងារ និងប្រាក់ចំណូលដល់ឧស្សាហកម្មច្នៃប្រឌិត តាមរយៈការពង្រឹងជំនាញសហគ្រិនវប្បធម៌ ក្នុងការអភិវឌ្ឍសេវាកម្មសម្រាប់ធ្វើពាណិជ្ជកម្ម និងទីផ្សារសេរី។

-ការបង្កើន និងពង្រឹងការធ្វើពាណិជ្ជកម្មនៃផលិតផល និងសេវាកម្មវប្បធម៌សម្រាប់ទីផ្សារក្នុងស្រុក ក្នុងតំបន់ និងអន្តរជាតិ។

## មហោស្រពសិល្បៈមហាជនអភិវឌ្ឍន៍

ការបើកមហោស្រពសិល្បៈមហាជន អភិវឌ្ឍន៍ថ្នាក់រាជធានី ខេត្ត ថ្នាក់ភូមិភាគ និងថ្នាក់ជាតិ គឺដើម្បីអភិវឌ្ឍន៏សិល្បៈមហាជនឲ្យក្លាយជាសិល្បៈអភិវឌ្ឍន៍ពិតប្រាកដ តាមរយៈការបណ្តុះបណ្តាលអ្នកនិពន្ធ អ្នកដឹកនាំរឿង អ្នកសម្តែង និងអ្នកបច្ចេកទេស។ ការស្ថាបនាស្នាដៃថ្មី និងការសម្តែងជូនសាធារណជនប្រកបដោយគុណភាព នឹងផ្តល់នូវសម្រស់វប្បធម៌ទាំងការអប់រំ និងការផ្សព្វផ្សាយអំពីតម្លៃសិល្បៈ ដើម្បីពង្រឹង និងពង្រីក គុណភាពស្នាដៃសិល្បៈ ទស្សនីយភាព សំដៅរួមចំណែកក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចជាតិ៕

# ពិភពលោកទាំងមូលត្រូវរួមគ្នាទប់ស្កាត់បម្លាស់ប្ដូរអាកាសធាតុដ៏ធ្ងន់ធ្ងរ



បម្រែបម្រួលអាកាសធាតុធ្វើឱ្យផែនដី កាន់តែទទួលរងនូវគ្រោះធម្មជាតិ



គ្រោះរាំងស្ងួត បណ្ដាលមកពីបម្រែបម្រួលអាកាសធាតុ

បច្ចុប្បន្ននេះ ពិភពលោកទាំងមូលហាក់ដូចជាកំពុងស្ថិតក្នុងស្ថានភាពក្ដៅគគុក និងត្រូវគ្របដណ្ដប់ដោយគ្រប់បញ្ហាស្មុគស្មាញជាច្រើន ហើយដែលងាយបង្កគ្រោះថ្នាក់បំផុត។ មេដឹកនាំពិភពលោកហាក់ដូចជាកំពុងផ្ដោតអារម្មណ៍ តែទៅលើជម្លោះនៅមជ្ឈិមបូព៌ា ការវាយប្រយុទ្ធជាមួយពួកសកម្មប្រយុទ្ធរដ្ឋឥស្លាមជ្រុលនិយម បញ្ហានៅអ៊ុយក្រែន នៅតំបន់ហុងកុងជាដើម។ ប៉ុន្តែពួកគេហាក់ដូចជាយកចិត្តទុកដាក់មិនទាន់ដិតដល់នៅឡើយអំពីគ្រោះថ្នាក់ ដែលទាំងអស់គ្នាមិនអាចគេចផុតបាន គឺការផ្លាស់ប្ដូរអាកាសធាតុដ៏ឆាប់រហ័ស និងផ្ដល់ផលអាក្រក់យ៉ាងក្រៃលែងដល់ មនុស្សជាតិ និងពិភពលោកទាំងមូល។

នៅក្នុងជំនួបកំពូល ស្ដីពីបម្លាស់ប្ដូរអាកាសធាតុរបស់អង្គការសហប្រជាជាតិដែលធ្វើឡើងនៅក្នុងទីក្រុងញូវយ៉កនៃសហរដ្ឋអាមេរិក កាលពីពេលកន្លងទៅនេះ មានការសន្យាជាច្រើន ប៉ុន្តែដូចជាគ្មានការអះអាងបញ្ជាក់ណាមួយច្បាស់លាស់នៅឡើយទេ ។ វាមានការកត់សម្គាល់ច្រើនដែរដូចជាឧបនាយករដ្ឋមន្ត្រីចិន លោក **ចាង ហ្គៅលី** បានសន្យាថា ប្រទេសរបស់លោកនឹងប្រឹងប្រែងកាត់បន្ថយឲ្យបានការបំភាយកាបូនឌីអុកស៊ីតតាមលទ្ធភាពដែលអាចធ្វើទៅបាន ។ លោកប្រធានាធិបតីអាមេរិក **បារ៉ាក់ អូបាម៉ា** ក៏បានសន្យាថានៅឆ្នាំក្រោយនេះលោកនឹងធ្វើឲ្យបានសម្រេចការដាក់ចេញផែនការ កាត់បន្ថយការបំភាយឧស្ម័នក្រោយឆ្នាំ២០២០។ ក៏ប៉ុន្តែនៅក្នុងការសន្យាទាំងនេះ គេមើលឃើញអំពីទំនាក់ទំនងនៃប្រតិបត្តិការពាណិជ្ជកម្មនៅក្នុងវិស័យកសិកម្ម ដែលចេះតែកើនឡើងនៅតំបន់ព្រៃដែលមានទឹកភ្លៀង ហើយរដ្ឋាភិបាលមួយចំនួនក៏បានចុះហត្ថលេខា ប្រកាសសន្យាកាប់បណ្ដាញព្រៃដ៏ធំស្កុកស្កម្មមួយចំនួននៅឆ្នាំ ២០២០ និងរហូតដល់ឆ្នាំ ២០៣០ ។ ជំនួបកំពូលនេះ មិនបានធ្វើការប្រមាណទុកជាមុន អំពីការពិភាក្សាលម្អិតចំពោះសន្ធិសញ្ញាអំពីអាកាសធាតុថ្មីមួយ ដែលបានចុះហត្ថលេខាហើយនោះទេ ។ ការពិភាក្សានោះគ្រាន់តែបានធ្វើឡើងដោយមានការចូលរួមផ្ដល់យោបល់របស់ the UN climate Andrew Burton/Getty ការថ្លែងសុន្ទរកថារបស់លោក **អូបាម៉ា** ទៅកាន់ជំនួបកំពូលស្ដីពីការផ្លាស់ប្ដូរអាកាសធាតុរបស់ អ.ស.ប នៅទីក្រុងញូវយ៉ក ការត្រៀមសន្និសីទមួយនៅទីក្រុងប៉ារីសនៅឆ្នាំក្រោយតែប៉ុណ្ណោះ។

លើភាពពិតជាក់ស្ដែង គេអាចមើលឃើញគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរពីផលវិបាកនៃការផ្លាស់ប្ដូរអាកាសធាតុដ៏លឿន។រលកកំដៅដ៏ខ្លាំងដែលមិនធ្លាប់មាននៅប្រទេសអូស្ត្រាលីកាលពីឆ្នាំកន្លងទៅ ត្រូវបានគេចាត់ទុកថានោះជាការផ្លាស់ប្ដូរធាតុអាកាស ដែលធ្វើឲ្យប៉ះពាល់ដល់មនុស្សជាតិយ៉ាងធ្ងន់ធ្ងរណាស់ ។ រលកកំដៅដែលកើតឡើងនៅប្រទេសជប៉ុន ចិន និងអឺរ៉ុប ក៏បានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់មនុស្សជាតិដែរ។ នេះបើយោងតាមរបាយការណ៍សំយោគមួយដែលព្រមានអំពីភាពគ្រោះថ្នាក់ជាសកល នៃការផ្លាស់ប្ដូរអាកាសធាតុ ។ របាយការណ៍សំយោគដែលបោះពុម្ពផ្សាយនៅក្នុងព្រឹត្តិបត្តិ the American Meteorological Society បានឲ្យដឹងថា អ្នកវិទ្យាសាស្ត្រ ២២ ក្រុមបានធ្វើការសិក្សាយ៉ាងលម្អិតអំពីហេតុការណ៍អាកាសធាតុដ៏ធ្ងន់ធ្ងរចំនួន ១៦ ករណី ដែលកើតឡើងនៅក្នុងឆ្នាំ ២០១៣។ ការសិក្សាបានធ្វើការសន្និដ្ឋានថា នៅពេលនេះ វាគឺជាការលំបាកយល់យ៉ាងក្រៃលែងអំពីផលវិបាកដែលជះទៅលើមនុស្សជាតិទូទៅដោយសារតែបម្រែបម្រួលអាកាសធាតុធ្ងន់ធ្ងរ គួយ៉ាងដូចជាគ្រោះរាំងស្ងួតដ៏យូរអង្វែងនៅកាលីហ្វ័រញ៉ា ភ្លៀងធ្លាក់យ៉ាងគំហុកនៅខូឡូរ៉ាដូ និងព្យុះទឹកកកមុនរដូវកាលនៅ South Dakota ជាដើម ។ នេះជារបាយការណ៍ប្រចាំឆ្នាំលើកទី ៣ ហើយ ដែលនិយាយទាក់ទិនវាងហេតុការណ៍នៃធាតុអាកាសដែលបានផ្លាស់ប្ដូរ ជាក់ស្ដែងនីមួយៗ និងបម្រែបម្រួលធាតុអាកាសទូទៅ ។ ការសិក្សាទាំងនេះ ក៏បានឈានទៅដល់ការសន្និដ្ឋានចំពោះគ្រោះរាំងស្ងួតយូរអង្វែង នៅកាលីហ្វ័រញ៉ា ដែលគេសង្កេតឃើញភាពរាំងស្ងួតកើតមានអស់រយៈពេល ១២ខែ ចាប់ពីឆ្នាំ២០១៣ ដល់ដើមឆ្នាំ២០១៤។លទ្ធផលនៃការសិក្សាបានរកឃើញថាវាមានការភ្ជាប់ទំនាក់ទំនងគ្នារវាងសីតុណ្ហភាពនៅលើផ្ទៃមហាសមុទ្រប៉ាស៊ីហ្វិក និងរឿងរ៉ាវប្លែកៗខុសពីធម្មតាដែលកើតក្នុងបរិយាកាស ហើយដែលគេមិនទាន់អាចមានលទ្ធភាពរកឃើញថាតើវាមានជាប់ទាក់ទិនដោយផ្ទាល់ទៅដល់ការប្រែប្រួលអាកាសធាតុដែលបង្កឡើងដោយមនុស្សជាតិ ឬយ៉ាងណានោះ។

របាយការណ៍បានធ្វើសំយោគ និងផ្ដល់ជាយោបល់ថា ការប្រើប្រាស់ធនធានធម្មជាតិដើម្បីទាញយកថាមពល ការប្រើប្រាស់ដីធ្លី ឬក៏ការធ្វើអ្វីមួយគ្រប់ប្រទេសទាំងអស់ដែលមានឱកាស ក្នុងការធ្វើឲ្យមានកំណើនសេដ្ឋកិច្ច ក្នុងពេលជាមួយគ្នានោះ ក៏ត្រូវកាត់បន្ថយ អំពីគ្រោះថ្នាក់ដែលបណ្ដាលមកពីការប្រែប្រួលអាកាសធាតុផងដែរ៕



ផ្សែងចេញពីរោងចក្រឧស្សាហកម្មធំៗ ធ្វើឱ្យប៉ះពាល់ដល់បរិស្ថានភពផែនដី

# អត្ថប្រយោជន៍ពីការទទួលទានទឹកក្រូចឆ្មារ





*ផ្លែក្រូចឆ្មារ ផ្តល់ប្រយោជន៍ជាច្រើនដល់សុខភាពមនុស្ស*



ផ្លែឈើគ្រប់ប្រភេទសុទ្ធតែមានមុខងារ និងផលប្រយោជន៍ដោយឡែករៀងខ្លួន សម្រាប់បម្រើដល់សុខភាពមនុស្សយើង ព្រោះវាមានផ្ទុកនូវវីតាមីនជាច្រើនប្រភេទផ្សេងៗគ្នា ដែលសុទ្ធតែជាសារជាតិចាំបាច់សម្រាប់សារពាង្គកាយ ។

ក្នុងចំណោមផ្លែឈើទាំងអស់នោះ ក្រូចឆ្មារក៏ជាផ្លែឈើមួយប្រភេទដែល បានផ្តល់គុណប្រយោជន៍យ៉ាងច្រើនដល់សុខភាព។ ការទទួលទានទឹកក្រូចឆ្មារជាមួយទឹកក្តៅឧណ្ហៗ ជារៀងរាល់ព្រឹក នឹងជួយជំរុញដំណើរការកន្ត្រាក់របស់ប្រព័ន្ធរំលាយអាហារបានល្អប្រសើរ ជួយកាត់បន្ថយជាតិអាស៊ីតនៅក្នុងក្រពះ និងសម្រួលដំណើរការបន្ទោបង់លាមក និងជួយសំអាតសារជាតិពុល ដែលមាននៅក្នុងថ្លើមបានមួយផ្នែកផងដែរ ។

នៅក្នុងផ្លែក្រូចឆ្មារសម្បូរវីតាមីន C និងអាស៊ីតអាស្កូប៊ីក ( Ascorbic Acid) យ៉ាងច្រើន ហើយសារធាតុទាំងនោះ គឺពិតជាមានសារៈសំខាន់សម្រាប់បំប៉នសុខភាពមនុស្សយ៉ាងខ្លាំង ព្រោះវីតាមីន C អាចប្រឆាំង និងព្យាបាលជំងឺផ្តាសាយ ជួយប្រឆាំងសារជាតិពុលក្នុងខ្លួនរបស់មនុស្ស និងជាឱសថធម្មជាតិក្នុងការថែរក្សាសុខភាពស្បែកប្រឆាំង នឹងភាពចាស់ជ្រីវជ្រួញមុនអាយុបានយ៉ាងល្អប្រសើរ ។ ចំណែកអាស៊ីតអាស្កូប៊ីក មានមុខងារជួយជំរុញសារពាង្គកាយឲ្យស្រូបយកសារជាតិដែក ពីចំណីអាហារបានយ៉ាងល្អ ។

ប្រសិនបើជាតិអាស៊ីតនៅក្នុងសារពាង្គកាយរបស់មនុស្សមិនមានតុល្យភាព ឬច្រើនលើសកម្រិត វានឹងងាយបង្កឲ្យមានជំងឺផ្សេងៗ ដោយសារកត្តាចំណីអាហារ និងការទទួលទានស្រាជាដើម នោះទឹកក្រូចឆ្មារនឹងជួយសម្រួលបរិមាណសារជាតិអាស៊ីត ដែលលើសទាំងអស់នោះបានយ៉ាងប្រសើរ ។ ទឹកក្រូចឆ្មារមានជាតិឌីអ៊ុយរ៉េធម្មជាតិ ជួយជំរុញដំណើរការបញ្ចេញចោលមេរោគនៅក្នុងទឹកនោមទៀតផង ។ ម្យ៉ាងទៀត ការដាក់បញ្ចូលគ្នារវាងទឹកក្រូចឆ្មារ និងទឹកក្តៅឧណ្ហៗក៏បានជួយបំបាត់កង្វះជាតិទឹក នៃសារពាង្គកាយ ព្រមទាំងសម្រួលការបញ្ជូនអុកស៊ីហ្សែនទៅក្នុងឈាម បានមួយផ្នែកផងដែរ ដែលនឹងធ្វើឲ្យមនុស្ស មានអារម្មណ៍ស្រស់ស្រាយពេញមួយថ្ងៃ ៕

# តើការវៀចខ្នងច្រមុះអាចការពារបានយ៉ាងដូចម្តេច?



*ខ្នង់ច្រមុះមនុស្សដែលវៀចដោយឧប្បត្តហេតុផ្សេងៗ អាចកែតម្រង់វិញបាន*

ការវៀចខ្នង់ច្រមុះ វាបានកើតឡើងនៅពេលដែលជញ្ជាំងស្តើងចន្លោះ រវាងរន្ធច្រមុះទាំងពីររបស់អ្នកត្រូវបានផ្លាស់ទីទៅមួយចំហៀង។ នៅលើមនុស្សជាច្រើន សន្ទះច្រមុះត្រូវបានវៀចធ្វើឲ្យរន្ធច្រមុះម្ខាងតូចជាងមុន ។ ពេលដែលមានការវៀចខ្នង់ច្រមុះមានសភាពធ្ងន់ធ្ងរ វាអាចខ្ទប់រន្ធច្រមុះរបស់អ្នកម្ខាង និងកាត់បន្ថយការខ្យល់ចូល បង្កឲ្យមានការលំបាកក្នុងការដកដង្ហើម។

បន្ថែមលើការវៀចខ្នង់ច្រមុះ ខ្យល់ស្ងួតឆ្លងកាត់តាមច្រមុះ ពេលខ្លះអាចនឹងរួមចំណែកធ្វើឲ្យមានការហូរឈាម ឬប្រេះលើបុគ្គលមួយចំនួន។ ការស្ទះរន្ធច្រមុះ អាចកើតឡើងមកពីសន្ទះច្រមុះហើម ហើយស្អិតជាប់គ្នា។ ការព្យាបាលនៃការស្ទះរន្ធច្រមុះអាចនឹងរួមបញ្ចូលទាំងការប្រើប្រាស់ថ្នាំដើម្បីកាត់បន្ថយការហើមដើម្បីជួយបើករន្ធច្រមុះ ។ ដើម្បីកែតម្រូវការវៀចខ្នង់ច្រមុះការវះកាត់គឺជាការចាំបាច់ ។ ការវៀចខ្នង់អាចត្រូវបានបង្កឡើងដោយ ៖

*-កើតមានតាំងពីកំណើត :* ក្នុងករណីខ្លះការវៀចខ្នង់ច្រមុះកើតឡើង ក្នុងអំឡុងពេលនៃការវិវឌ្ឍរបស់ទារកក្នុងផ្ទៃ និងអាចដឹងបាននៅពេលកើត។

*-ការរងរបួសទៅនឹងច្រមុះ :* អ្នកប្រហែលជាអាចបង្ការការរងរបួសច្រមុះរបស់អ្នកដែលអាចបណ្តាលឲ្យវៀចខ្នង់ ជាមួយនឹងការប្រុងប្រយ័ត្នទាំងនេះ ៖

*-ពាក់មួកសុវត្ថិភាព :* នៅពេលដែលលេងកីឡា ឬធ្វើដំណើរតាមម៉ូតូ។

*-ពាក់ខ្សែក្រវ៉ាត់ :* នៅពេលដែលជិះនៅក្នុងរថយន្ត៕



# យើងស្រឡាញ់ខេត្តពោធិ៍សាត់របស់យើង

*គ្រប់ខេត្តនៅទូទាំងព្រះរាជាណាចក្រកម្ពុជា សុទ្ធតែមានលក្ខណៈពិសេសដោយឡែកៗពីគ្នា អាស្រ័យទៅលើភូមិសាស្ត្រ ប្រពៃណី ទំនៀមទម្លាប់ និងការរស់នៅជាក់ស្តែងរបស់ប្រជាជន។ បណ្តាខេត្តនៅភូមិភាគឦសាន្តសម្បូរទៅដោយព្រៃឈើ សត្វព្រៃ ហើយមានអាកាសធាតុត្រជាក់ស្ទើរគ្រប់រដូវកាលបានធ្វើឲ្យតំបន់នោះមានការទាក់ទាញបែបម្យ៉ាងទៅ។ខេត្តនៅភូមិភាគពាយ័ព្យ និងបស្ចិម សម្បូរទៅដោយវាលស្រែល្វឹងល្វើយ មានលទ្ធភាពឲ្យប្រជាជនងាយស្រួលបង្កបង្កើនផលស្រូវ និងដំណាំផ្សេងៗ។ ខេត្តនៅជាប់មាត់សមុទ្រក៏មានលក្ខណៈពិសេសរបស់ខ្លួនទៅតាមនោះដែរ។ ប៉ុន្តែអ្វីដែលគួរកត់សម្គាល់ គឺគ្រប់ខេត្តទាំងអស់សុទ្ធតែមានតំបន់ទេសចរណ៍ធម្មជាតិ តំបន់ទេសចរណ៍វប្បធម៌ និងសក្តានុពលសេដ្ឋកិច្ចដ៏ពិសេស។ ដោយឡែកខេត្តពោធិ៍សាត់ក៏មិនខុសពីខេត្តដទៃទៀតដែរ។*



*លោក សៅ ដារឿន*





*រមណីយដ្ឋានធម្មជាតិទឹកហូរតាមដងស្ទឹង និងស្ពានឆ្លងកាត់ស្ទឹងពោធិ៍សាត់*

ខេត្តពោធិ៍សាត់ ស្ថិតនៅជាប់បឹងទន្លេសាប និងជាប់តំបន់ព្រៃភ្នំ ព្រមទាំងជិតដែនសមុទ្រថែមទៀតដែលមានទីតាំងនៅបស្ចិមទិសនៃប្រទេសកម្ពុជា។ ខេត្តនេះមាន ៦ ស្រុក មាន ៤៩ ឃុំ ចែកជា ៤៩៥ ភូមិ។ មានប្រជាជនរស់នៅ ៣៦០ ៤៤៥ នាក់ ក្នុងនោះ ស្ត្រីមាន ៥២% នៃប្រជាជនសរុបក្នុងខេត្ត។ ដង់ស៊ីតេប្រជាជនរបស់ខេត្ត គឺ ២៨ នាក់ ក្នុង ១ គីឡូម៉ែត្រការ៉េ។ កាលណានិយាយពីខេត្តពោធិ៍សាត់ គេតែងនឹកឃើញទៅដល់ឈ្មោះភ្នំក្រវាញ និងថ្មកែវ។ ខេត្តនេះមានភ្នំធម្មជាតិមួយកន្លែង គឺភ្នំក្រវាញ ដែលប្រជាជនយើងតែងតែទៅគាស់យកថ្មម៉្យាង ជាប្រភេទថ្មកែវដែលមានតម្លៃ មកឆ្លាក់ជារូបផ្សេងៗសម្រាប់លក់ដូរជូនប្រជាជន ទាំងក្នុងប្រទេស និងក្រៅប្រទេស។ លោក*សំ ឃីម* ប្រធានមន្ទីរទេសចរណ៍ខេត្តបានឲ្យដឹងថា នៅក្នុងខេត្តនេះមានសិប្បករដ៏មានជំនាញ ដែលយើងអាចឃើញពួកគេនៅកន្លែងធ្វើសិប្បកម្ម ដែលមានចម្លាក់ព្រះពុទ្ធបដិមាករតូចធំ និងរូបចម្លាក់ដ៏ស្រស់ស្អាតផ្សេងទៀត។ មានសិប្បកម្មចម្លាក់ច្រើនជាង ១៦០ កន្លែងក្នុងបណ្តាស្រុក លើកលែងតែស្រុកវាលវែងមួយប៉ុណ្ណោះដែលជាតំបន់ភ្នំ។ រោងចម្លាក់ភាគច្រើន មានលក្ខណៈជាសិប្បកម្មឯកជនតូចៗ។ រោងចម្លាក់ និងហាងជាច្រើនក្នុងខេត្តពោធិ៍សាត់លក់របស់មួយចំនួនជាចម្លាក់ធ្វើដោយដៃយ៉ាងពិសេស ដូចជាចម្លាក់ថ្មកែវ ចម្លាក់ឈើប្រណីតជាដើម។ កន្លែងចម្លាក់មួយដែលគួរទៅទស្សនា គឺស្ថិតក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈសិប្បកម្ម **ប៊ុន រ៉ានី ហ៊ុន សែន** ពោធិ៍សាត់។ទីនេះក៏ជាកន្លែងមួយយ៉ាងពិសេសបំផុតសម្រាប់អ្នកទស្សនា ព្រោះយើងអាចជជែកពិភាក្សាគ្នាលេង ជាមួយប្រជាជនសិក្សាអំពីសិប្បកម្មប្រពៃណី ដ៏មានភាពល្បី





*ភ្ញៀវទេសចរជាតិ-អន្តរជាតិ ទស្សនាកំសាន្តភូមិបណ្តែតទឹកនៅតាមដងទន្លេសាប ក្នុងខេត្តពោធិ៍សាត់*



*រមណីយដ្ឋានកោះសំពៅស្ទឹងពោធិ៍សាត់ ក្នុងខេត្តពោធិ៍សាត់*



*ភ្ញៀវទេសចរជាតិ-អន្តរជាតិ ទស្សនាកំសាន្តនៅរមណីយដ្ឋានធម្មជាតិ និងប្រវត្តិសាស្ត្រនានា ក្នុងខេត្តពោធិ៍សាត់*

ល្បាញ ដូចជាការត្បាញសូត្រ ត្បាញកន្ទេលដ៏ស្រស់ស្អាត ឬក៏សិក្សាស្វែងយល់អំពីការធ្វើជំនួញនៃរូបចម្លាក់ជាដើម ។ មជ្ឈមណ្ឌលនេះមានទីតាំងនៅជិតវិទ្យាល័យពោធិ៍សាត់ ខាងជើងក្រុងពោធិ៍សាត់តាមផ្លូវជាតិលេខ ៥ ។

ដូចខេត្តដទៃទៀតដែរ ចង់ទៅលេងខេត្តពោធិ៍សាត់ គឺមិនចាំបាច់ភ័យព្រួយអំពីបញ្ហាអសន្តិសុខអ្វីទៀតទេ។ គ្រប់កន្លែងទាំងអស់គឺធានាសុវត្ថិភាព។ ខេត្តនេះសម្បូរទៅដោយតំបន់ទេសចរណ៍យ៉ាងច្រើន។ រមណីយដ្ឋានធម្មជាតិកោះថាសមានចម្ងាយ ១៦ គីឡូម៉ែត្រ ពីទីរួមខេត្តតាមផ្លូវលេខ ៥៦ ។ ទីនេះមានកូនភ្នំ មានព្រៃឈើ មានទឹកអូរធម្មជាតិដែលមានទឹកធ្លាក់ជាប្រចាំ និងសម្បូរទៅដោយរុក្ខជាតិព្រៃឈើហូបផ្លែ ដូចជា គុយ សិរមាន់ ជាដើម។ ប៉ុន្តែតំបន់ទេសចរណ៍ដែលមានសក្តានុពលខ្លាំងជាងគេ គឺរមណីយដ្ឋានទឹកធ្លាក់ច្រកល្អៀង ស្ថិតក្នុងភូមិបំណាក់ ស្រុកក្រគរ ខេត្តពោធិ៍សាត់ ដែលមានចម្ងាយពីទីរួមស្រុក ឆ្ពោះទៅទិសខាងត្បូងតាមបណ្តោយផ្លូវជាតិលេខ ៥ ប្រមាណ ៤១ គីឡូម៉ែត្រ។ នៅលើផ្ទៃទឹកបឹងទន្លេសាបវិញ ភូមិសហគមន៍ទេសចរណ៍ បណ្តែតទឹកកំពង់លួង ស្ថិតក្នុងស្រុកក្រគរដែរនោះ បានបង្ហាញរូបភាពដ៏ស្រស់បំព្រងបង្អួតខ្លួន ជាមួយនឹងសម្រស់ធម្មជាតិដ៏ត្រកាល ហាក់ដូចជាផ្ទាំងគំនូររបស់វិចិត្រករដែឯកដែលបានគូសវាសឡើង ជាមួយនឹងមនោសញ្ចេតនាជក់ចិត្ត ដិតអារម្មណ៍យ៉ាងក្រៃលែង។ ភូមិសហគមន៍នេះមានចម្ងាយប្រមាណ ៣៥ គីឡូម៉ែត្រពីទីរួមខេត្តជាទីកន្លែងដ៏សំខាន់មួយសម្រាប់ភ្ញៀវទេសចរចម្រុះគ្រប់ជាតិសាសន៍ដែលមកទស្សនាពុំមានដាច់។ ភូមិនេះតាំងនៅលើផ្ទៃទឹកបឹងទន្លេសាប ដែលមានប្រជាជនរស់នៅជាង ១ ម៉ឺននាក់។ ប្រជាជនគ្រប់រូប រស់នៅលើទូកបណ្តែតទឹក ហើយភូមិទាំងមូលត្រូវប្តូរទីតាំងចល័ត ទៅតាមកម្រិតភូមិសាស្ត្រ ទឹកជ្រៅ ឬទឹករាក់នៃទឹកបឹង។ ថ្វីបើភូមិទេសចរណ៍មួយនេះស្ថិតនៅលើផ្ទៃទឹក ប៉ុន្តែជីវភាពរបស់ប្រជាជនមានភាពធូរធារ មិនចាញ់អ្នករស់នៅលើគោកទេ គ្រាន់តែរបៀបនៃការរស់នៅខុសគ្នាពីអ្នកដីគោកតែប៉ុណ្ណោះ។ មានសាលារៀន មាន ផ្សារ មានស្នាក់ការឃុំ ភូមិ ប៉ុស្តិ៍រដ្ឋបាល វត្តអារាម ប៉ុន្តែចង់ទៅទីកន្លែងណាមួយគឺជិះទូក សូម្បីតែរោងបុណ្យ រោងការ ក៏ធ្វើនៅលើទូកដែលចងភ្ជាប់គ្នា។ ភ្ញៀវទេសចរទាំងឡាយដែលទៅទស្សនាភូមិសហគមន៍បណ្តែតទឹកនោះ ក៏អត់មានបញ្ហាអ្វីដែរ ព្រោះទីនោះមានផ្ទះសំណាក់ មានភោជនីយដ្ឋាន រាប់ទាំងមានហាងខារ៉ាអូខេផង ។ ប៉ុន្តែក៏អាចទស្សនាត្រឹមរយៈពេល ១ ថ្ងៃ ហើយត្រឡប់មកសម្រាកនៅទីរួមស្រុកក្រគរ ឬក៏ទីរួមខេត្តពោធិ៍សាត់ក៏បាន។ គេអាចធ្វើដំណើរទៅទីនោះដោយជិះម៉ូតូ ដែលត្រូវចំណាយ ៦ ដុល្លារ និងចំណាយពេលវេលាធ្វើដំណើរមួយម៉ោងកន្លះ ។ បន្ទាប់ពីទស្សនាភូមិសហគមន៍ បណ្តែតទឹកផ្ទៃបឹងទន្លេសាបរួចហើយ យើងក៏អាចទៅទស្សនាតំបន់ព្រៃភ្នំរមណីយដ្ឋានទឹកធ្លាក់ច្រកល្អៀងថែមទៀត ។ លោក *សំ ឃីម* បានឲ្យដឹងទៀតថា ខេត្តពោធិ៍សាត់ថ្វីត្បិតតែមិនមាន សម្បត្តិបេតិកភណ្ឌ ដូចជាប្រាសាទបុរាណ ដែលមាននៅខេត្តសៀមរាប បាត់ដំបង កំពង់ធំ តាកែវក្តី ប៉ុន្តែខេត្តនេះក៏មានធនធានសម្បត្តិធម្មជាតិជាច្រើនអាចទាក់ទាញភ្ញៀវទេសចរជាតិ អន្តរជាតិផងដែរ ដូចជាសម្រស់ធម្មជាតិនៅភ្នំក្រវាញសត្វ ព្រៃប្លែកៗ និងកម្រ



*លោក មូលផុន*



*អ្នកមីង ភិន ថាវ*



*ហ្វូងសត្វស្លាបជាច្រើនដែលបាននាំគ្នាមករស់នៅក្នុងបឹងព្រះពន្លៃ*



*រូបសំណាកដែលបានត្រូវកសាងតម្កល់នៅតាមសួនសាធារណៈនានា ក្នុងខេត្តពោធិ៍សាត់*

ដូចជាក្រពើភ្នំ ជីវិតរស់នៅរបស់បងប្អូនជនជាតិភាគតិចនិងតំបន់ទឹកធ្លាក់ជាដើម។ថ្មីៗនេះមានហ្វូងសត្វស្លាបរាប់សែនក្បាល បាននាំគ្នាមករស់នៅបឹងព្រះពន្លៃ ដែលជាបឹងបុរាណយូរមកហើយ ស្ថិតក្នុងភូមិបត់រំដួល ឃុំផ្ទះរ៉ុង ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។ កង្វះខាតតែមួយគត់គឺហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទាក់ទាញទេសចរ ដែលនៅតែជាបញ្ហាចោទ។

យើងងាកមកមើលស្រុកមួយចំនួនទៀតដែលមានសក្តានុពល ខាងវិស័យបង្កបង្កើនផលវិញម្តង។ លោក *សៅ ដារឿន* អភិបាលស្រុកបាកានបានមានប្រសាសន៍ថា តាំងពីរាជរដ្ឋាភិបាលស្ថាបនា ប្រព័ន្ធធារាសាស្ត្របានជាច្រើនកន្លែងបានបង្កលក្ខណៈងាយស្រួលដល់ប្រជាជន ក្នុងការធ្វើស្រែ និងដាំដំណាំទទួលបានទិន្នផលខ្ពស់ ។ កន្លែងខ្លះក្នុងមួយឆ្នាំអាចធ្វើស្រែដល់ទៅ ២ ដង ឬ ៣ ដងឯណោះ។ អ្នកមីង *ភិន ថាវ* រស់នៅភូមិផ្លូវក្របីឃុំអន្លង់វិល ស្រុកកណ្តៀង ដែលស្រុកនេះ ភាគច្រើនជាតំបន់វាលទំនាប បានឲ្យដឹងថា ក្រៅពីធ្វើស្រែក្នុងរដូវវស្សាហើយ ពួកគាត់តែងតែដាំដំណាំរួមផ្សំដែលងាយទទួលបានផល ដូចជាដំណាំស្ពៃគ្រប់ប្រភេទ ត្រសក់ ត្រឡាច ពពាយ រនោង ពោត សណ្តែកជាដើម។ ទីនេះ មានប្រព័ន្ធស្រោចស្រពគ្រប់គ្រាន់ជាជាងទុកដីទំនេរ យើងក៏បង្កើនការដាំដុះព្រោះវាអាចរកប្រភពចំណូលបន្ថែម សម្រាប់ផ្គត់ផ្គង់គ្រួសារ និងឲ្យកូនមានលទ្ធភាព បន្តការសិក្សានៅភ្នំពេញ។ លោក *ហេង សុភាណា* អភិបាលស្រុកវាលវែងក៏បានមានប្រសាសន៍ថា ស្រុករបស់លោកជាតំបន់ខ្ពង់រាប ហ៊ុមព័ទ្ធដោយព្រៃ ភ្នំជ្រោះជ្រលងដងអូរ។ ប្រជាជននៅទីនេះដាំដំណាំស្រូវមិនសូវបានទេ អាស្រ័យដោយកត្តាភូមិសាស្ត្រនៃផ្ទៃដី ។ ប៉ុន្តែបងប្អូន អាចដាំដំណាំឧស្សាហកម្ម បានបង្គួរ ហើយមកដល់ពេលនេះ គឺកន្លែងខ្លះអាចប្រមូលផលបានជាបណ្តើរៗហើយ។ ដំណាំឧស្សាហកម្ម និងកសិឧស្សាហកម្ម ត្រូវចំណាយពេលដាំដុះយូរ ប៉ុន្តែប្រភពចំណូលក៏មិនតិចដែរ។ ដោយឡែកលោក *មូលផុន* ប្រជាជនរស់នៅឃុំឈើតុំ ស្រុកក្រគរ ជាកសិករផង និងជាគ្រូបង្រៀនផង បានមានប្រសាសន៍ថា ជីវភាពប្រជាជននៅមូលដ្ឋានរបស់គាត់មានភាពប្រសើរជាងពីមុនឆ្ងាយ។ រាជរដ្ឋាភិបាល បានកសាងប្រព័ន្ធស្រោចស្រពគ្រប់ទីកន្លែង។ ទឹកមានប្រើប្រាស់សម្រាប់ការបង្កបង្កើនផលខួបប្រាំងខួបវស្សា ។ ខ្លួនគាត់ផ្ទាល់ អាចធ្វើស្រែបានដល់ទៅ៣ដងក្នុងមួយឆ្នាំ ដូច នេះគ្មានអ្វីដែលលំបាកទៀតទេ ។ពេលនេះ ប្រជាជនត្រូវចំណាយពេលវេលា និយាយតែពីធ្វើម៉េចឲ្យជីវភាពសម្បូរសប្បាយ ។ ស្រុកទេសមានការអភិវឌ្ឍ គ្មានសង្គ្រាមទៀតទេ គ្មានចលាចល គ្មានការកាប់សម្លាប់ ដូចនៅប្រទេសគេខ្លះទេ ។ ឱកាសកំពុងស្ថិតនៅក្នុងដៃរបស់យើង។

ប្រជាជន ខេត្តពោធិ៍សាត់ ក៏ដូចជាប្រជាជនទូទាំងប្រទេស សុទ្ធតែបានមើល ឃើញច្បាស់ថា សន្តិភាពកំពុងតែកើតមានគ្រប់ច្រកល្ហក ក្នុងទូទាំងប្រទេស។ សន្តិភាពត្រូវបានទទួលមកវិញ ដោយស្នាដៃរបស់ប្រជាជនកម្ពុជា ក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា ដែលមានសម្តេចអគ្គមហាទាំងបីជាប្រមុខដ៏ឈ្លាសវៃ ។ តទៅមុខទៀត ខេត្តពោធិ៍សាត់ នឹងនៅតែស្ថិតនៅលើផ្លូវនៃការអភិវឌ្ឍ ដោយគ្មានអ្វីអាចរារាំងបានឡើយ ។លោក *សំឃើម*បានបញ្ចប់កិច្ចសម្ភាសន៍ដោយស្នាមញញឹមនៅលើផ្ទៃមុខ ប្រកបដោយមោទនភាព ហើយបានបញ្ជាក់ជាចុងក្រោយថា សមិទ្ធផលដែលយើងខិតខំធ្វើបាន គឺច្រើនណាស់ ហើយធំធេងណាស់។ ហេតុនេះ យើងត្រូវថែរក្សាវាឲ្យបានជាក់ស្តែង ដូចជានៅខេត្តពោធិ៍សាត់នេះអ៊ីចឹង ។ យើងស្រឡាញ់ខេត្តពោធិ៍សាត់របស់យើង៕



*សាលាខេត្តពោធិ៍សាត់*




(បទពាក្យ ៧)

- ភ្លៀងធ្លាក់ទៀបភ្លឺ ព្ធក្អាត់យំ
ទំនៀមចាស់ទុំលោកផ្ដាំថា
- ជំនួសមកវិញនូវហេមន្ត
ទឹកភ្លៀងលាងស្លែខែរំហើយ
- ស្រូវបងមូរដើមផើមបណ្ដើរ
បងជីកអន្លង់ចាប់ត្រីផង
- បងដើរលើភ្លឺព្ធតៅរ៉ៅ
ត្រដេវិចស្រែកទទាឆ្លើយ
- រលឹមផ្សែងក្រួចបងហួចហៅ
កំពុងបាចជីកណ្ដៀតល្អី
- បងប្រញាប់ជួយមិននៅស្ងៀម
អូនញញឹមអៀនមានកង្វល់
- អូនច្រៀងហ៊ឹមៗបទវាលធំ
បងអើយបងចាំអូនផងណា
- ស្ដាប់ចម្រៀងអូនបងព្រឺព្រួច
សន្យាធ្លាក់ខ្យល់ដល់ស្រូវថ្មី
- រដូវកឋិនមកដល់ហើយ
អូនទៅធ្វើបុណ្យជាមួយបង
- ឆ្នាំមុនយើងជិះរទេះសាឡី
រឺម៉កគោយន្តថ្មីធានា
- ស្រូវស្រែលេងខ្លួនអូនតែងកាយ
អាវប៉ាក់ជរជាយលាយជាប់ឱន

សន្ទូងបែកគុម្ពថ្នក់ទឹកផ្កា
រដូវវស្សាជិតឃ្លាតហើយ។
ឆ្លងផុតវស្សន្ដមិនយូរឡើយ
ផ្គរដាស់ឆ្លងឆ្លើយលាក្ដាមខ្យង។
ចោលក្លិនប្រហើររសលម្អង
ក្បែរស្រែនួនល្អងជិតបង្កើយ។
យំបង្កូកហៅសូរខ្ញើយៗ
កៀនទួលកន្ត្រើយក្បែរស្រែស្រី។
ដើរកាត់សំដៅទៅជួបថ្លៃ
បំប៉នស្រូវស្រីបង្កើនផល។
ទាំងព្រឹកព្រហាមមេឃស្ងប់ខ្យល់
ក្នុងចិត្តគិតដល់ពាក្យសន្យា ។
ស្រងៃបែកគុម្ពកំពីងពួយផ្កា
កំពីងពួយផ្កាចាំមានថ្មី ។
បងប្រាប់ស្រីខួចសូមប្រណី
ម៉ែពុកចូលស្ដីស្រស់នួនល្អង។
ស្រីខួចត្រាណត្រើយមួយឆ្នាំម្ដង
សាងកុសលផ្សងប៉ងជួបគ្នា។
ឆ្នាំនេះដឹកស្រីស្រស់ពុំងា
រួមនឹងមីងមាទៅកឋិន។
ផាមួងពណ៌ស្វាយមិនបាច់ក្បិន
សមណាស់មាសឆ្អិនពានាស្បែ៕




**ខ្ញុំយ៉ាប់ជាង**

នាយកាត់ នាយកង ស្រវឹង ទន់រវៀងខ្លួនជជែកគ្នា :

កាត់ : ខ្ញុំនេះយ៉ាប់មែនទែន ថ្ងៃមុនពេលត្រឡប់ពីស៊ីការវិញ ដោយសារស្រវឹងខ្លាំងពេកក៏ធ្លោយមាត់ប្រាប់ការពិតដល់ប្រពន្ធថា ធ្លាប់រៀបការម្ដងហើយកាលពីប៉ុន្មានឆ្នាំមុន ។

កង : អ្ហេស គ្រាន់តែប៉ុណ្ណឹងមានអីធ្ងន់ធ្ងរ។ ខ្ញុំឯណោះទើបយ៉ាប់ជាងបងឯងទៅទៀត ។ ម្សិលមិញ ពេលត្រឡប់មកពីចូលរួមពិធីឡើងផ្ទះមិតភក្ដិ ព្រោះតែស្រវឹងខ្លាំងពេកក៏ធ្លោយមាត់ប្រាប់ប្រពន្ធពីគម្រោងប្រុងលួចរៀបការជាមួយនារីម្នាក់ទៀត ។

**រួចគ្នា**

ពិធីអាពាហ៍ពិពាហ៍បានបញ្ចប់ ភ្ញៀវត្រឡប់ទៅផ្ទះវិញអស់ កូនកំលោះក្រមុំនាំគ្នាពិនិត្យចំណងដៃ ។ ពេលបើកស្រោមសំបុត្រមួយនេះ នាងប្រពន្ធថ្មោងថ្មីសួរប្ដីដោយងឿងឆ្ងល់ :

-ម៉េចក៏ស្រោមសសោះអ៊ីចឹង មានតែក្រដាសមួយសន្លឹកតូចសរសេរពាក្យពីរម៉ាត់ថា " រួចគ្នា ? " ប្ដីសើចតិចៗរួចតប"

-ព្រោះពេលបងទៅស៊ីការពួកវាកាលពីប្រាំបីខែមុនអត់មានលុយចងដៃវា។ បងសរសេរលើក្រដាសមួយសន្លឹកដាក់ថា "ជំពាក់សិន" ហេតុនេះទើបវាកាត់សងឱ្យរួចគ្នា។

**ចំណីឆ្មា !**

ព្រឹកមួយនាងអូនស្រីបានទៅតវ៉ាជាមួយអ្នកលក់ថ្នាំ ៖

-ថ្នាំសម្លាប់សត្វកណ្ដុរ ដែលពូឯងលក់ឱ្យខ្ញុំកាលពីថ្ងៃមុនម៉េចគ្មានប្រសិទ្ធភាពសោះអ៊ីចឹង ? ខ្ញុំយកទៅប្រើមិនឃើញមានកណ្ដុរណាមួយងាប់សោះ។ ផ្ទុយទៅវិញវារឹតតែធាត់ ឥឡូវពូឯងដោះសាថាម៉េច ?

-បាទ ត្រឹមត្រូវហើយអ្នកស្រី ! ចូរអ្នកស្រីទិញថ្នាំនេះថែមដាក់ឱ្យពួកកណ្ដុរស៊ីទាល់តែធាត់ ចូលរន្ធវិញលែងកើតទៅ។ ដល់ពេលនោះ ពួកវាក្លាយជាកណ្ដុរអត់ផ្ទះសម្បែងរស់នៅតែលតោលកណ្ដាលវាល លែងអីក្លាយជាចំណីរបស់ឆ្មាឆាប់ៗ ។

**ចាប់អាឈ្នះ**

លោកកិត្យា ចូលស្រស់ស្រូបក្នុងភោជនីយដ្ឋានបានកម្មង់បង្កងដុត។ ពេលអ្នករត់តុលើកបង្កងមក ស្រាប់តែវាមានតែដង្កៀបម្ខាង។ លោកកិត្យាសួរចំអក :

-សម័យកុំព្យូទ័រ បង្កងមានតែដង្កៀបម្ខាងទេឬ ?

អ្នករត់តុដោះសា ៖

-សម័យណា ក៏បង្កងមានដង្កៀបពីរតាំងពីបុរាណកាលរហូតដល់បច្ចុប្បន្ន។ ប៉ុន្ដែពេលហាងខ្ញុំ ទិញបង្កងយកមកប្រស់ក្នុងអាង បង្កងនេះប្រយុទ្ធដណ្ដើមញីជាមួយបង្កឈ្មោលមួយក្បាលទៀត ពេលប្រយុទ្ធគ្នានោះ បង្កងនេះចាញ់គេបាត់ដង្កៀបម្ខាង ទើបសល់តែម្ខាងអ៊ីចឹង ។

លោកកិត្យា និយាយលាយសំណើច ៖

-អ្នកឯងយកបង្កងចាញ់គេនេះទៅវិញចុះ ហើយចាប់បង្កងដែលទទួលជ័យជម្នះមកឱ្យខ្ញុំ! ។

បោះពុម្ពដោយ រោងពុម្ព **អរិយធម៌** ផ្ទះលេខ ៩២, ផ្លូវលេខ ៥៩៤, សង្កាត់បឹងកក់ II ខ័ណ្ឌទួលគោក-ភ្នំពេញ
H/P : 012 935 822 / Tel : 023 885 188 / Fax : 023 885 189 E-mail : ariyathoar@yahoo.com / ariyathoar@online.com.kh

# អ្នកឧបត្ថម្ភ ទស្សនាវដ្ដី ប្រជាជន លេខ ១៦១

| | | | | |
|---|---|---|---|---|
| ១- | ឯ.ឧ | **កែ គឹមយ៉ាន** | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្ដាល ប្រធានក្រុមការងារចុះខេត្តបន្ទាយមានជ័យ | ១០០ ដុល្លារ |
| ២- | ឯ.ឧ | **ហ៊ីន ណេង** | ប្រធានគណៈកម្មការទី ៤ នៃរដ្ឋសភា | ១០០ ដុល្លារ |
| ៣- | ឯ.ឧ | **មីន ឃិន** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងធម្មការ និងសាសនា និងលោកជំទាវ **ខួន ឆួន** | ១០០ ដុល្លារ |
| ៤- | ឯ.ឧ | **ត្រាំ អ៊ីវតឹក** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងសាធារណការ និងដឹកជញ្ជូន | ១០០ ដុល្លារ |
| ៥- | ឯ.ឧ | **ថោង ខុន** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងទេសចរណ៍ | ១០០ ដុល្លារ |
| ៦- | ឯ.ឧ | **ប្រាក់ ចំរើន** | សមាជិកព្រឹទ្ធសភា | ១០០ ដុល្លារ |
| ៧- | ឯ.ឧ | **គង់ វិបុល** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយកដ្ឋាន នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១០០ ដុល្លារ |
| ៨- | ឯ.ឧ | **លន់ លីមថៃ** | ប្រធានគណៈកម្មាធិការគណបក្សខេត្តកំពង់ចាម | ១០០ ដុល្លារ |
| ៩- | ឯ.ឧ | **ជៀង អ៊ំ** | ប្រធានគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង | ១០០ ដុល្លារ |
| ១០- | ឯ.ឧ | **អូស្មាន ហាស្សាន់** | ប្រធានគណៈចលនាសាសនិកឥស្លាមនៃគណបក្សប្រជាជនកម្ពុជា | ១០០ ដុល្លារ |
| ១១- | ឯ.ឧ | **សរ ចឺរ៉ុង** | ប្រធានគណៈកម្មាធិការគណបក្សខេត្តក្រចេះ | ១០០ ដុល្លារ |
| ១២- | ឯ.ឧ | **ផា សុជាតិវង្ស** | ប្រធានគណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ | ១០០ ដុល្លារ |
| ១៣- | ឯ.ឧ | **ឈិត សុខុន** | អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ | ១០០ ដុល្លារ |
| ១៤- | ឯ.ឧ | **ម៉ម ប៊ុននាង** | អនុប្រធានគណៈកម្មការទី ១០ នៃព្រឹទ្ធសភា | ១០០ ដុល្លារ |
| ១៥- | ឯ.ឧ | **ម៉ៅ ធនិន** | អភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់ | ១០០ ដុល្លារ |
| ១៦- | ឯ.ឧ | **អ៊ុន វីរជាតិ** | រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | ១០០ ដុល្លារ |
| ១៧- | ឯ.ឧ | **យូ តិរម្យ** | សមាជិកក្រុមការងារចុះខេត្តកំពង់ស្ពឺ ប្រធានក្រុមការងារចុះស្រុកឱរ៉ាល់ | ១០០ ដុល្លារ |
| ១៨- | គណៈកម្មាធិការគណបក្សខេត្តបាត់ដំបង | | | ១០០ ដុល្លារ |
| ១៩- | គណៈកម្មាធិការគណបក្សខេត្តសៀមរាប | | | ១០០ ដុល្លារ |
| ២០- | គណៈកម្មាធិការគណបក្សខេត្តបន្ទាយមានជ័យ | | | ៥០ ដុល្លារ |
| ២១- | គណៈកម្មាធិការគណបក្សក្រសួងកិច្ចការនារី | | | ៥០ ដុល្លារ |
| ២២- | ឯ.ឧ | **លឹម គានហោ** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក | ២០០.០០០ ៛ |
| ២៣- | ឯ.ឧ | **ម៉ម ប៊ុនហេង** | ប្រធានគណៈកម្មាធិការគណបក្សក្រសួងសុខាភិបាល | ៥០ ដុល្លារ |
| ២៤- | ឯ.ឧ | **ថា យ៉ាវ** | អនុប្រធានគណៈកម្មាធិការគណបក្សធនាគារជាតិនៃកម្ពុជា | ២១៣.៤៧០៛ |
| ២៥- | ឯ.ឧ | **ជូ យិនស៊ឹម** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | ៥០ ដុល្លារ |
| ២៦- | ឯ.ឧ | **អ៊ុក ប្រាថ្នា** | រដ្ឋលេខាធិការក្រសួងព័ត៌មាន | ២០០.០០០ ៛ |
| ២៧- | ឯ.ឧ | **ផាវ ហាមផាន** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ៥០ ដុល្លារ |
| ២៨- | ឯ.ឧ | **សូ ជុងហួរ** | ប្រធានក្រុមប្រឹក្សាខេត្តព្រះសីហនុ | ៥០ ដុល្លារ |
| ២៩- | ឯ.ឧ | **ចាយ បូរិន** | អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាម | ៥០ ដុល្លារ |
| ៣០- | ឯ.ឧ | **សួស យ៉ារ៉ា** | អ្នកតំណាងរាស្ត្រមណ្ឌលព្រះវិហារ | ៥០ ដុល្លារ |
| ៣១- | ឯ.ឧ | **នរៈ រតនៈវឌ្ឍនោ** | រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា | ២០០.០០០ ៛ |
| ៣២- | ឯ.ឧ | **ឃួន រ៉ានីន** | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៥០ ដុល្លារ |
| ៣៣- | ឯ.ឧ.ឧ.សេនីយឯក | **មាស វីរិទ្ធ** | អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រឆាំងគ្រឿងញៀន | ៥០ ដុល្លារ |
| ៣៤- | ឯ.ឧ. | **ប៊ុន លឹមហេង** | អនុរដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | ២០០.០០០៛ |
| ៣៥- | ឯ.ឧ | **សេង ទៀង** | ជំនួយការផ្ទាល់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** | ២០០.០០០៛ |
| ៣៦- | ឯ.ឧ | **ថោង ឈិន** | សមាជិកគណៈកម្មាធិការត្រួតពិនិត្យ នៃគណៈកម្មាធិការកណ្ដាល | ៥០ ដុល្លារ |
| ៣៧- | ឯ.ឧ | **ម៉ៅ ប៊ុនណារិន** | សមាជិកគណៈកម្មាធិការកណ្ដាលគណបក្សប្រជាជនកម្ពុជា | ១០០.០០០៛ |
| ៣៨- | ឯ,ឧ | **ម៉ាន ប៊ុនធឿន** | រដ្ឋលេខាធិការក្រសួងផែនការ | ១០០.០០០៛ |
| ៣៩- | លោកជំទាវ | **ស៊ឹង ស៊ុំយុត** | | ១០០.០០០៛ |
| ៤០- | ឯ.ឧ | **គឹម ធា** | ប្រធានក្រុមប្រឹក្សាខេត្តស្វាយរៀង | ១០០.០០០៛ |
| ៤១- | ឯ.ឧ | **ប៊ិច សុវណ្ណ** | | ១០០.០០០៛ |
| ៤២- | ឯ.ឧបណ្ឌិត | **មាស ប៉ូ** | អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ១០០.០០០៛ |
| ៤៣- | លោកជំទាវ | **ឥត្យ ច័ន្ទតារីន** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ១០០.០០០៛ |
| ៤៤- | ឯ.ឧ | **ឆា ច័ន្ទលីដា** | ទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** | ១០០.០០០៛ |
| ៤៥- | ឯ.ឧ | **ម៉ែន វិបុល** | ប្រធានគណៈហិរញ្ញវត្ថុនៃគណៈកម្មាធិការគណបក្សខេត្តស្វាយរៀង | ១០០.០០០៛ |
| ៤៦- | ឯ.ឧ | **ជួន ថេរ៉ាវ៉ាត** | ទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** | ១០០.០០០៛ |
| ៤៧- | ឯ.ឧ | **ម៉ៅ ឡាំង** | ទីប្រឹក្សាឯកឧត្តម **ខួន ញឹល** អនុប្រធានទី ២ រដ្ឋសភា | ១០០.០០០៛ |
| ៤៨- | ឯ.ឧ | **ឆាយ បូឆ្លីសែន** | អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | ១០០.០០០៛ |
| ៤៩- | ឯ,ឧ | **អ៊ុន ឆាលី** | សមាជិកគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណបក្សខេត្តកោះកុង | ១០០.០០០៛ |
| ៥០- | លោក | **អោម ចន** | ប្រធាននាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិនៃអគ្គនាយកដ្ឋានពន្ធដារ | ១០០.០០០៛ |
| ៥១- | លោក | **សាំ ពិសិដ្ឋ** | ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានីភ្នំពេញ | ១០០.០០០៛ |
| ៥២- | លោក | **សុខ វិសាលសម្បត្តិ** | អនុប្រធានក្រុមការងារចុះជួយឃុំព្រៃដើមថ្នឹង និងឃុំត្នោត១ ស្រុកស៊ីធរកណ្ដាល ប្រធានក្រុមហ៊ុនសម្បត្តិវិសាល | ១០០.០០០៛ |
| ៥៣- | លោក | **សារូ រដ្ឋជាតិ** | មន្ត្រីសាលាខេត្តប៉ៃលិន | ៧០.០០០៛ |
| ៥៤- | លោកជំទាវ | **ខេង សំវ៉ាដា** | រដ្ឋលេខាធិការក្រសួងកិច្ចការនារី | ៥០.០០០៛ |
| ៥៥- | ឯ.ឧ | **សាយ បូរិន** | ទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី **ហេង សំរិន** | ៥០.០០០៛ |
| ៥៦- | ឯ.ឧ | **សេង គឹមសាន** | ជំនួយការសម្ដេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** | ៥០.០០០៛ |
| ៥៧- | ឯ.ឧ | **ពត ចាន់នី** | សមាជិកក្រុមការងារចុះជួយខេត្តកំពង់ចាម | ៥០.០០០៛ |
| ៥៨- | ឯ.ឧ | **ហេង វណ្ណា** | សមាជិកក្រុមការងារគណៈកម្មាធិការកណ្ដាលចុះជួយខេត្តព្រះសីហនុ | ៥០.០០០៛ |
| ៥៩- | លោក | **ស៊ាង ចាន់** | សមាជិកក្រុមការងារគណៈកម្មាធិការកណ្ដាលចុះជួយខេត្តព្រះសីហនុ | ៥០.០០០៛ |
| ៦០- | លោក | **ឃួន សំបូរ** | សមាជិកក្រុមការងារគណៈកម្មាធិការកណ្ដាលចុះជួយខេត្តព្រះសីហនុ | ៥០.០០០៛ |

# អ្នកឧបត្ថម្ភ ទស្សនាវដ្ដី ប្រជាជន លេខ ១៦១

| | | | | | |
|---|---|---|---|---|---|
| ៦១- | លោកជំទាវ | សឿ | ច័ន្ទថា | ................................................ | ៥០.០០០៛ |
| ៦២- | លោក | ជា | វុទ្ធី | សមាជិកក្រុមការងារគណៈកម្មាធិការកណ្ដាលចុះជួយខេត្តព្រះសីហនុ ................ | ៥០.០០០៛ |
| ៦៣- | កញ្ញា | ផាង | និតហ្វើរ៍ | មន្ត្រីក្រសួងទេសចរណ៍ ................ | ៥០.០០០៛ |
| ៦៤- | លោក | ង៉ោ | ម៉េងថ្នន | អភិបាលក្រុងប៉ោយប៉ែត ................ | ៥០.០០០៛ |
| ៦៥- | លោក | អ៊ុំ | រាត្រី | ប្រធានគណៈកម្មាធិការគណបក្សក្រុងសេរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ ................ | ៥០.០០០៛ |
| ៦៦- | លោក | កែវ | សែន | ប្រធានគណៈកម្មាធិការគណបក្សស្រុកអូរជ្រៅ................ | ៥០.០០០៛ |
| ៦៧- | លោក | សួន | សុធី | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តបន្ទាយមានជ័យ ................ | ៥០.០០០៛ |
| ៦៨- | លោក | គាត | ហ៊ុល | ប្រធានគណៈកម្មាធិការគណបក្សសង្កាត់ផ្សារកណ្ដាល ខេត្តបន្ទាយមានជ័យ ................ | ៥០.០០០៛ |
| ៦៩- | លោក | ចាប | ឱណា | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស ខណ្ឌដូនពេញ ................ | ៥០.០០០៛ |
| ៧០- | ឯ.ឧ | វេង | សាខុន | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម ................ | ៤០.០០០៛ |
| ៧១- | លោក | លី | សារី | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្ស ប្រធានមន្ទីររៀបចំដែនដី ខេត្តបន្ទាយមានជ័យ ................ | ៤០.០០០៛ |
| ៧២- | លោក | គឹម | សុវណ្ណ | ប្រធានមន្ទីរសាធារណការ ខេត្តបន្ទាយមានជ័យ ................ | ៤០.០០០៛ |
| ៧៣- | ឯ.ឧ | ស៊ិន | វុទ្ធី | សមាជិកអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួងធនធានទឹក ................ | ៣០.០០០៛ |
| ៧៤- | ឯ.ឧ | ឈុំ | វណ្ណារិទ្ធ | អភិបាលរងខេត្តបន្ទាយមានជ័យ ................ | ៣០.០០០៛ |
| ៧៥- | លោក | ម៉ៅ | សុខលីម | អនុប្រធានមជ្ឈមណ្ឌលជាតិវេជ្ជសាស្ត្របូរាណក្រសួងសុខាភិបាល សមាជិកក្រុមការងារចុះខេត្តតាកែវ ................ | ៣០.០០០៛ |
| ៧៦- | លោក | ចាន់ | ស៊ីណាត | សមាជិកគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក ................ | ៣០.០០០៛ |
| ៧៧- | លោក | យូ | ពៅ | អភិបាលស្រុកស្វាយចេក................ | ៣០.០០០៛ |
| ៧៨- | លោក | នេព | វិសិដ្ឋ | អនុប្រធានគណៈត្រួតពិនិត្យគណបក្សខេត្តព្រះសីហនុ ................ | ៣០.០០០៛ |
| ៧៩- | កញ្ញា | កែវ | សុជាតា | អនុប្រធានលេខាធិការដ្ឋានអមគណៈកម្មការទី ៤ នៃព្រឹទ្ធសភា ................ | ៣០.០០០៛ |
| ៨០- | ឯ.ឧ | ចុង | ផែត | អភិបាលរងខេត្តបន្ទាយមានជ័យ ................ | ២០.០០០៛ |
| ៨១- | លោក | ឈា | ប៊ុនរិទ្ធ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ................ | ២០.០០០៛ |
| ៨២- | លោក | ម៉ៅ | ហាក់ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ................ | ២០.០០០៛ |
| ៨៣- | លោក | លឹម | វីរក្ស | សមាជិកគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក និងឧតុនិយម ................ | ២០.០០០៛ |
| ៨៤- | លោក | លឹម | ថេង | សមាជិកក្រុមការងារចុះខេត្តកណ្ដាល................ | ២០.០០០៛ |
| ៨៥- | លោក | ឃ្លោក | សំអាង | សមាជិកក្រុមការងារចុះខេត្តកំពង់ចាម ................ | ២០.០០០៛ |
| ៨៦- | លោក | ជា | គឹមលីន | ប្រធានលេខាធិការដ្ឋានអមគណៈកម្មការទី ៤ នៃព្រឹទ្ធសភា ................ | ២០.០០០៛ |
| ៨៧- | លោក | នូច | សារ៉េត | ប្រធានការិយាល័យគណនេយ្យកសិកម្ម ខេត្តបន្ទាយមានជ័យ ................ | ២០.០០០៛ |
| ៨៨- | លោក | ហ្វាង | ថ្វិន | ប្រធានគណៈហិរញ្ញវត្ថុនៃគណៈកម្មាធិការគណបក្សខេត្តបាត់ដំបង ................ | ២០.០០០៛ |
| ៨៩- | លោក | ម៉ី | វុទ្ធា | មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង ................ | ២០.០០០៛ |
| ៩០- | លោក | អ៊ុក | គឹមអាន | មន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ................ | ២០.០០០៛ |
| ៩១- | លោក | គួច | ចាន់និត្យ | អាជីវករ ខេត្តបន្ទាយមានជ័យ ................ | ២០.០០០៛ |
| ៩២- | លោក | លី | សារុន | មន្ត្រីក្រសួងហិរញ្ញវត្ថុ ................ | ១៥.០០០៛ |
| ៩៣- | លោក | អ៊ុច | សាវន | អនុប្រធានមន្ទីរកសិកម្ម ខេត្តបន្ទាយមានជ័យ ................ | ១៥.០០០៛ |
| ៩៤- | ឯ.ឧ | សេង | សុមុនី | សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សក្រសួងធម្មការ និងសាសនា ................ | ១០.០០០៛ |
| ៩៥- | ឯ.ឧ | ប៊ុញ | សច្ចះ | អគ្គនាយកកិច្ចការបច្ចេកទេសនៃក្រសួងធនធានទឹក និងឧតុនិយម ................ | ១០.០០០៛ |
| ៩៦- | លោក | មុំ | លីហួត | សមាជិកក្រុមការងារចុះខេត្តកំពង់ចាម ................ | ១០.០០០៛ |
| ៩៧- | លោក | ជួន | វណ្ណរិទ្ធ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ................ | ១០.០០០៛ |
| ៩៨- | លោក | មឹម | ប្ញស | អនុប្រធាននាយកដ្ឋានរដ្ឋបាល និងធនធានមនុស្សនៃក្រសួងធានធានទឹក និងឧតុនិយម ................ | ១០.០០០៛ |
| ៩៩- | លោក | សៅ | សម្ផស្ស | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុនៃក្រសួងនៃក្រសួងធានធានទឹក និងឧតុនិយម ................ | ១០.០០០៛ |
| ១០០- | លោក | ឈុន | ប៊ុនឈឿន | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ................ | ១០.០០០៛ |
| ១០១- | លោក | ថេង | ប៊ុនតេង | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ................ | ១០.០០០៛ |
| ១០២- | លោក | ស្វាយ | សុគន្ធី | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ................ | ១០.០០០៛ |
| ១០៣- | លោក | សុខ | ចំណាន | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ................ | ១០.០០០៛ |
| ១០៤- | លោក | សៅ | សម្ភារ | ប្រធានការិយាល័យបណ្ដុះបណ្ដាលនៃនាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស នៃក្រសួងធានធានទឹក និងឧតុនិយម ..... | ១០.០០០៛ |
| ១០៥- | លោក | និត | ចរិយា | ប្រធានការិយាល័យគណនេយ្យនាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងធានធានទឹក និងឧតុនិយម ................ | ១០.០០០៛ |
| ១០៦- | លោក | សែម | សំណាង | ប្រធានការិយាល័យគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រនាយកដ្ឋានធារាសាស្ត្រ កសិកម្ម នៃក្រសួងធានធានទឹក និងឧតុនិយម . | ១០.០០០៛ |
| ១០៧- | លោក | សុខ | តារា | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ................ | ១០.០០០៛ |
| ១០៨- | លោក | ស៊ូ | ផល្លី | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ................ | ១០.០០០៛ |
| ១០៩- | លោក | ហួត | ធាន | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ................ | ១០.០០០៛ |
| ១១០- | លោក | ទឹម | វុឌ្ឍារី | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ................ | ១០.០០០៛ |
| ១១១- | លោក | ណុប | វឿមណី | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ................ | ១០.០០០៛ |
| ១១២- | លោក | សារុន | សម្បត្តិ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ................ | ១០.០០០៛ |
| ១១៣- | លោក | សរ | វិចិត្រ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ................ | ១០.០០០៛ |
| ១១៤- | លោក | នូច | សុផល្លា | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ................ | ១០.០០០៛ |
| ១១៥- | លោក | ជុំ | ឧត្តរ៉ា | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ................ | ១០.០០០៛ |
| ១១៦- | លោក | ឈ្លាង | ប៊ុយ | សមាជិកក្រុមការងារចុះខេត្តកណ្ដាល ................ | ១០.០០០៛ |
| ១១៧- | លោក | យស់ | ធុល | សមាជិកក្រុមការងារចុះស្រុកកំពង់លាវ ខេត្តព្រៃវែង ................ | ១០.០០០៛ |
| ១១៨- | លោក | ឡុង | ចន្ថា | សមាជិកក្រុមការងារចុះស្រុកកំពង់លាវ ខេត្តព្រៃវែង ................ | ១០.០០០៛ |
| ១១៩- | លោក | ឡាច | គីរ៉ាត់ | សមាជិកក្រុមការងារចុះស្រុកបាភ្នំ ខេត្តព្រៃវែង ................ | ១០.០០០៛ |
| ១២០- | លោក | ឈាង | សុវណ្ណារ៉ា | មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង ................ | ១០.០០០៛ |



**និពន្ធនាយក ៖**
**លោក តាក ស៊ុនអ៊ី**
**គណៈកម្មការនិពន្ធ**
១. លោក ខៀវ ណារី
២. លោក អ៊ឹម សុន្ទរ:
៣. លោក វង្ស សារ៉ុធ
៤. លោក ទាវ សារៈមុនី
៥. លោក សុខ សុធន
**លេខានិពន្ធ**
១. លោក ជុំ សម្បត្តិ
២. លោក ម៉ក់ ឈិន
**អ្នកបកប្រែភាសា**
១. លោកស្រី ម៉ែន នារីសោភ័គ
**អ្នកថតរូប**
១. លោក សុផាត វីរៈមុនី
**វិចិត្រករ**
១. លោក ធា សារ៉ុធ
អាស័យដ្ឋាន ៖
លេខ ២០៣
មហាវិថី ព្រះនរោត្តម
ភ្នំពេញ-កម្ពុជា
ទូរស័ព្ទលេខ ៖
០២៣ ២១៩ ០៦៥
**Address :**
**No 203 Preah Norodom Bld.**
**Phnom Penh Cambodia**
**Tel : 023 219 065**



*សម្តេចប្រធានព្រឹទ្ធសភា ទទួលជួបសវនាការជាមួយឯកអគ្គរដ្ឋទូតថ្មី នៃប្រទេសវៀតណាមប្រចាំកម្ពុជា* ៦



*កិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប លើកទី ១០ ក្រោមប្រធានបទ ភាពជាដៃគូទទួលខុសត្រូវ សម្រាប់កំណើនដោយចីរភាព និងសន្តិសុខ* ៧




*សម្តេចតេជោ ៖ កម្ពុជាមិនអាចស្ថប់ស្ថល់នៅស្ងៀមទេ ត្រូវតែបន្តកែទម្រង់* ៩



*គណបក្សប្រជាជនទទួលបានភាពជាអ្នកដឹកនាំនៅក្នុងតួនាទី របស់គណបក្សនយោបាយនៅអាស៊ី* ១៣

## ក្របមុខ

*សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ទទួលជួបសវនាការជាមួយ ឯកឧត្តម **ថាច់ហ៊ឿ** ឯកអគ្គរដ្ឋទូតថ្មី នៃប្រទេសវៀតណាមប្រចាំកម្ពុជា*

# មាតិកា
# Contents

*វិចារណកថា ៖ កម្ពុជានឹងបន្តឈានទៅមុខ ដោយរក្សាបានល្បឿននៃកំណើនសេដ្ឋកិច្ចនិងចីរភាពនៃការអភិវឌ្ឍ*
*Editorial : Cambodia to Advance in Momentum of Economic Growth and Sustainable Development* .......... ៣
➩ *ការដកហូតដីសម្បទានសេដ្ឋកិច្ចដែលមិនបានធ្វើការអភិវឌ្ឍបានទទួលការគាំទ្រពីគ្រប់មជ្ឈដ្ឋាន* .......... ៥

➩ *សកម្មភាពសមាជិកព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស* .......... ១៤
➩ *លទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច* .......... ១៦
➩ *រាជរដ្ឋាភិបាលចាប់ផ្តើមបង្កើតប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពចំណីអាហារ ឱ្យមានកម្រិតស្តង់ដារអន្តរជាតិ* .......... ១៨
➩ *ទេសចរណ៍កម្ពុជាក្នុងចក្ខុវិស័យនៃជំហានរីកចម្រើន* .......... ២០
➩ *វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរួមចំណែកយ៉ាងសំខាន់ ក្នុងការកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយចីរភាព* .......... ២២
➩ *វប្បធម៌ ៖ អភិរក្ស និងអភិវឌ្ឍបេតិកភណ្ឌវប្បធម៌ជាតិ ដើម្បីចូលរួមអភិវឌ្ឍសេដ្ឋកិច្ចសង្គម* .......... ២៥
➩ *ចំណេះដឹងទូទៅ ៖ ពិភពលោកទាំងមូលត្រូវរួមគ្នាទប់ស្កាត់បម្លាស់ប្តូរអាកាសធាតុដ៏ធ្ងន់ធ្ងរ* .......... ២៦
➩ *វិទ្យាសាស្ត្រ សុខភាព ៖ អត្ថប្រយោជន៍ពីការទទួលទានទឹកក្រូចឆ្មារ.....តើការរៀចខ្ចង់ច្រមុះអាច* .... ២៧
➩ *ទឹកដី មាតុភូមិ ៖ យើងស្រឡាញ់ខេត្តពោធិ៍សាត់របស់យើង* .......... ២៨
➩ *កំណាព្យ ៖ រលើមផ្សែងក្រូច* .......... *សំណើច* .......... ៣១

ទស្សនាវដ្តី

# ប្រជាជន

THE PRACHEACHUN MAGAZINE







ឆ្នាំទី១៤ លេខ ១៦១ ខែតុលា ឆ្នាំ ២០១៤



អគារមជ្ឈមណ្ឌលវិទ្យាសាស្ត្រប្រព័ន្ធប្រសាទ  ស្ថិតក្នុងមន្ទីរពេទ្យកាល់ម៉ែត

(សម្ពោធថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០១៤)



ស្ពានព្រែកសំរោងប្រវែង ៨៥៥ ម៉ែត្រ ឆ្លងកាត់ទន្លេបាសាក់ ក្រុងតាខ្មៅ ខេត្តកណ្ដាល
បើកឱ្យប្រជាពលរដ្ឋប្រើប្រាស់ជាបណ្ដោះអាសន្ន

ចែកជូនដោយឥតគិតថ្លៃ